# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## និក្ខេបបទ

# ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិង គណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិ ហៅថា ( SEIP )

## ករណីសិក្សា៖ ខេត្តព្រះសីហនុ

# The Impact of Grade 6 and 7 testing in Khmer and mathematics language of the project to improve the quality of education at the lower secondary school called (SEIP) Case Study in Preah Sihanouk Province

**ឈូក ដន**

CHHOUK DORN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២១**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិ ហៅថា( SEIP )

## ករណីសិក្សា៖ ខេត្តព្រះសីហនុ។

## The Impact of Grade 6 and 7 testing in Khmer and mathematics language of the project to improve the quality of education at the lower secondary school called (SEIP) Case Study in Preah Sihanouk Province.

**ឈូក ដន**

CHHOUK DORN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

សាស្ត្រាចារ្យដឹកនាំ ៖ លោកបណ្ឌិត នី រដ្ឋា

សាស្ត្រាចារ្យដឹកនាំរង ៖ លោក ឌី បុណ្ណា

# សេចក្តីធានាអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា"ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិហៅថា"SEIP" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២១

**ហត្ថលេខា**

**ឈូក ជន**

# លិខិតបញ្ជាក់

| | | | |
|---|---|---|---|
| លោកបណ្ឌិត | **នី** | **រដ្ឋា** | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក | **ឌី** | **បុណ្ណា** | ជាសាស្ត្រាចារ្យដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ឈូក ជន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិហៅថាSEIP**" ពិតប្រាកដមែន។

ថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២១

| | |
|---|---|
| ........................................... | ........................................... |
| **បណ្ឌិត នី រដ្ឋា** | **លោក ឌី បុណ្ណា** |
| ប្រធានការិយាល័យសិក្សា នៃវិទ្យាស្ថានជាតិអប់រំ | នាយករង វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣២០៥ អយក. ១៩

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ទី ឌាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈួក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ទី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ រ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអេ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី ផ្សៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងធាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ុំ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៨ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ិច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ អាទិត្យ ៥កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ -ឯកសារ រដអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និង ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយទាំងកម្លាំងកាយនិងកម្លាំងចិត្ត។

ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារ៉ា** នាយកនៃវិទ្យាស្ថានជាតិអប់រំ និងលោកបណ្ឌិត **នួន ធីរ៉ា** នាយករង។

ជាមួយគ្នានេះដែរខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកបណ្ឌិត **នី រដ្ឋា** សាស្ត្រាចារ្យដឹកនាំ ដែលតែងតែចំណាយពេលវេលាមកពន្យល់ ខ្ញុំបាទគ្រប់ជំហាន ទើបធ្វើឲ្យការស្រាវជ្រាវរបស់ខ្ញុំបាទពេលនេះទទួលបានជោគជ័យនិងភាពរលូន។ មិត្តរួមជំនាន់ទី ៨ ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្តតាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

សូមថ្លែងអំណរគុណដល់លោក **ឌី មុន្នីណា** សាស្ត្រាចារ្យដឹកនាំរងដែលជួយយើងខ្ញុំក្នុងការសរសេរនិក្ខេបបទនេះឡើង លោកបានដឹកនាំកែតម្រូវបង្ហាញផ្លូវក្នុងការសរសេរនិក្ខេបបទរហូតមក។

សូមថ្លែងអំណរគុណដល់គណៈកម្មការវាយតម្លៃទាំងពីរ ដែលបានផ្តល់ការទូន្មានលើកទឹកចិត្ត កែលម្អរាល់ចំណុចខ្វះខាតដើម្បីឱ្យការស្រាវជ្រាវនិក្ខេបបទមួយនេះកាន់តែល្អប្រសើរ។

សូមថ្លែងអំណរគុណដល់ មន្ទីរអប់រំយុវជន និងកីឡាខេត្តព្រះសីហនុ ការិយាល័យ អប់រំយុវជន និងកីឡា ជានិច្ចកាលលោកតែងតែគាំទ្រនិងជួយ ធ្វើឱ្យមានការចូលរួមពីសាលារៀន និងការសរសេរនិក្ខេបបទមានការប្រែប្រួលគួរជាទីមោទនៈ។

សូមអរគុណដល់គណៈនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍វិទ្យាល័យទាំងបី ដែលបានចូលរួមសហការក្នុងផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវសរសេរនិក្ខេបបទមួយនេះ។ បន្ថែមពីនេះទៀតខ្ញុំសូមថ្លែងអំណរគុណដល់ លោកឪពុក **ឈូក ឌីម** អ្នកម្តាយ **សៅ បាន** លោកឪពុកក្មេក **ម៉ុន ឆួន** អ្នកម្តាយ **ជា ផាច** បងប្អូន និងភរិយារបស់ខ្ញុំ (**ម៉ុន ដានី**) ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញនិងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។ ខ្ញុំក៏សូមឧទ្ទិសនូវស្នាដៃនៃការសិក្សាស្រាវជ្រាវនេះជូនចំពោះលោកតា **ម៉ច់ ឈូក** និងលោក យាយ **សោម អ៊ាច**(ហៅលោកយាយ ឈូក) ដែលបានបែកកាយទៅកាន់លោកខាងមុខហើយក្តីសុខ សូមឲ្យលោកទាំងពីរទទួលបាននូវអ្វីដែលជាការខិតខំបណ្តុះបណ្តាលថៅឲ្យមានថ្ងៃនេះផងចុះ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយាកូនខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

ស្របតាមបរិបទនៃការសិក្សាអប់រំនៅកម្ពុជា សព្វថ្ងៃនេះក្រសួងអប់រំយុវជន និងកីឡា យើងបាន ពង្រឹងពង្រីក គុណភាពនាយក គ្រូ និងសិស្ស បញ្ញារ័នឲ្យទៅបណ្តុះបណ្តាលផ្តល់អាហារូបករណ៍សិស្ស និងគ្រូ ហើយបាន កែទម្រង់ស៊ីជម្រៅទៅលើវិស័យអប់រំនៅទូទាំងប្រទេស និងរៀបចំឲ្យមានគុណភាព និងការ បណ្តុះបណ្តាលដើម្បីទទួលបានធនធានមនុស្សប្រកបដោយគុណភាព ប្រសិទ្ធិភាពនិង លទ្ធផល អាចទទួលយកបាន។ ដើម្បីទទួលបានលទ្ធផលបែបនេះ យើងគួរតែយកចិត្តទុកដាក់លើការធ្វើតេស្តស្តង់ ដាសិស្សនៅកម្រិតសាលារៀនបឋមភូមិព្រោះថា បច្ចុប្បន្ននេះសិស្សមានការសិក្សាខ្សោយជាពិសេស ភាសាខ្មែរ(អំណាន) និងគណិតវិទ្យា និងអនុលោមតាមគោលនយោបាយទី២ នៃផែនការយុទ្ធសាស្ត្រ វិស័យអប់រំជាតិ គោលការណែនាំស្តីពីការគ្រប់គ្រងតាមសាលារៀន (SBM) ពង្រឹងការគ្រប់គ្រងនៅតាម សាលារៀនសាធារណៈ។ ទន្ទឹមនោះលទ្ធផលសិក្សារបស់សិស្សចំណុះកត្តាធំ៤យ៉ាង នាយកល្អ គ្រូបង្រៀនល្អ សិស្សល្អ មាតាបិតានិងសហគមន៍ល្អ ។ លើសពីនេះការលើកកម្ពស់គុណភាព ប្រសិទ្ធិភាព ក្នុងការអប់រំ គឺតម្រូវការួលរួមពីសំណាក់សាលារៀន ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្ម ការគ្រប់គ្រងសាលារៀន គណៈនាយក លោកគ្រូអ្នកគ្រូ មាតាបិតាអ្នកអាណាព្យាលសិស្ស សហគមន៍ សិស្សានុសិស្សផ្ទាល់។

ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយកប្រធានបទ ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា បឋមភូមិហៅ ថា(SEIP)ករណីសិក្សា៖ ខេត្តព្រះសីហនុ យកមកធ្វើជារបាយការណ៍ស្រាវជ្រាវ ហើយមានគោល បំណងពីរ៖ (១) សិក្សាពីកម្រិតដំណើរការដឹកនាំ គ្រប់គ្រងបង្រៀន និងរៀនសម្រាប់អនុវត្តតេស្តលើ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧បាន (២)រកឱ្យឃើញពី កត្តានានាដែលជាផលជះនៃការធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បី អាចរៀនថ្នាក់ទី៧។

វិធីសាស្ត្រនៃការស្រាវជ្រាវនេះយើងអនុវត្តយកតាមបែបបរិមាណវិស័យ។ ភាគសំណាកយើងទៅលើខេត្តព្រះសីហនុះការិយាល័យអប់រំស្រុកមានចំនួន៦នាក់ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនមានចំនួន៤០នាក់ គណៈគ្រប់គ្រងសាលាមានចំនួន៨នាក់ គ្រូបង្រៀនមានចំនួន៤៥នាក់ អាណាព្យាបាលសិស្សមានចំនួន៦១នាក់ និងសិស្សានុសិស្សមានចំនួន៦០នាក់។ កម្រងសំនួរចែកជា៥ផ្នែក គឺផ្នែកទី១៖ ព័ត៌មានទូទៅ ផ្នែកទី២៖ ដំណើរការគ្រប់គ្រង ផ្នែកទី៣៖ អំពីការទំនាក់ទំនង ផ្នែកទី៤៖ ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ផ្នែកទី៥៖ ផលជះនិងសំណូមពរ និយាយពីពត៌មានផ្ទាល់ខ្លួនរបស់ ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស និងសិស្ស។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ បានយកចម្លើយដែលបានមកពីកម្រងសំណួរ ទាំងអស់មកវិភាគ តាមកម្មវិធី Excel ដើម្បីរកជាភាគរយ(%) តម្លៃមធ្យម(Mean) និងគម្លាតស្តង់ដា(S.D) កម្រិត លំដាប់។

តាមរយៈលទ្ធនៃការសិក្សាស្រាវជ្រាវនេះតាមកម្រិតក្រុមគោលដៅនីមួយៗបានបង្ហាញថា៖

ការចូលរួមរបស់(១)ការិយាល័យអប់រំស្រុកមានតម្លៃមធ្យម(Mean)=4.47 , SD=0.10 ស្ថិតនៅកម្រិតខ្ពស់។ (២)អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន មានតម្លៃមធ្យម(Mean)= 4.68,SD=0.19ស្ថិតនៅកម្រិតខ្ពស់។ (៣)គណៈគ្រប់គ្រងសាលារៀនមានតម្លៃមធ្យម(Mean)= 3.92 , SD=0.40 ស្ថិតនៅកម្រិតខ្ពស់។ (៤)គ្រូបង្រៀនមានតម្លៃមធ្យម(Mean)=4.29 , SD=0.13 ស្ថិតនៅកម្រិតខ្ពស់។ (៥)មាតាបិតារឺអ្នកអាណាព្យាបាលសិស្ស មានតម្លៃមធ្យម(Mean)=4.36 , SD=0.11 ស្ថិតនៅកម្រិតខ្ពស់។ (៦)សិស្សមានតម្លៃមធ្យម(Mean)=4.38 , SD=0.08 ស្ថិតនៅកម្រិតខ្ពស់។ នៅក្នុងសាលារៀននៅក្នុងខេត្តព្រះសីហនុមានតម្លៃមធ្យម(Mean)=4.35 , SD=0.25 ស្ថិតនៅកម្រិតខ្ពស់។ នៅក្នុងដែរក៏មានចំណុចអវិជ្ជមានមួយចំនួនគឺ៖ (១)សិស្សមួយចំនួននៅមានពិន្ទុទាប (២)មាតាបិតាចូលរួមប្រជុំធ្វើផែនការកែលម្អ សាលារៀននៅមានចំនួនតិច(៣) មាតាបិតាឬអ្នកអាណាព្យាលសិស្សមិនបានពង្រឹងការរៀនរបស់កូនៗពេលនៅផ្ទះ។ (៤)សិស្សមួយចំនួនតូចមិនចូលអានសៀវភៅក្នុងបណ្ណាល័យ

សរុបសេចក្តីមកផលជះនៃការធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ ដើម្បីអាចរៀនថ្នាក់ទី៧ មានភាពគួរឲ្យកត់សំគាល់នៅក្នុងនោះផងដែរ យើងក៏មានឃើញបញ្ហាមួយ អាជ្ញាធរដែនដី/គាណៈកម្មការ គ្រប់គ្រងសាលារៀន គ្រូ មាតាបិតាឬអ្នកអាណាព្យាលសិស្ស សិស្ស មានចំណុចអវិជ្ជមាន។ ក្រសួងអប់រំយវជន និងកីឡា ត្រូវមានវគ្គបំប៉នបន្ថែម និងមានការបណ្តុះបណ្តាល គណៈនាយក គ្រូសិក្សាលើវិធីសាស្រ្តបង្រៀនល្អៗ ជួយសិស្សរៀនយឺតនិងការស្រាវជ្រាវវិធីសាស្រ្តថ្មីៗល្អ និងការរៀបចំតាក់តែងតេស្តដោយមានស្តង់ដាជួយដល់សិស្សរៀនខ្សោយ និងរៀនយឺត(មានចំណេះដឹងជាមូលដ្ឋានថ្នាក់បឋមសិក្សាដើម្បីបន្តទៅចូលរៀនថ្នាក់ទី៧) និងដើម្បីលើកកម្ពស់ប្រសិទ្ធិភាពនៃការអនុវត្តលើការបង្រៀន និងរៀន តាមសាលារៀនស្របតាមទិដ្ឋភាពសង្គមជាក់ស្តែងឆ្លើយតបតាមការចង់បានរបស់សាលារៀននិងសហគមន៍ក៏ដូចកម្មវិធីកំណែទម្រង់គុណភាពអប់រំរបស់ក្រសួងអប់រំយុវជននិងកីឡា នៅក្នុងប្រទេសទេសកម្ពុជា ។

# Abstrat

According to the context of Education in Cambodia nowadays, The Ministry of Education youth and Sports, have strengthened and expanded the quality of principal's teachers and intellectuals to train and provide scholarships for teachers and in-depth reform in the of education across the country and provide quantity training & we should pay attention to the standard testing at primary school. Level. As the week students now, especially in Khmer and Math According to the second policy of the National Education strategies plan the school management guidelines (SBM) in public school. By the way, students learning out comes are based on 4 factors. Good principals, Good - students, good parents, Good communities.

For this study topic in pact of six and a grade focus on Khmer and Math subjects of Secondary education quantity to improve the project (SIEP). Sihanouk province make are sea ich report and have 2 objectives (1) leadership management, teaching and learning for testing on Khmer and Math to grade six students to be able to student in grade 7. (2) To find out the factor of treating result in Khmer and Math.

This Method of research is carried out on a quantitative basis in Sihanouk province. The District Education office has six members The local authority, school arrangement committee has 40 mars Bers, the management committee has 8 members and 45 teachers; 67. parents and to students. The questionaries are divided into 5 sectors: (Part) general information, Part2. management process, Part3) communication, (Part 4) testing of Khmer and Math, (Parts) suggest time on personal information. After divided from quiz From Excel analysis to find percentage (2.) Mean and standard deviation (so) sequence Level.

The result of research at each target group Level showed that the participation (1) 07 District Education office Mean= 4.47. SD=010. was high (2) Local authorities committee school manageress (Mean) 4.68 SD = 0.19 were high. (3) School management value Mean=3.92 SD-0.40 is high (4) Teacher average value (Mean) =4.29 SD=0.13 is high (5) Parents average (Mean) =4.36 Scum is a high Level. Lo students (Mean)= 4.38 SD=0.08 in Sihanouk the (Mean) = 4.35 SD = 0.25 and there are some negative points. up Some students Still low scores (2) Parents participant School improvement planning Meeting sane1 Parents don't teach the children at home A small Menon of students read in the participate about 1 test are son all, Library o in conclusion, The tearing of Khmer and Tithes on grade six students to be able to study in grade & is significant that there are some problems with the local authority, management committee, schools, teachers, parents or Guardia ns of students. The Ministry of Education, youth and sport have to refresher courses and training of good methods.

As well as the reform program of Ministry of Education, Youth and sports in Cambodia.

# មាតិកា

**សេចក្តីធានាអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់** ........ ii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ** ........ iii
**សេចក្តីថ្លែងអំណរគុណ** ........ v
**មូលន័យសង្ខេប** ........ vii
**មាតិកា** ........ xi
**ជំពូកទី១** ........ 1
សេចក្តីផ្តើម ........ 1
១.១-សាវតា ........ 1
១.២-ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 6
១.៣-គោលបំណងនៃការស្រាវជ្រាវ ........ 9
១.៤-សំណួរស្រាវនៃការស្រាវជ្រាវ ........ 10
១.៥-សារៈសំខាន់នៃការស្រាវជ្រាវ ........ 10
១.៦-ដែនកំណត់នៃវិសាលភាពនៃការស្រាវជ្រាវ ........ 11
១.៧- រចនាសម្ព័នស្រាវជ្រាវ ........ 11
**ជំពូកទី២** ........ 12
**ការរំលឹកទ្រឹស្តី** ........ 12
២.១. និយមន័យ ........ 12
២.១គោលបំណងនៃការធ្វើតេស្ត ........ 14
២.២-ទង្វើតេស្តក្នុងដំណើរការសិក្សា ........ 14
២.៣-កំណែទម្រង់ជាប្រព័ន្ធ និងការគ្រប់គ្រងតាមសាលារៀន ........ 18
២.៣.១ គំនិតផ្តួចផ្តើមសកល និងទិដ្ឋភាពនៃកំណែទម្រង់ការអប់រំមានសារៈសំខាន់ ........ 19
២.៣.២ នាយកសាលាល្អ ........ 21
២.៣.៣. តួនាទី និងភារកិច្ចរបស់នាយក ........ 23
២.៣.៤. ភាពជាអ្នកដឹកនាំការបង្រៀន (Instructional leadership) ........ 26
២.៣.៥ គ្រូបង្រៀននៅក្នុងសាលារៀន ........ 27
២.៣.៦ប្រតិបត្តិវិជ្ជាជីវៈ ........ 28
២.៦.៧-ក្របខ័ណ្ឌ គន្លងអាជីបគ្រូបង្រៀនកម្ពុជា ........ 29
២.៦.៨ ចំណុចខ្លាំងនិងចំណុចខ្សោយនៃវិធីសាស្រ្ត ........ 30
២.៦.៩ វិធីសាស្រ្តរៀន និងបង្រៀនតាមបែបត្រិះរិះ ........ 30
២.៦.១០ គ្រូទទួលបន្ទុកថ្នាក់ខ្លួន ........ 31
២.៦.១១-សីលធម៌វិជ្ជាជីវៈ ........ 33

២.៦.១២ កត្តាសិស្ស....................................................................................................36
៣-សហគមន៍ ............................................................................................................39
៣.១.១ស ហាគមន៍និងសាលារៀន ................................................................................39
៣.១.២ ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍ ..........................................................39
៤ -យន្តការតេស្តគណិតវិទ្យាថ្នាក់ទី៦ឡើងទី៧ ដើមឆ្នាំសិក្សា .........................................40
**ជំពូកទី ៣** ..........................................................................................................62
វិធីសាស្រ្តស្រាវជ្រាវ......................................................................................................62
៣.១ គម្រោងវិភាគ ........................................................................................................62
៣.២ ការប្រមូលទិន្នន័យ .................................................................................................62
៣.៣ ឧបករស្រាវជ្រាវ.......................................................................................................63
៣.៤.១ កម្រិតចង្អុលបង្ហាញ ................................................................................................64
៣.៤.២ កម្រងសំណួរ .........................................................................................................66
៣.៤.៣ កម្រងសំណួរសម្រាប់ការិយាល័យអប់រំយុវជននិងកីឡាស្រុក ...................................66
៣.៤.៤ កម្រងសំណួរសម្រាប់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន.....................66
៣.៤.៥ កម្រងសំណួរសម្រាប់ គណៈគ្រប់គ្រងសាលារៀន ....................................................67
៣.៤.៦ កម្រងសំណួរសម្រាប់ គ្រូបង្រៀន.............................................................................67
៣.៤.៧ កម្រងសំណួរសម្រាប់ មាតាបិតារឺអាណាព្យាបាលសិស្ស...........................................67
៣.៤.៨ កម្រងសំណួរសម្រាប់ សិស្សានុសិស្ស ........................................................................68
៣.៤.៩ ការជ្រើសរើសសំណាក..............................................................................................68
៣.៤.១០ ការវិភាគទិន្នន័យ ..................................................................................................71
៣.៤.១១ ក្រមសីលធម៌នៃសិក្សាស្រាវជ្រាវ.............................................................................71
**ជំពូក៤**...................................................................................................................73
**លទ្ធផល និងពិភាក្សា**...................................................................................................73
៤.១. ឧបករណ៍វិភាគទិន្នន័យ ..........................................................................................73
៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ .............................................................................73
៤.៣. លទ្ធផលនៃការវិភាគទិន្នន័យ ....................................................................................74
៤.៤ ការវិភាគទិន្នន័យទម្រង់ការិយាល័យអប់រំយុវជននិងកីឡាស្រុក ..................................74
**ផ្នែកទី១ ពត៌មានទូទៅ** ................................................................................................74
៤.៣.២ ការវិភាគទិន្នន័យទម្រង់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រង................................86
សាលារៀន .................................................................................................................86
ផ្នែកទី១ ពត៌មានទូទៅ.....................................................................................................86
៤.៣.២ ការវិភាគទិន្នន័យទម្រង់គណៈគ្រប់គ្រងសាលារៀន ..................................................95
ផ្នែកទី១ ពត៌មានទូទៅ.....................................................................................................95

៤.៣.២ ការវិភាគទិន្នន័យទម្រង់គ្រូបង្រៀន......105
ផ្នែកទី១ ពត៌មានទូទៅ......105
៤.៣.២ ការវិភាគទិន្នន័យទម្រង់មាតាបិតា អាណាព្យាបាលសិស្ស ......112
ផ្នែកទី១ ពត៌មានទូទៅ......112
៤.៣.៣ ការវិភាគទិន្នន័យទម្រង់សិស្សានុសិស្ស ......120
ផ្នែកទី១ ពត៌មានទូទៅ......120
៤.៤-ការពិភាក្សាចំពោះលទ្ធផល......132
ជំពូកទី៥......136
សេចក្តីសន្និដ្ឋាន និងសំណូមពរ......136
៥.សេចក្តីសន្និដ្ឋាន៖ ......136
៥.១-សំណូមពរ ......140
៥.១.១ ចំពោះក្រសួងអប់រំយុវជន និងកីឡា ......140
៥.១.២ ចំពោះមន្ទីរអប់រំ......140
៥.១.៣ ចំពោះការិយាល័យអប់រំស្រុក ......141
៥.១.៤ ចំពោះអាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន......141
៥.១.៥ ចំពោះគណៈនាយក ......141
៥.១.៦ ចំពោះគ្រូបង្រៀន......141
៥.១.៧ ចំពោះមាតាបិតាសិស្ស......141
៥.១.៨ ចំពោះសិស្ស ......142
៥.១.៩ ការស្រាវជ្រាវបន្ត......142
ឯកសារយោង៖ ......143
ឧបសម្ព័ន្ធ "ក"......145
តារាងឧបសម្ព័ន្ធ(២)......156
កម្រងសំណួរស្រាវជ្រាវសម្រាប់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន ......156
តារាងឧបសម្ព័ន្ធ(៣)......164
តារាងឧបសម្ព័ន(៤)......174
តារាងឧបសម្ព័ន្ធ(៥)......182
តារាងឧបសម្ព័ន(៦)......190
តារាងឧបសម្ព័ន(៧)......198
លិខតអនុញ្ញាតការចុះប្រមូលទិន្នន័យ......198
ឧបសម្ព័ន្ធ(៨) ......199
លិខិតអញ្ជើញធ្វើបទបង្ហាញ......199

# ជំពូកទី១

# សេចក្ដីផ្ដើម

# ជំពូកទី១

# សេចក្ដីផ្ដើម

## ១.១-សាវតា

ពីដើមការសិក្សាត្រូវធ្វើតេស្តសម្រាប់គោលបំណងម្យ៉ាងសំរាប់បញ្ជាក់ការសិក្សាតែប៉ុណ្ណោះដូចជាការបញ្ជាក់ការសិក្សាឲ្យសិស្សឡើងថ្នាក់ ឬចូលមហាវិទ្យាល័យនានា។

សព្វថ្ងៃនេះ ប្រព័ន្ធនៃទធ្វើតេស្ត និងវង្វាយតម្លៃការសិក្សាអប់រំ រីកលូតលាស់យ៉ាងឆាប់រហ័សនិងបម្រើគោលបំណងឬមុខងារដ៏ទូលំលាយ ដូចជាការពិនិត្យតាមដានការសិក្សា ប្រមូលពត៌មានត្រឡប់ពីការវីចម្រើននៃការសិក្សារបស់សិស្ស វិនិច្ឆ័យរកប្រភពនៃការពិបាកក្នុងការសិក្សា និងវាយតម្លៃលទ្ធផលសរុបនៃការសិក្សារបស់សិស្ស។ជាពិសិស្សលទ្ធផលតេស្តមានសារៈសំខាន់បំផុតនៅក្នុងប្រព័ន្ធអប់រំសព្វថ្ងៃគឺបម្រើជាជំនួយក្នុងការសម្រេចចិត្តផ្សេងៗលើដំណើការសិក្សា និងការគ្រប់គ្រង។

ថ្វីបើមានការលូតលាស់យ៉ាងខ្លាំងក្លាអស់រយៈពេលមួយទស្សវត្ស មកក្ដីប្រទេសកម្ពុជានៅតែជាប្រទេស មួយក្នុងចំណោមបណ្ដាប្រទេសមិនសូវអភិវឌ្ឍក្នុងតំបន់អាស៊ីអាគ្នេយ៍។ប្រមាណជា២០ភាគរយនៃប្រជាជនកម្ពុជារកចំណូលបានតិចជាង១ដុល្លាក្នុងមួយថ្ងៃហើយប្រមាណ២៤% ភាគរយ នៃពលរដ្ឋកម្ពុជារស់នៅក្រោមបន្ទាត់ក្រីក្រ។ ទិដ្ឋភាពទូទៅនៃជីវិតប្រចាំថ្ងៃរស់ប្រជាពលរដ្ឋមានលក្ខណៈងាយរងគ្រោះ អាស្រ័យដោយភាពក្រីក្រ វត្តមាននៃចំការមីន ពិការភាព នៃករណីខ្ពស់នៃអត្រាស្លាប់ព្រមទាំងមានជំងឺ ហើយផលប៉ះពាល់ទាំងអស់នេះ ត្រូវបានធ្វើឲ្យអាក្រក់ថែមទៀតដោយកង្វះខាតសំណាញ់សុវិត្ថភាពសង្គមប្រកបដោយប្រសិទ្ធភាព។ មួយភាគបួននៃគ្រួសារទាំងអស់ គឺមានស្ត្រីជាមេគ្រួសារហើយ៥៩ភាគរយនៃប្រជាជនសរុបគឺ ពឹងផ្អែកលើវិស័យក សិកម្មដើម្បីចិញ្ចឹមជីវិត។រាជរដ្ឋាភិបា

លកម្ពុជា(RGC) និងសហគមន៍អ្នកផ្ដល់ជំនួយកំពុងធ្វើការរួមគ្នាដើម្បីឆ្លើយតបបញ្ហាជាច្រើនក្នុងចំណោមបញ្ហាទាំងអស់នេះ។

ការសម្រេចបានសក្តានុពលការអប់រំដើម្បីឈានទៅជំរុញការរីកលូតលាស់ គឺជាអទិភាពមួយសម្រាប់ប្រទេសកម្ពុជា។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិរបស់កម្ពុជា និងយុទ្ធសាស្រ្តចតុកោណ អំពាវនាវឲ្យបង្កើតសេដ្ឋកិច្ចដែលមានលក្ខណៈប្រកួតប្រជែងមួយ តាមរយៈចំណេះដឹង និងការបង្កើតថ្មី ដើម្បីបង្កើតមូលដ្ឋានដ៏រឹងមាំ ផែនការយុទ្ធសាស្រ្តការអប់រំ(ESP)ផ្តោតយកការទុកដាក់លើបញ្ហាគន្លឹះចំនួនពីរៈការសម្រេចបានលទ្ធភាពទទួលបានការអប់រំកម្រិតមូលដ្ឋានមានគុណភាពខ្ពស់ជាសាកល និងការលើកកម្ពស់ឱកាសការអប់រំស្មើគ្នាដើម្បីបង្កើនចំណូល និងមុខរបរ។

ជាលទ្ធផល ប្រទេសកម្ពុជាបានពង្រីកលទ្ធភាពទទួលបានការអប់រំក្នុងរយៈពេលជាង២០ឆ្នាំចុងក្រោយនេះ។អត្រាការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាបានកើនឡើង៨៣,៨ភាគរយ ក្នុងឆ្នាំ១៩៩២ រហូតដល់៩៦,៤ ភាគរយ ក្នុងឆ្នាំ២០១២ ហើយអត្រាចុះឈ្មោះចូលរៀនកម្រិតមធ្យម សិក្សាបានកើនឡើងពី១៦,៦ភាគរយ ក្នុងឆ្នាំ២០០០ រហូតដល់៣៥,១ភាគរយក្នុងឆ្នាំ២០១២។ បន្ថែមលើសនេះទៅទៀតក្មេងស្រីមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានឱកាសការអប់រំៈ សន្ទស្សន៍ភាពខុសគ្នាផ្នែកយេនឌ័រសម្រាប់ការចុះឈ្មោះចូលរៀនក្នុងឆ្នាំ២០១១/១២ ដែលជាផលនៃចំនួនកុមារីធៀបជាមួយកុមារ ដែលបានចុះឈ្មោះនៅដំណាក់កាលជាក់លាក់ គឺមានចំនួន០,៩៩ ក្នុងថ្នាក់បឋមសិក្សា ១,១៣នៅមធ្យមសិក្សាបឋមសិក្សា និង១,០៥ នៅមធ្យមសិក្សាទុតិយភូមិ។ទិន្នន័យគ្រួសារបានមកពីការអង្កេតផ្នែកសង្គម និងសេដ្ឋកិច្ចកម្ពុជា បានអះអាងបន្ថែមទៀតថាអត្រាមករៀននៅថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សាក៏មានភាពល្អប្រសើរឡើងផងដែរ ដោយមិនគិតពីទីតាំងទីលំនៅ យេនឌ័រ ឬធនធានឡើយ(ធានាគាពិភពលោក ២០១៣)។

គម្រោងនេះផ្សារភ្ជាប់យ៉ាងជិតស្និទជា មួយគោលបំណងនៃយុទ្ធសាស្រ្តជំនួយបច្ចេកទេសតាមប្រទេស (CAS)ដែលត្រូវបានធ្វើបច្ចុប្បន្នភាពលើកចុងក្រោយនៅខែឧសភា ឆ្នាំ២០០៨ ក៏ដូចជាការកំណត់សំគាល់យុទ្ធសាស្រ្ត បណ្តោះអាសន្ន(SIN) ដែលកំពុងធ្វើឡើង ហើយបច្ចុប្បន្នហៅថា កំណត់សម្គាល់ការចូលរួមថ្នាក់ប្រទេស(CEN)។ CASស្នើឡើងថានឹងស្ថាបនាមូលដ្ឋានដ៏រឹងមាំសម្រាប់អភិវឌ្ឍ

ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រតាមរយៈការវិនិយោគលើអភិបាលកិច្ចល្អ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើមទុនមនុស្ស និងវិស័យឯកជន(ធានាគារពិភពលោក ២០១៦)។

គោលបំណងគម្រោង និងពង្រឹងការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិតាមបទដ្ឋានអប្បបរមា នៅក្នុងតំបន់គោលដៅនិងផ្តល់ការឆ្លើយតបចំពោះមុខ និងប្រកបដោយប្រសិទ្ធភាពក្នុងករណីមានវិបត្តិ ឬមានបញ្ហាអាសន្នផ្នែកលក្ខណៈសម្បត្តិនៃការចូលរួម។ គោលបំណងនេះអាចសម្រេចបានតាមរយៈសមាសភាពសំខាន់ៗពីរ៖(i)ការកែលម្អការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិឲ្យឆ្លើយតបតាមបទដ្ឋាន តាមរយៈការផ្តល់មូលនិធិកែលម្អសាលារៀន(SIF)បង្កើនគុណវឌ្ឍិគ្រូបង្រៀនថ្នាក់មធ្យមសិក្សាបឋមភូមិដែលបច្ចុប្បន្នមិនទាន់មានសញ្ញាបត្របរិញ្ញាបត្រក្នុងមុខវិជ្ជាដែលពួកគេបង្រៀន។ បន្ថែមលើនេះទៀត គម្រោងនិងគាំទ្រការអភិវឌ្ឍរចនាសម្ព័ន្ធគ្រប់គ្រងសាលារៀនថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់ការគាំទ្របន្ថែមដល់សាលារៀនចំនួន១០០សាលារៀន ការិយាល័យអប់រំស្រុក(DOEs)នៅទីតាំងសាលារៀនទាំងនោះនិងមន្ទីរអប់រំខេត្តក្នុងខេត្តក្រុងទាំង២៥។ គាំទ្ររបស់គម្រោងនិងបង្កើនការគ្រប់គ្រងថ្នាក់សាលារៀន និងសមត្ថភាពផ្នែកហិរញ្ញវត្ថុដើម្បីសម្រេចបាននូវតម្រូវអភិវឌ្ឍតាមសាលារៀនជាក់លាក់ ក៏ដូចជាស្ថាបនាបរព័ន្ធតាមពិនិត្យដាន និងវាយតម្លៃនៅតាមការិយាល័យអប់រំថ្នាក់ក្រោមជាតិដែរ។

គម្រោងនេះនិងមានសមាសជាតុពីរ។អនុសមាសជាតុទី១.១និង១.២ នឹងប្រើប្រាស់ការផ្គត់ផ្គង់ហិរញ្ញវត្ថុផ្អែកលើលទ្ធផលដើម្បីគាំទ្រសម្រេចបានបទដ្ឋានសាលារៀនមធ្យមសិក្សារបស់ក្រសួងអប់រំ យុវជននិងកីឡា តាមរយៈរូបភាពប្រទាក់ក្រឡាគ្នាចំនួនបីគឺ៖(i)ពង្រឹងការគ្រប់គ្រងនៅថ្នាក់សាលារៀន (ii) និងបង្កើនកម្រិតគុណវឌ្ឍិគ្រូបង្រៀន។ សម្រាប់អនុសមាសជាតុនីមួយៗ និងមានសូចនាករផ្សារភ្ជាប់ការបញ្ចេញសាច់ប្រាក់(DIL) ចំនួនមួយឬពីរដោយមានចំណុចគោលដៅមានពេលវេលាកំណត់។ សមាសជាតុទាំងបីនេះនឹងបង្កើតជាកញ្ចប់មួយ(ឬកញ្ចប់ច្រើន)ដែលត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុសម្រាប់អនុម័តការរៀបចំជាពិសេស។ការផ្គត់ផ្គង់ហិរញ្ញវត្ថុវិនិយោគ នឹងត្រូវបានប្រើប្រាស់

សម្រាប់អនុសមាសធាតុ១.៣ គឺការកែលម្អបរិក្ខាសាលារៀន និងសមាសធាតុទី២៖(i)ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាននិងវាយតម្លៃ(M&E) និង(ii) កម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ(PISA) សម្រាប់ការអភិវឌ្ឍន(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)

បច្ចុប្បន្ននេះ គឺជាសម័យសាកលភាវូបនីយកម្មដែលព្រះរាណាចក្រកម្ពុជាមានភារៈកិច្ចយ៉ាងធ្ងន់ធ្ងរក្នុងការអភិវឌ្ឍនិងប្រកួតប្រជែងជាមួយសាកលលោកក៏ដូចប្រទេសនៅ ក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូលផងដែរ។ការប្រកួតប្រជែងនៅលើទីផ្សារសេរី គឺទាមទារឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដែលចាប់ផ្តើមមុនគេគឺចាប់ពីវិស័យធនធានមនុស្សឡើងទៅ។ កង្វះខាតផ្នែកធនធានមនុស្សធ្វើឲ្យប្រទេសជាតិ បាននឹងប្រឈមមុខទៅនឹងភាពអសមត្ថភាពក្នុងការប្រកួត ប្រជែង និងធ្វើសមាហរណកម្មខ្លួនចូលក្នុងសមាគមន៍អាស៊ាន និងទីផ្សារពិភពលោក ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់ វិស័យទាំងអស់ហើយក៏កំពុងបង្កើតយន្តការដ៏មមាញឹកសំដៅជំរុញលើកកំពស់ផ្នែកធនធានមនុស្សឲ្យទទួលបានទាំងបរិមាណ គុណភាព ជំនាញច្បាស់លាស់ មានក្រមសីលធម៌វិជ្ជាជីវៈ និងមានប្រសិទ្ធភាពដូចទៅនឹងបណ្តាប្រទេសអភិវឌ្ឍន៍ និងដៃគូប្រកួតប្រជែងផ្សេងៗទៀត។អាស្រ័យហេតុដូចនេះហើយទើបរាល់បណ្តាស្ថាប័នរដ្ឋ ក៏ដូចជាអង្គភាពឯកជនផ្សេងៗទៀតបានរកឃើញថាការធ្វើឲ្យមន្ត្រីរាជការ ក៏ដូចជាបុគ្គលិកមានការអភិវឌ្ឍ និងមានសមត្ថភាពកាន់តែខ្ពស់ក្នុងការប្រកួតប្រជែងនោះធ្វើឲ្យស្ថាប័នឫអង្គភាពមួយមានការអភិវឌ្ឍទទួលបាននូវភាពជោគជ័យ និងដំណើរការកាន់តែប្រសើរឡើង។ ហេតុនេះគេត្រូវយកចិត្តទុកដាក់លើបញ្ហានៃការគ្រប់គ្រង សិស្ស និស្សិត បុគ្គលិក និងការបណ្តុះបណ្តាលធនធានមនុស្សឲ្យបានល្អប្រសើរនោះអង្គភាពពិតជាទទួលបាននូវលទ្ធផលល្អប្រសើរហើយរាល់ការប្រតិបត្តិ នឹងមានប្រសិទ្ធភាពខ្ពស់និងអត្រាជោគជ័យឈានឡើងជាអតិបរិមា និងអត្រានៃការបោះបង់សិស្សមានកម្រិតទាបបំផុត(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ក្នុងអាណត្តិទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងគោលដៅលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋទូទៅទទួលបានការអប់រំគ្រប់ដោយសមភាព និងបរិយាបន្នប្រកបដោយសមធម៌។ ស្របតាមបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន(AEC)ប្រទេសកម្ពុជាបានបើកទូលាយយកលំហូរនៃកម្លាំងពលកម្មក្នុងទីផ្សារសេរីលើគ្រប់វិស័យ។ដើម្បីឆ្លើយតបនឹងនិន្នាការនេះ ប្រទេសកម្ពុជានៅមិនទាន់មានធនធាន និងកម្លាំងពលកម្មដែលមានជំនាញ(វិទ្យាសាស្ត្រ) គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការជាក់ស្តែង ព្រមទាំងការប្រកួតប្រជែងនៅលើទីផ្សារការងារ ដែលកាន់តែមានលក្ខណៈមុតស្រួចនោះឡើយ ព្រមទាំងបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធ នឹងវិស័យអប់រំ និយាយដោយឡែកនិងដោយសារបញ្ហាប្រឈមផ្សេងៗទៀត ដែលត្រូវដោះស្រាយជាបន្ទាន់ និយាយជាទូទៅ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ពាក់ព័ន្ធនឹងវិស័យអប់រំ លទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតនៅឡើយ ពិសេស ក្នុងរយៈពេលប៉ុន្មាន ឆ្នាំចុងក្រោយនេះស្របពេលដែលក្រសួងបានធ្វើកំណែទម្រង់ការប្រឡងនៅមធ្យមសិក្សាទុតិយភូមិ។ បញ្ហាប្រឈមទាំងនេះ ត្រូវបានក្រសួងអប់រំយុវជន និងកីឡា យកចិត្តទុកដាក់យ៉ាងខ្លាំងអំពីការរៀបចំកម្មវិធីសិក្សា វិធីសាស្ត្ររៀន-បង្រៀន និងនីតិវិធីនៃការប្រឡងចាប់តាំងពីកម្រិតសាលារៀន រហូតដល់ថ្នាក់ជាតិ ដើម្បីធានាបាននូវការបណ្តុះបណ្តាលធនធានមនុស្សទទួលបានការអប់រំល្អ និងមានគុណភាពឆ្លើយតបនឹងតម្រូវការទីផ្សារការងារទាំងបច្ចុប្បន្ននិងទៅទីផ្សារការងារទៅថ្ងៃអនាគតតាមបែបបច្ចេកវិជ្ជាវិទ្យាសាស្ត្រឌីជីថល (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨ )។ ពិតហើយថាអន្តរាគមន៍ជាច្រើនបានផ្តោតទៅលើគុណភាពនិងលទ្ធផលសិក្សារបស់សិស្ស ពីគ្រប់មជ្ឈដ្ឋាននៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីរួមធ្វើយ៉ាងណាឱ្យគុណភាពនិងលទ្ធផលសិក្សារបស់សិស្សគ្រប់កម្រិតមានការកើនឡើង និងមានភាគរយខ្ពស់បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។ តាមរយៈទិន្នន័យរបស់នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញពីកម្រិតភាគរយនៃលទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចាប់ពីឆ្នាំ២០១៤ មក គឺមានភាគជាប់ទាប និងកើន

ឡើងតិចតួចបើធៀបជាមួយ នឹងចំនួនបេក្ខជនដែលបានដាក់ពាក្យប្រឡងសរុបជាអាទិ៍នៅឆ្នាំ២០១៤ ជាប់៤៣.៦០% , ២០១៥ ជាប់៥៥.៨៨% , ឆ្នាំ២០១៦ ជាប់៦២.១៨% , ឆ្នាំ២០១៧ ជាប់ ៦៣.៨៤% , ឆ្នាំ២០១៨ ជាប់៦៧.០៧% និងឆ្នាំ២០១៩ជាប់ ៦៨.៦២% និងឆ្នាំ២០២០ជាប់ ១០០%ទូទាំងប្រទេស( សម័យកូវីដ-១៩ជាការចម្លងជំងឺមនុស្សតាមផ្លូវដង្ហើមជាលក្ខណៈជាសាកល) (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

គម្រោងកែលម្អការអប់រំនៅកម្ពុជា តម្រូវឱ្យសាលារៀនធ្វើកិច្ចការងារកែទម្រង់ទៅលើផ្នែកជាច្រើន ពិសេសសាលារៀនត្រូវចាប់ផ្តើមរៀបចំដំណើការ ពីការធ្វើតេស្តស្តង់ដាប្រចាំខែជាមុន។ ទន្ទឹមនឹងនេះ វិទ្យាល័យទាំងបី ដែលជាសាលាស្ថិតក្នុងខេត្តព្រះសីហនុ ហើយក៏ជាសាលាស្ថិតក្នុងសាលាគម្រោងទាំង១០០ របស់កម្មវិធីការកែលម្អគុណភាពនៅមធ្យមសិក្សាបឋមភូមិ ហៅថា (SEIP) ក៏បានខិតខំអនុវត្តធ្វើកំណែទម្រង់តាមការណែនាំរបស់ក្រសួងអប់រំ និងគម្រោង ដោយបានធ្វើតេស្តស្តង់ដាប្រចាំខែដែលជាផ្នែកមួយក្នុងការជួយបង្រឹងគុណភាពសិក្សារបស់សិស្សានុសិស្ស និងធ្វើឱ្យសិស្សមានទម្លាប់ក្នុងការអនុវត្តនីតិប្រឡងស្តង់ដា ដូចការដែលក្រសួងបានអនុវត្តចំពោះការប្រឡងថ្នាក់ជាតិនៅមធ្យមសិក្សាទុតិយភូមិ(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

## ១.២-ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយស្ថានការសព្វថ្ងៃនេះ ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាចិត្តនៅក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅគ្រប់កម្រិត ជាពិសេសនៅកម្រិតសាលារៀន និងគ្រូបង្រៀន។ ដើម្បីសម្រេចបាននូវគោលដៅអប់រំប្រកបដោយចីរភាព និងធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងរៀបចំកិច្ចសហការជាមួយធនាគារពិភពលោកដើម្បីអនុវត្ត " គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សា (SEIP)"។ គម្រោងនេះមានគោលបំណងបង្កើនគុណភាពអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិដោយ ផ្តោតលើការគ្រប់គ្រងតាមសាលារៀន School Bacs

Managerment (SBM) ដើម្បីធានាបាននូវគុណភាពសិក្សារបស់សិស្ស គុណភាពរបស់គ្រូបង្រៀន សម្ភារបង្រៀន ធនធានរូបវន្ត ធនធានមនុស្សក្នុងសាលារៀន សុខមាល ភាពរបស់សិស្ស ការចូលរួមរបស់សហគមន៍មាតាបិតានិងអ្នកពាក់ព័ន្ធទាំងឡាយក្នុងការអភិវឌ្ឍសាលារៀន( ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) ឱ្យទទួលបានលទ្ធផលល្អប្រសើរ គឺត្រូវមានការចូលរួម ចំណែកលះបង់នូវធនធាន សម្ភារ និងថវិកា របស់គ្រប់ភាគីពាក់ព័ន្ធ (សិស្ស គ្រូ មាតាបិតា សហគមន៍ សប្បុរសជន អតីតសិស្ស)។ ទាំងនេះជាកត្តាជំរុញដ៏សំខាន់ដែលមិនអាចខ្វះបានដើម្បីកែលម្អបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយបរិស្ថានមេត្រីភាពសម្រាប់បម្រើឱ្យការសិក្សារៀនសូត្ររបស់សិស្ស។ ការចូលរួមរបស់សហគមន៍បានរួមចំណែកអភិវឌ្ឍ វិទ្យាល័យឬមធ្យមសិក្សាបឋមភូមិ ក្នុងការរៀបចំឱ្យមានការប្រឡងតេស្តដោយហ្មតចត់ ស្តង់ដា ធ្វើឱ្យមានការប្រែប្រួលឥរិយាបទរបស់សិស្ស និងការបំពេញការងាររបស់បុគ្គលិកសិក្សាមាន តម្លាភាព និងគណនេយ្យភាព កាន់តែមានប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិ ហើយបង្ហាញឱ្យសហគមន៍ មាតាបិតា និងអាណាព្យាបាលសិស្ស អង្គការដៃគូជាតិអន្តរជាតិបានឃើញនិងមានភាពជឿជាក់លើគុណភាពអប់រំ របស់សាលារៀន(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

**ក.ការពង្រឹងការគ្រប់គ្រងនៅសាលារៀន** អនុសមាសធាតុនេះមានគោលបំណងគាំទ្រការអភិវឌ្ឍសមាស ធាតុរបស់មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និងសាលាមធ្យមសិក្សាបឋមភូមិគោលដៅទាំង ១០០ សាលា ដើម្បីពង្រឹងការផ្តល់សេវាក្នុងកិច្ចខិតខំដើម្បី៖ (i) ពង្រឹងថ្នាក់គ្រប់គ្រងសាលារៀនតាមរយៈការធ្វើ ផែនការអភិវឌ្ឍសាលារៀន ការពិនិត្យតាមដាន/ការវាយតម្លៃលើលទ្ធផលការងាររបស់គ្រូបង្រៀន និងសិស្ស និងការចូលរួមរបស់សហគមន៍ និង (i) គាំទ្រគ្រូបង្រៀនក្នុងការកែលម្អការបង្រៀន និងការអនុវត្តក្នុងការ គ្រប់គ្រងថ្នាក់រៀន រួមទាំងការធ្វើកិច្ចតែងការបង្រៀន សៀវភៅលំហាត់

ឯកសារធ្វើតេស្ត និងការវាយតម្លៃ ការផ្តល់យោបល់ត្រឡប់ដល់សិស្ស។ ដើម្បីសម្រេចបានគោលដៅរបស់ អនុសមាសជាតុនេះ គម្រោងនឹង ផ្តល់ហិរញ្ញវត្ថុ (១) SIFs នៅថ្នាក់មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុកនិងសាលារៀនក៏ដូចជា(២)សកម្មភាពនានាដែលកសាងសមត្ថភាពបុគ្គលិកនៅថ្នាក់នីមួយៗក្នុងចំណោមកម្រិតដែលបានរៀបរាប់ខាងលើ(ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។

**ខ.បង្កើនកម្រិតគ្រូបង្រៀន** ដោយធ្វើការតាមរយៈរចនាសម្ព័ន្ធថ្នាក់ជាតិរបស់TPAP-អនុសមាសជាតុនេះមានគោល បំណងដើម្បីបង្កើនកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀនចំនួន ២០០០ នាក់ និងនាយកសាលា ព្រមទាំងនាយក រងសាលាចំនួន ៣១០ នាក់ ឲ្យដល់កម្រិតបរិញ្ញាបត្រ។ ក្រុមដំបូងដែលនឹងត្រូវបង្កើនកម្រិតគុណវុឌ្ឍិរបស់ ខ្លួនគឺគ្រូបង្រៀន និងនាយកសាលាមកពីសាលាគោលដៅទាំង ១០០ សាលា ។ គ្រូបង្រៀនដែលនៅសល់នឹងត្រូវបានបង្កើនកម្រិតគុណវុឌ្ឍិដោយផ្អែកលើសេចក្តីត្រូវការថ្នាក់ជាតិ ដែលត្រូវបានកំណត់ដោយ TPAP ដែលជាលទ្ធផលនឹងបង្កើតឲ្យមានឥទ្ធិពលធ្វើឲ្យមានមនុស្សនៅសល់ ហូរហៀរ។ សកម្មភាពរបស់អនុសមាសជាតុដែលត្រូវបានស្នើឡើង នឹងផ្តោតការយកចិត្តទុកដាក់លើអាហា រូបករណ៍នៅផ្នែកតម្រូវការដោយគ្របដណ្តប់លើការចំណាយថ្លៃសាលារៀន និងប្រាក់ឧបត្ថម្ភ (រួមមានថ្លៃ ធ្វើដំណើរ និងថ្លៃកន្លែងស្នាក់នៅ)។

**គ. ការកែលម្អបរិក្ខារសាលារៀន** ដើម្បីបំពេញបន្ថែមលើអនុសមាសជាតុពីរខាងលើ អនុសមាសជាតុនេះ នឹងគាំទ្រការកែលម្អរូបវន្តរបស់សាលាមធ្យមសិក្សាបឋមភូមិគោលដៅទាំង១៣០ ដើម្បីពង្រីកលទ្ធភាព ទទួលបានសេវា។ អនុសមាសជាតុនេះរួមមាន៖ (i) ការសាងសង់ និងការស្តារឡើងវិញនូវសាលារៀន ដែលមានស្រាប់ចំនួន ១០០ សាលានិង (i) ការសាងសង់សាលារៀនថ្មីចំនួន ៣០ ថែមទៀតនៅក្នុងឃុំ នានាដែលកំពុងខ្វះខាតសាលាមធ្យមសិក្សាបឋមភូមិ។ សាលារៀនទាំងនេះនឹងគ្របដណ្តប់លើខេត្តទាំង ២៥ នៅក្នុងស្រុកចំនួន ៧៨។ ផែនការសាងសង់សាលារៀនដែលបានជ្រើសរើសទាំង ១៣០ នឹងរួម បញ្ចូលនូវកន្លែងស្នាក់នៅរបស់គ្រូតាមការចាំបាច់ ហើយនឹងត្រូវអនុវត្តតាមរយៈវិធីសាស្ត្រការសាងសង់មាន ការចូលរួមពីសហគមន៍។ ការជ្រើសរើសសាលារៀននឹងត្រូវផ្អែក

តាមសេចក្តីត្រូវការ ហើយត្រូវទាញចេញពី លំហាត់ធ្វើផែនទីសាលារៀនដែលបានធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។

**ឃ.ការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា**

ដើម្បីសម្រេចតាមគោលនយោបាយនេះ ក្រសួងបានធ្វើកំណែទម្រង់១៥ចំណុចក្នុងនោះរួមមាន៖ (១)កំណែទម្រង់ហិរញ្ញវត្ថុ(២) ការពង្រាយគ្រូ(៣) ការបណ្តុះបណ្តាល(៤) លើកកម្ពស់គុណវុឌ្ឍិគ្រូ(៥) ការងារអធិការកិច្ច (៦) ការវាយតម្លៃលទ្ធផលសិក្សាសិស្ស(៧) កំណែទម្រង់លើការប្រឡងមធ្យមសិក្សាទុតិយភូមិ(៨) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល(៩)ការសាងសង់អគារសិក្សានិងការជួសជុល(១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១)ការលើកកម្ពស់វិស័យកីឡា(១២) ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន(១៣) ការអប់រំបច្ចេកទេស(១៤) ការបង្កើតសាលាជំនាន់ថ្មី (១៥)ការរៀបចំគន្លងអាជីពនិងការបណ្តុះបណ្តាលនាយកសាលា(ហង់ជួន ណារ៉ុន ២០១៥)។

អាស្រ័យហេតុនេះបានជាអ្នកស្រាវជ្រាវសុំស្នើលើកប្រធានបទ « **ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិហៅថា SEIP ក្នុងខេត្តព្រះសីហនុ** »ដើម្បីធ្វើការសិក្សាស្រាវជ្រាវក្នុងក្របខណ្ឌថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំសម្រាប់ឆ្នាំសិក្សា២០១៩-២០២១នេះ។

## ១.៣-គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវ មានគោលបំណងធំៗចំនួនពីរដូចខាងក្រោម ៖

(១) សិក្សាពីកម្រិតដំណើការដឹកនាំ គ្រប់គ្រងបង្រៀន និងរៀនសម្រាប់អនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧បាន

(២)រកឱ្យឃើញពីកត្តានានាដែលជាផលជះនៃការធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧

## ១.៤-សំណួរស្រាវជ្រាវ

(១) តើដំណើការដឹកនាំគ្រប់គ្រងការបង្រៀន និងរៀនសម្រាប់អនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧ ទទួលបានកម្រិណា?

(២) តើមានកត្តាអ្វីខ្លះដែលជាផលជះនៃការធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧បាន?

## ១.៥-សារៈសំខាន់នៃការស្រាវជ្រាវ

**របាយការណ៍ស្រាវជ្រាវប្រើសម្រាប់៖**

-ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពយុទ្ធវិធី និងសកម្មភាពអន្តរាគមន៍ កែលម្អសាលារៀនចែករំលែកបទពិសោធន៍ដែលទទួលបាន ជាមួយសាលារៀនជិតខាង និងដៃគូរពាក់ព័ន្ធ

-ការជំរុញលើកទឹកចិត្តដល់បុគ្គលិកទាំងអស់ក្នុងអង្គភាពកាន់តែមានការទទួលខុសត្រូវនិងមានប្រសិទ្ធិភាពកាន់ខ្ពស់

-ជាភ័ស្តុតាងក្នុងការវាយតម្លៃផលជះដែលបានមកពីការអនុវត្តតេស្តស្តង់ដាកម្រិតសាលារៀន

-កសាងឯកសារទុកសម្រាប់សាលាមធ្យមសិក្សានិងសម្រាប់អ្នកពាក់ព័ន្ធសិក្សាស្រាវជ្រាវបន្ត ។

-ធ្វើឲ្យមានការកែប្រែឥរិយាបទអ្នកអប់រំ ការិយាល័យ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈនាយក គ្រូ សិស្ស មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស។

-ធ្វើឲ្យ អាជ្ញាធរដែនដី សហគមន៍ មាតាបិតា សប្បុរសជន អង្គការដៃគូរចូលរួមលើដំណើការសាលារៀន

## ១.៦-ដែនកំណត់នៃវិសាលភាពនៃការស្រាវជ្រាវ

ខេត្តព្រះសីហនុស្ថិតនៅភាគនារតី នៃព្រះរាជាណាចក្រកម្ពុជាដែលមានចំងាយផ្លូវ២៣៦គីឡូម៉ែត្រត្រពីរាជធានីភ្នំពេញ ហើយមានព្រំប្រទល់ខាងកើតទល់ខេត្តកំពត ខាងលិចទល់និងខេត្តកោះកុង ខាងត្បូងទល់និងឈូងសមុទ្រ ថៃ ខាងជើងទល់និងខេត្តកំពុងស្ពឺ។

ខេត្តព្រះសីហនុមានស្រុកចំនួន៣ និងក្រុងចំនួន២គឺក្រុងព្រះសីហនុ និងក្រុងកោះរ៉ុង ស្រុកព្រៃនប់ស្រុកកំពុងសិលា ស្រុកស្ទឹងហាវ ដោយក្នុងនោះ ឃុំមានចំនួន២៣ឃុំមានសង្កាត់ចំនួន០៦ និងភូមិមានចំនួន៩៤ភូមិ មានប្រជាជនសរុបចំនួន១,៩៩៩.៩០២នាក់ (ក្រសួងផែនការ ២០០៨)។

## ១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវ មុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក និងប្រភេទសំណាកព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម ។

**ជំពូកទី៤៖** លទ្ធផលការស្រាវជ្រាវ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឲ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន ការពិភាក្សា និងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែក ធ្វើឲ្យស្ថានភាពបង្រៀន និងរៀនប្រសើរឡើងថែមមួយកម្រិតទៀត។

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ អ្នកសិក្សាផ្តោតទៅលើ និយមន័យពាក្យគន្លឹះដែលទាក់ទងទៅ វិធីសាស្ត្រក្នុងការធ្វើតេស្ត សិស្សកម្ពុជានៅកម្រិតមធ្យមសិក្សាបឋមភូមិ វាស់ស្ទង់សមត្ថភាពចំណេះដឹងរបស់សិស្សសារៈសំខាន់នៃការបំពេញតេស្តស្តង់ដា។ ពាក្យគន្លឹះសំខាន់ៗដែលអ្នកសិក្សានឹងយកមកពន្យល់បកស្រាយនោះរួមមានៈផលជះនិងការធ្វើតេស្តស្តង់ដាលើសិស្សថ្នាក់ទី៦ឡើងទី៧ថ្មី។

## ២.១. និយមន័យ

នៅក្នុងការសរសេរនិក្ខេបនេះ យើងបានកំណត់នូវពាក្យគន្លឹះមួយចំនួនជាមុនសិនគឺះ

តេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា គឺជាតេស្តមួយប្រភេទដែលគេធ្វើឡើងដើម្បីវាស់ស្ទង់ចំណេះដឹងមូលដ្ឋានគណិតវិទ្យា ដែលសិស្សចាំបាច់ត្រូវចេះ ទើបអាចរៀនបន្តទៅកម្រិតថ្នាក់បន្តបន្ទាប់ទៀតបាន។ តេស្តនេះផ្តោតលើប្រមាណវិធីទាំង៤ នៃគណិតវិទ្យាមាន ប្រមាណវិធីបូក ប្រមាណវិធីដកប្រមាណវិធីគុណ និង ប្រមាណវិធីចែក( នាយកដ្ឋានចំណេះទូទៅ ២០២១)។

លទ្ធផលនៃការអនុវត្តតេស្តស្តង់ដាប្រចាំខែ គឺជាលទ្ធផលសិក្សាដែលទទួលបានពីការប្រឡងរបស់សិស្សដើម្បីវាស់ស្ទង់សមត្ថភាពសិក្សារបស់សិស្សានុសិស្សតាមខែនីមួយៗ (ធានាគារពិភពលោក គម្រោង ២០១៩)។

ផលជះនៃការអនុវត្តតេស្តស្តង់ដាប្រចាំខែ មានន័យថា ជាសមិទ្ធិផលទាំងឡាយដែលបាន ឬកើតអំពីការអនុវត្តតេស្តស្តង់ដារបស់សិស្ស។ ទន្ទឹមក្នុងការបកស្រាយយើងសូមលើកប្រវត្តិនៃ ការសិក្សាអប់រំពីសម័យបុរាណមកជាមួយផងដែរ ដូចដែលបានសិក្សាកន្លងក៏ដូចជាការសិក្សានៅសាកលលោកនិងការអប់រំនៅក្នុងប្រទេសកម្ពុជាយើងទាំងមូលផងដែរ (នាយកដ្ឋានចំណេះទូទៅ ២០២១)។

ការងារគ្រប់គ្រង សំដៅទៅដល់ការធ្វើផែនការណ៍ ការរៀបចំចាត់ចែងការដឹកនាំ និងការត្រួតពិនិត្យធនធានដទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័នប្រកបដោយប្រសិទ្ធិភាព។ ឬអាចនិយាយម្យ៉ាងទៀតថាគឺជាធ្វើឲ្យសម្រេចគោលដៅប្រកបដោយប្រសិទ្ធភាព ដោយកិច្ចសហការគ្នាតាមរយៈ ការធ្វើផែនការណ៍ ការរៀបចំាចាត់តែងអនុវត្ត ការដឹកនាំ និងការត្រួតពិនិត្យធនធានរបស់អង្គភាព។

អ្នកគ្រប់គ្រង សំដៅដល់អ្នកទទួលខុសត្រូវអភិបាលកិច្ច ក្នុងការប្រើប្រាស់ធនធាន របស់អង្គភាពឲ្យសម្រេចគោលដៅ។អ្នកគ្រប់គ្រងត្រូវបើកមាត់ ត្រចៀក ត្រូវស្ដាប់ហើយគិត បើនិយាយស្ដីត្រូវនិយាយឲ្យបានល្អ ពិរោះ ឲ្យបុគ្គលិកយល់ និយាយរឿងលំបាកឲ្យទៅជារឿងងាយស្រួលវិញ។ ឬអាចនិយាយដោយខ្លីអ្នកគ្រប់គ្រងល្អគឺជាមនុស្សដែលចេះលៃលក កែលម្អឬផ្លាស់ប្ដូរដោយរកនៅវិធីសាស្រ្តថ្មីៗ និងមានប្រសិទ្ធិភាព( នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រិតការ ២០១៦ )

ការអប់រំជាកត្តាចាំបាច់មិនអាចខ្វះបានឡើយ ហើយការអប់រំត្រូវតែមានសម្រាប់ប្រទេសនីមួយៗនៅលើសាកលលោក ក៏ដូចជាប្រទេសកម្ពុជាជាពិសេសត្រូវមានកាបណ្ដុះការអប់រំកុមារតាំងពីកំណើតរហូតពេញវ័យនិងមានការរៀនពេញមួយជីវិត ដូចនេះរដ្ឋាភិបាលត្រូវបង្កើតឲ្យមានសាលារៀនជាកត្តាចាំបាច់មិនអាចខ្វះបានឡើយ ហើយការសិក្សារៀនសូត្រគណៈនាយកដឹកនាំសាលាចាំបាច់ត្រូវតែការធ្វើការប្រឡងតេស្តជាចាំបាច់ក្នុងការវាស់ស្ទង់សមត្ថភាពសិស្ស ដើម្បីមានភាពងាយស្រួលក្នុងដឹកនាំនិងគ្រប់គ្រងលើការបង្រៀន និងរៀនជួយសិស្ស។

## ២.១គោលបំណងនៃការធ្វើតេស្ត

ជាទូទៅ យើងសង្កេតឃើញថាគោលបំណងនៃការវង្វាតតេស្ត ប្រែប្រួលទៅតាមប្រភេទរបស់វា។ ដូចនេះក្នុងដំណើការសិក្សា តេស្តត្រូវបានរៀបចំធ្វើឡើងដើម្បីបម្រើគោលបំណង ឬមុខងារច្រើនយ៉ាង។ លោកWiersma និងJurs( 1990 )បានសរុបគោលបំណងទូទៅនៃទង្វើតេស្តដូចខាងក្រោមៈ

1-ដើម្បីពណ៌នាស្ថានភាពបច្ចុប្បន្នរបស់សិស្សតាមភាពប្លែកៗនៃអក្សថេរ ព្រោះចរិតលក្ខណៈរបស់មនុស្សអាចប្រែប្រួល។

2-ដើម្បីប្រមើមើលសមត្ថភាពអនាគតរបស់សិស្ស។

3-ដើម្បីវាស់សមត្ថភាពខុសគ្នារវាងសិស្ស និងសិស្ស

4-ដើម្បីរាយការណ៍ពីការរីកចម្រើននៃការសិក្សា និងធ្វើការពាក់ព័ន្ធនឹងវត្ថុបំណងការសិក្សា។

5-ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយរបស់សិស្ស។

6-ដើម្បីរកឲ្យឃើញផល ដែលសិស្សសម្រេចបាននៅក្នុងសាលារៀន ឬភាពខុសគ្នារវាងពិន្ទុបុរតេស្ត( Pre test និង បច្ឆាតេស្ត Post test ) (នាយកដ្ឋានចំណេះទូទៅ ២០២១)។

## ២.២-ទង្វើតេស្តក្នុងដំណើរការសិក្សា

ទង្វើតេស្ត ជាពិសេសតេស្តសមិទ្ធកម្មមានតួនាទីដ៏សំខាន់នៅក្នុងដំណើការសិក្សា។ តាំងពីដើមរហូតដល់ចុងបញ្ចប់នៃការសិក្សា មានការសម្រេចចិត្តច្រើនយ៉ាងដែលគ្រូត្រូវធ្វើ ដើម្បីកែលម្អប្រសិទ្ធភាពនៃការសិក្សា។ តាមលោកGronlund( 1991 ) ការសម្រេចចិត្តសំខាន់ៗ ធ្វើឡើងជា៣ដំណាក់កាលគឺ ការសម្រេចចិត្តនៅដើមការសិក្សា ការសម្រេចចិត្តពេលកំពុងការសិក្សា និងការសម្រេចចិត្តនៅបញ្ចប់ការសិក្សា។ ការសម្រេចចិត្តទាំង៣ដំណាក់នេះទាក់ទង នឹងទង្វើតេស្ត៣ប្រភេទ( នាយកដ្ឋានចំណេះទូទៅ ២០២១)។

**ក.នៅដើមការសិក្សា** គេធ្វើបុរតេស្តស្ទាបស្ទង់កម្រិត( Placement test)។

១.បុរេតេស្តស្ទាបស្ទង់សមត្ថភាពចាំបាច់ដំបូង(Preequisites)ដែលសិស្សមាន មុនពេលចូលរៀន ហៅថាបុរេតេស្តត្រៀម(Readiness test).ឧទាហរណ៍ មុនរៀនពិជគណិត គ្រូឲ្យសិស្សធ្វើបុរេតេស្តត្រៀមខាងប្រមាណវិធី ដើម្បីកំណត់សមត្ថភាពចាំដំបូងដែលគេមាន ។ សិស្សដែលមានសមត្ថភាពទាប អាចត្រូវរៀនបំប៉នឬត្រូវចាត់ចូលក្រុមដោយឡែក។

២.បុរេតេស្តស្ទាបស្ទង់កម្រិតសមិទ្ធផលដែលសិស្សសម្រេចបាន ដើម្បីធ្វើជាមូលដ្ឋានសម្រាប់បន្តភ្ជាប់ការសិក្សាក្នុងគម្រោងកម្មវិធីសិក្សា ហៅថាបុរេតេស្តស្ទាបស្ទង់កម្រិត(Plasement test )។ តេស្តនេះច្រើនគេនិយមយកទៅប្រើម្តងទៀតនៅចុងបញ្ចប់ការសិក្សា(Post test)ដោយគ្រាន់តែកែសម្រួលទម្រង់ខ្លះប៉ុណ្ណោះប្រសិនជាចាំបាច់។ ដោយផ្អែកលើលទ្ធផលតេស្តនេះ គេអាចដំណើការបង្រៀន និងរៀនបានសមស្រប។

ជួនកាលទង្វើតេស្តស្ទាបស្ទង់កម្រិតមិនជាការចាំបាច់ទេ ប្រសិនបើគ្រូដែលបានបងរៀនសិស្សផ្ទាល់ពីមុនមក អាចស្គាល់សតម្ថភាពសិស្សច្បាស់(នាយកដ្ឋានចំណេះទូទៅ ២០១៨)។

**ខ.ពេលកំពុងសិក្សា** គេធ្វើតេស្តតាមដំណាក់វិស័យ និងតេស្តវិនិច្ឆ័យ។

**១.តេស្តតាមដំណាក់កាល** ( formative test )ធ្វើឡើងតាមផ្នែកឬជំពូកនីមួយៗនៃកម្មវិធីសិក្សា ដើម្បីពិនិត្យតាមដានការសិក្សារបស់សិស្សក្នុងបំណងជួយកែលម្អ។ការងារនេះតម្រូវឲ្យគ្រូស្គាល់ច្បាស់អំពីការទទួលបានជោគជ័យឬការ មិនទទួលបានជោគជ័យរបស់សិស្សក្នុងការសិក្សា។ កាលណាសិស្សភាគច្រើនឆ្លើយខុសក្នុងតេស្តមួយច្រើន ខ្លឹមសាមេរៀនពាក់ព័ន្ធនិងកុំហុសនេះត្រូវលើកយកមកបង្រៀនឡើងវិញ។ កាលណាសិស្សភាគតិចឆ្លើយខុស គ្រូត្រូវស្គាល់មូលហេតុនៃកំហុសនោះរួចរិះរកមធ្យោបាយកែសម្រួល(នាយកដ្ឋានចំណេះទូទៅ ២០១៨)។

**២.តេស្តវិនិច្ឆ័យ**(diagnostic test)រៀបចំធ្វើឡើងដើម្បីស្រាវជ្រាវស៊ីជម្រៅលើភាពខ្លាំង និងភាពខ្សោយរបស់សិស្សក្នុងការសិក្សា ជាពិសេសរកមូលហេតុនៃកង្វះខាតឬពិបាកដែលតេស្ត

តាមដមណាក់ មិនអាចដោះស្រាយបាន។ឧទាហរណ៍ដើម្បីវាស់សូរអាន(Prunanciation)ខាងភាសាអង់គ្លេសគេធ្វើតេស្តវិច្ឆ័យ ដើម្បីញែកសូរឲ្យច្បាស់ បើមានកំហុសជួយកែលម្អ(នាយកដ្ឋានចំណេះទូទៅ ២០១៨)។

**គ.នៅបញ្ចប់ការសិក្សា** គេធ្វើតេស្តសរុប(summative test )ដើម្បីបញ្ជាក់កម្រិតជំនាញឬចាត់ថ្នាក់សិស្សទៅតាមសតម្កភាពរបស់គេ។ តេស្តនេះមានលក្ខណៈសរុប អាចវាស់ភាគសំណាកតំណាងវត្ថុបំណងសិក្សាទាំងអស់ក្នុងកម្មវិធីសិក្សា។ គេអាចប្រើលទ្ធផលនេះ ធ្វើជាទិន្នន័យសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃការសិក្សាផងដែរ(នាយកដ្ឋានចំណេះទូទៅ ២០២១)។

ការអប់រំ គឺជាប្រព័ន្ធស្មុគស្មាញដែលបង្កប់ក្នុងបរិបទសេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ ទិដ្ឋភាពសេដ្ឋកិច្ច វប្បធម៌ និងនយោបាយនៃការអប់រំគឺមានអន្តរទំនាក់ទំនងគ្នានិងមានឥទ្ធិពលទៅគ្នាទៅវិញទៅមក។ ដូចនេះការអប់រំគឺមានលក្ខណៈជាប្រព័ន្ធធម្មជាតិ។ ការសិក្សាកន្លងមកមួយចំនួនបង្ហាញថាគន្លឹះឈានទៅរកកំណែទម្រង់ជោគជ័យ គឺចាប់ផ្តើមពីការកំណែទម្រង់ជាប្រព័ន្ធ ដែលត្រូវដោះស្រាយបញ្ហានៅតាមអង្គភាពដ៏ស្មុគស្មាញ ដោះស្រាយសមាសភាគ និងបញ្ហាជំពាក់គ្នាជាច្រើនក្នុងពេលដំណាលគ្នា(Anson, 1994 Fullan, 2007)។ ការសិក្សានាពេលថ្មីនេះក៏បានបង្ហាញថា ការកើនឡើងនៃការវិនិយោគលើធាតុចូលការអប់រំ មិនបានធ្វើឲ្យវិស័យអប់រំ មានភាពប្រសើរឡើងនោះទេ ដោយសារកំណែទម្រង់ការអប់រំផ្អែកលើការគ្រប់គ្រងជាប្រព័ន្ធPritchett (២០១៥)។ ប្រសិនបើប្រព័ន្ធអប់រំខ្សោយ ការបន្ថែមធនធាន និងមិនអាចនាំមកនូវភាពពង្រឹងគុណភាពអប់រំនោះទេ (ហង់ជួន ណារ៉ុន ២០២០)

សាលារៀនជាប្រព័ន្ធបើកចំហមួយដែលពាក់ព័ន្ធនឹងការដាក់ធាតុចូល ដំណើរការ និងបំលែងទៅជាលទ្ធផល។ ធនធានមនុស្ស វត្ថុធាតុដើម ព័ត៌មាន និងថវិកាគឺជាធាតុចូលទូទៅសម្រាប់សាលារៀន។ ក្នុងដំណើរការនៃការផ្លាស់ប្តូរធាតុចូលទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅជាតម្លៃដែលហៅថាលទ្ធផលនឹង

ផ្តល់ផលវិញទៅក្នុងសង្គម។ លទ្ធផល គឺផលិតផលនិងសេវាដែលរាប់បញ្ចូលទាំងការពេញចិត្តរបស់និយោជកនិងអ្នកពាក់ព័ន្ធផ្សេងទៀត។ ថ្នាក់រៀន សៀវភៅ កុំព្យូទ័រ សម្ភារៈសិក្សា គ្រូបង្រៀន និងសិស្សក៏ជាធាតុចូលសំខាន់សម្រាប់សាលារៀនផងដែរ(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

លក្ខណៈវិនិច្ឆ័យនៃការផ្លាស់ប្តូរសំដៅទៅលើបរិមាណ គុណភាពនិងការស៊ីសង្វាក់គ្នានៃដំណើរការផ្ទៃកខាងក្នុងនិងរចនាសម្ព័ន្ធ ដែលបានផ្លាស់ប្តូរធាតុចូលទៅជាលទ្ធផល។ ឧទាហរណ៍ នៃលក្ខណៈវិនិច្ឆ័យការផ្លាស់ប្តូរគឺរចនាសម្ព័ន្ធ និងមាតិការបស់កម្មវិធីសិក្សាបរិយាកាសអន្តរបុគ្គលកម្រិតនៃការលើកទឹកចិត្តរបស់សិស្សនិងគ្រូបង្រៀនភាពដឹកនាំ របស់អ្នករដ្ឋបាលនិងគ្រូបង្រៀនគុណភាពនិងបរិមាណនៃការបង្រៀន និងនីតិវិធីនៃការត្រួតពិនិត្យគុណភាពដូចជាចំនួនតេស្ត ការវាយតម្លៃការបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា និងការវាយតម្លៃបុគ្គល។ អតិបរមានៃប្រសិទ្ធភាពរបស់សាលារៀនធាតុខាងក្នុងនៃការបង្រៀន និងរៀនការរំពឹងទុកនៃការិយាធិបតេយ្យវប្បធម៌ការរំពឹងទុកផ្នែកនយោបាយតម្រូវការបុគ្គលត្រូវតែធ្វើការដោយស៊ីចង្វាក់គ្នាដើម្បីសម្រេចបានតាមគោលដៅចង់បាន។

លទ្ធផលបង្កើតបានជាគុណភាពនៃសេវារបស់សាលារៀននិងផលិតផលសម្រាប់សិស្សអ្នកអប់រំនិងអ្នកពាក់ព័ន្ធផ្សេងទៀត។ តាមរយៈទស្សនវិស័យប្រព័ន្ធសង្គមលទ្ធផលសំខាន់រួមមាន (i)សម្រាប់សិស្ស៖ ភាពជោគជ័យក្នុងការសិក្សា ការបង្កើតថ្មី ភាពជឿជាក់ការជំរុញទឹកចិត្ត ក្តីរំពឹងទុកវត្តមានការបញ្ចប់ការសិក្សា និងអត្រាត្រួតថ្នាក់ (ii) សម្រាប់អ្នកស្រាវជ្រាវ៖ ភាពពេញចិត្តការងារអវត្តមាន និងផលត្រឡប់វិញ (iii) សម្រាប់អ្នករដ្ឋបាល៖ ក្តីពេញចិត្តលើការងារ ថវិកា និងការប្តេជ្ញាចិត្តចំពោះសាលារៀន។

ភាពស្មុគស្មាញ នៃប្រព័ន្ធគ្រប់គ្រងអប់រំពហុកម្រិត បានឈានទៅដល់ការរីកសាយនៃគំរូគ្រប់គ្រងអប់រំខុសៗគ្នា។

## ២.៣-កំណែទម្រង់ជាប្រព័ន្ធ និងការគ្រប់គ្រងតាមសាលារៀន

កំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធមាននិយមន័យជាច្រើនដោយសំដៅលើការសម្រេចចិត្តនៅតាមសាលារៀន ឬការគ្រប់គ្រងតាមសាលារៀន(School-Based Management (SBM))។ SBM គឺជាវិមជ្ឈការអំណាចពីរដ្ឋាភិបាលទៅកាន់កម្រិតសាលារៀន។ ការទទួលខុសត្រូវនិងការសម្រេចចិត្តលើដំណើរការសាលារៀន ត្រូវបានផ្ទេរទៅកាន់ភ្នាក់ងារកម្រិតស្រុក។ ភ្នាក់ងារទាំងនេះ ជាការរួមបញ្ចូលគ្នានៃនាយកសាលា គ្រូបង្រៀន ឪពុកម្តាយ សិស្ស និងសមាជិកសហគមន៍ផ្សេងទៀត។ SBM មានគោលបំណងកែលម្អគណនេយ្យភាពដោយៈ (i) ផ្តល់ស្វ័យភាពដល់សាលារៀនក្នុងធ្វើសេចក្តីសម្រេចចិត្ត ក្នុងគោលបំណងកែលម្អភាពច្បាស់លាស់រវាងអ្នកត្រួតពិនិត្យ ការផ្តល់សេវា និងអ្នកផ្តល់សេវា(ii) លើកទឹកចិត្តឪពុកម្តាយឲ្យចូលរួមក្នុងដំណើរការសម្រេចចិត្តក្នុងគោលបំណងបង្កើនសំឡេងក្នុងការផ្តល់សេវា(Bruns ot al. 2011)។

(Bruns ot al. 2011) បានផ្តល់ការវិភាគក្នុងការផ្តល់សេវាអប់រំគ្រប់ជ្រុងជ្រោយ អំពីទិដ្ឋភាពនៃបញ្ហាគោលការណ៍របស់ភ្នាក់ងារផ្តល់ការអប់រំ។ ក្រសួងអប់រំគឺជាភ្នាក់ងាររបស់ប្រជាជន នៅពេលដែលឪពុកម្តាយនិងសិស្សអាចត្រូវគេចាត់ទុកជានាយកសាលា។ អ្នកប្រើប្រាស់សេវាអប់រំទទួលខុសត្រូវចំពោះប្រទេសជាតិ។ ក្នុពេលជាមួយគ្នា រដ្ឋក៏ដើរតួនាទីជាអ្នកផ្តល់សេវា(សាលារៀននិងគ្រូបង្រៀន) ទទួលខុសត្រូវចំពោះការអនុវត្ត។ របាយការណ៍អភិវឌ្ឍពិភពលោក ២០០៤ បានពីពណ៌នានូវក្របខណ្ឌមួយអំពីទំនាក់ទំនងស្នូលចំនួន៣គឺរវាងប្រជាជននិង អ្នកនយោបាយ និងអ្នកផ្តល់សេវា។ ទំនាក់ទំនងការផ្តល់សេវា និងការទទួលខុសត្រូវក្នុងចំណោមតួអង្គទាំងនេះមានភាពស្មុគស្មាញ។ តួអង្គជាច្រើនទាក់ទងគ្នា។ ទំនាក់ទំនងនៃការលើកទឹកចិត្តនិងការទទួលខុសត្រូវ របស់ក្រុមមួយអាចនឹងខុសគ្នាពីក្រុមដទៃ(World Bank, 2003)។ ដូចនេះ SBM អាចត្រូវបានគេគិតថា ជាទម្រង់នៃកំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធពីក្រោមទៅលើ(នាយកដ្ឋានចំណេះទូទៅ ២០២១)។

និន្នាការក្នុងប្រទេសជាច្រើន បានធ្វើការបង្កើនស្វ័យភាព ទទួលខុសត្រូវបែបវិមជ្ឈការ និងជម្រុញការលើទឹកចិត្តដល់តម្រូវការក្នុងតំបន់ ដើម្បីធ្វើការកែលម្អការអនុវត្ត(Bruns ot al. 2011)។ ទោះបីជាយ៉ាងណា ពីពេលមួយទៅមួយ ទីផ្សារសម្រាប់ការអប់រំរងគ្រោះពីបរាជ័យទីផ្សារ។ នេះតម្រូវឲ្យរដ្ឋាភិបាលអន្តរាគមន៍ និងកែតម្រូវបញ្ហា។ ក្នុងគោលបំណងធ្វើឲ្យប្រសើរសេវាអប់រំ ប្រទេសជាច្រើនបានអនុម័តនូវយុទ្ធសាស្ត្រកំណែទម្រង់គណនេយ្យភាពទាំង ៣(Bruns ot al. 2011)៖

ព័ត៌មានគណនេយ្យភាព៖ សំដៅទៅលើការបង្កើត និងការផ្សព្វផ្សាយព័ត៌មាន ស្តីពីសិទ្ធរបស់សាលារៀននិងការទទួលខុសត្រូវជាតុចូល លទ្ធផលរយៈពេលខ្លី និងលទ្ធផលរយៈពេលវែងការគ្រប់គ្រងតាមសាលារៀន៖ សំដៅលើវិមជ្ឈការការសម្រេចចិត្តនៅកម្រិតសាលារៀន និងស្វ័យភាពរបស់សាលារៀន

ការលើទឹកចិត្តគ្រូបង្រៀន៖ សំដៅលើគោលនយោបាយដែលផ្សារភ្ជាប់នឹងប្រាក់រង្វាន់ ឬមុខតំណែងស្របទៅនឹងការអនុវត្ត( ហង់ជួន ណារ៉ុន ២០២០)។

## ២.៣.១ គំនិតផ្តួចផ្តើមសកល និងទិដ្ឋភាពនៃកំណែទម្រង់ការអប់រំមានសារៈសំខាន់

នាពេលបច្ចុប្បន្ន គំនិតផ្តួចផ្តើមសកលស្តីពីការអប់រំបានឆ្លុះបញ្ចាំងពីតម្រូវការរបស់ប្រទេសជាច្រើនក្នុងការចាប់ផ្តើមធ្វើកំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធ ក្នុងគោលបំណងសម្រេចឲ្យបានគោលដៅ។

**ក. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងការអប់រំឆ្នាំ ២០៣០ ៖** របៀបវារៈការអប់រំសកល(ការអប់រំ ២០៣០) គឺជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ របស់អង្គការសហប្រជាជាតិដែលជារបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ គឺធានាសមធម៌ក្នុងការទទួលបានការអប់រំ

ប្រកបដោយគុណភាពបរិយាបន្ន និងបង្កើតឱកាសទទួលបានការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការអប់រំគឺជាផ្នែកមួយដ៏សំខាន់នៃគោលដៅផ្សេងទៀតទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈនៃសេវាមូលដ្ឋាន និងក្របខណ្ឌច្បាប់/នយោបាយ ដែលជានានូវឱកាសអប់រំនិងសមាហរណកម្មគោលបំណងខុសៗគ្នា(ឧទា.ប្រជាពលរដ្ឋសកល ការឆ្លើយតបនឹងវិបត្តិ បរិយាកាសចំណេះដឹង)ទៅក្នុងគោលនយោបាយ និងកម្មវិធីសិក្សាអប់រំជាតិ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ គ្របដណ្តប់លើការសិក្សាពីកុមារតូចរហូតដល់ពេញវ័យដោយផ្តោតសំខាន់លើគុណភាពអប់រំ ការសិក្សា បរិយាបន្ន និងសមភាព។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤ ផ្តោតលើទិសដៅសកល និងគោលដៅសម្រាប់ប្រទេសនៅគ្រប់កម្រិតនៃការអភិវឌ្ឍ។ របៀបវារៈការអប់រំឆ្នាំ ២០៣០ បង្ហាញពីការចូលរួមរបស់អ្នកពាក់ព័ន្ធវិស័យអប់រំទាំងផ្នែកជាតិ និងអន្តរជាតិជាមួយនឹងបញ្ហាប្រឈម២ គឺលទ្ធផលនៃការសិក្សានិងសមភាពនៃគុណភាពអប់រំ (UNESCO, ២០១៥)។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ក្របខណ្ឌការអប់រំឆ្នាំ ២០៣០ រួមមាន៖

១. ការប្តេជ្ញាចិត្ត៖ (១)ចំពោះសកលកម្មអក្ខរកម្ម យ៉ាងហោចណាស់យុវជនទទួលបានការអប់រំ ១ឆ្នាំនៃថ្នាក់មត្តេយ្យសិក្សា ១២ឆ្នាំនៃការអប់រំបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ដោយឥតបង់ថ្លៃ(យ៉ាងហាហោចណាស់បញ្ចប់ការសិក្សារយៈពេល ៩ឆ្នាំ) និង (២)ជានាឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំនៅកម្រិតក្រោយការអប់រំមូលដ្ឋាន និងតម្រូវការការបណ្តុះបណ្តាលដែលត្រូវកែតម្រូវ/ពង្រឹងនិតិបញ្ញតិរបស់ជាតិ។

២. គោលដៅអភិវឌ្ឍ ប្រកបដោយចីរភាពផ្តោត លើការអប់រំពេញមួយជីវិត ចាប់ពីកុមារតូចរហូតដល់ពេញវ័យ។ គោលដៅទាំងនេះផ្តោតលើវិធានការពង្រឹងការអាន និងគណិតវិទ្យា ដើម្បីឆ្លុះបញ្ចាំងពីការពិនិត្យរួមគ្នា និងគ្រប់ជ្រុងជ្រោយអំពីជំនាញដែលត្រូវការសម្រាប់សង្គម និងបរិស្ថាន។

៣.កត្តាសមត្ថភាពត្រូវបានបញ្ជាក់យ៉ាងច្បាស់ ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤ ដោយបានចាត់វិធានការជាច្រើនផ្តោតលើគុណភាពអប់រំ។ ដូចនេះជាចាំបាច់ត្រូវជំរុញការអនុវត្តគោលនយោបាយលើកកម្ពស់គុណភាពអប់រំនិងបង្កើនការសិក្សាជាបន្តន្ទាប់។

៤. ការពង្រីកការទទួលបាន ការអប់រំគ្រប់កម្រិត និងការសិក្សាពេញមួយជីវិត ផ្អែកលើគោលការណ៍នៅផ្ទះអប់រំស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន និងផលិតផលសាធារណៈ។

៥. ការកែតម្រូវនានាដោយផ្តោតលើសមភាពយេនឌ័រ និងបរិយាបន្ន។

៦. ការយកចិត្តទុកដាក់ជាថ្មីលើប្រសិទ្ធភាពនៃការសិក្សា ដោយផ្តោតលើ កម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូបង្រៀន រួមមានមាតិកាបង្រៀន និងការបង្រៀន គរុកោសល្យ សម្ភារៈ និងការបង្រៀនក្នុងថ្នាក់ក្របខណ្ឌវាយតម្លៃ ព្រមទាំងការបណ្តុះបណ្តាលគ្រូបង្រៀននិងការអភិវឌ្ឍវិជ្ជាជីវៈ។ មធ្យោបាយសន្តនិយមនិងស៊ីចង្វាក់គ្នា គឺតម្រូវឲ្យមានភាពស្របគ្នារវាងកម្មវិធីសិក្សា ការវាយតម្លៃការបណ្តុះបណ្តាលគ្រូបង្រៀនព្រមទាំងភាពដឹកនាំ និងការគ្រប់គ្រងសាលារៀន។

៧. ការផ្តោតលើការសិក្សាអំពីកិច្ចការអន្តរជាតិ និងភាពជាពលរដ្ឋសកល។ កត្តានេះមានន័យថា(i)ការវាយតម្លៃលទ្ធផលសិក្សា ដោយសារការសិក្សាមានប្រសិទ្ធភាពនិងពាក់ព័ន្ធគ្នាតម្រូវឱ្យស្មើភាពនិងយន្តការមានតុល្យការ និងវាយតម្លៃចំណេះដឹង ជំនាញនិងការប្រកួតប្រជែងគ្រប់ទិដ្ឋភាពរបស់អ្នកប្រើប្រាស់សមត្ថភាព និងភាពបត់បែនក្នុងការអនុវត្តការវាយតម្លៃ និង(ii)ការធានាគុណភាពនិងក្របខណ្ឌគុណសម្បត្តិ។

## ២.៣.២ នាយកសាលាល្អ

ភាពជាអ្នកដឹកនាំ គឺជាដំណើរការការមានឥទ្ធិពលផ្នែកសង្គម ដែលបុគ្គលម្នាក់អាចទាក់ទាញអ្នកផ្សេងទៀតឲ្យជួយ នឹងគាំទ្រខ្លួនក្នុងការបំពេញភារកិច្ចរួម(Martin M. Chemers.1997)។មានការពិភាក្សាពីភាពខុសគ្នារវាងអ្នកដឹកនាំ(Leader) និងអ្នកគ្រប់គ្រង(Administrator)។បុគ្គលខ្លះជាអ្នកដឹកនាំ ដោយមិនចាំបាច់ជាអ្នកគ្រប់គ្រង (ដោយមិនចាំបាច់កាន់តំណែងផ្លូវការ ពោលជាអ្នកដឹកនាំក្រៅ

ផ្លូវការ)ហើយបុគ្គលខ្លះទៀតជាអ្នករដ្ឋបាលតែបុណ្ណោះនោះ ដោយមិនមែនជាអ្នកដឹកនាំឡើយ (Yukl,1994)។

អ្នកគ្រប់គ្រងគឺជាអ្នកធានានូវស្ថិរភាព និងប្រសិទ្ធភាព ៖ រៀបចំផែនការ និងថវិកា ចាត់ចែង និងគ្រប់គ្រងបុគ្គលិក ត្រួតពិនិត្យនិងដោះស្រាយបញ្ហា។

អ្នកដឹកនាំផ្តោតទៅលើការផ្លាស់ប្តូរ និងដឹកនាំអ្នកក្រោមបង្គាប់ឲ្យបំពេញការងារ ៖ បង្ហាញផ្លូវដែលត្រូវដើរ កៀគរមនុស្ស លើកទឹកចិត្តនិងជំរុញចិត្ត(Kotter,1990)។

ការសិក្សាពីអ្នកដឹកនាំសាលារៀនមានការវិវត្តន៍ជាប្រចាំ។ Ralph M. Stogdill (1948) បានចាត់ថ្នាក់កត្តាបុគ្គលដែលពាក់ព័ន្ធ នឹងភាពជាអ្នកដឹកនាំទៅតាមលក្ខណៈវិនិច្ឆ័យ៥យ៉ាង៖(១)សមត្ថភាព(Capacity)៖ ប្រាជ្ញាវាងវៃ ពូកែនិយាយ ពិតឥតក្លែងក្លាយ ចេះវាយតម្លៃត្រឹមត្រូវ (២)ជាមួយអ្នកដឹកនាំឯទៀតនិងជាមួយសមិទ្ធិផល(Achivement)៖ អ្នកប្រាជ្ញ ចំណេះដឹង សមត្ថភាពខាងកីឡា (៣) ការទទួលខុសត្រូវ (Respondsibility)៖ អាចទុកចិត្តបានមានការផ្តួចផ្តើមគំនិត្យ ព្យាយាម ការឆ្លើយតប មានជំនឿជឿជាក់លើខ្លួនឯងចង់ល្អឥតខ្ចោះ (៤) ការចូលរួម (Paticipattion)៖ សកម្មភាពចូលក្នុងសង្គម សហការ សម្របសម្រួល ចេះលេងសើច (៥) ឋានៈ (Status)៖មានឋានៈខាងផ្នែកសង្គមនិងសេដ្ឋកិច្ច និងមានប្រជាប្រិយភាព។

នៅកំឡុងទស្សវត្សរ៍ឆ្នាំ1980 Ralph M. Stogdill (1981)បានពិនិត្យឡើងវិញភាពជាអ្នកដឹកនាំ ដែលត្រូវមានលក្ខណៈដូចតទៅ៖(១)មានការទទួលខុសត្រូវខ្ពស់ និងមានចំណង់ចំណូលចិត្តក្នុងការបំពេញការងារឲ្យបានសម្រេច (២)មានថាមពល និងការព្យាយាមក្នុងការសម្រេចគោលដៅ (៣)ហ៊ាននិងមានភាពច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា (៤)ចូលចិត្តផ្តួចផ្តើម គនិតក្នុងគ្រប់ស្ថានភាព(៥)មានជំនឿជឿជាក់លើខ្លួនឯង និងមានអត្តសញ្ញាណផ្ទាល់ខ្លួន (៦) មានចិត្តក្លាហានក្នុងការទទួលយកនូវបច្ច័យនៃការសម្រេចចិត្ត និងសកម្មភាព (៧) ត្រៀមខ្លួនស្រូវយកកង្វាល់ក្នុងការទំនាក់

ទំនង(៨)ចេះអត់ធ្មត់និងការមួម៉ៅ និងការយឺតយូរ (៩)អាចមានឥទ្ធិពលលើអាកាប្បកិរិយាអ្នកផ្សេង (ហង់ជួន ណារ៉ុន ២០២០)។

បុគ្គលិកលក្ខណៈ(Personallitytraits)នៃអ្នកដឹកនាំមានសារៈសំខាន់ខ្លាំងណាស់ដែលYukl (2002)ចែកជាប្រាំផ្នែកៈ(១)ជំនឿជឿជាក់លើខ្លួនឯង ដែលជួយអ្នកដឹកនាំកំណត់គោលដៅ ដោះស្រាយលំបាកធំៗ និងមានភាពអត់ធ្មត់ក្នុងការប្រឈមនិងបញ្ហា និងភាពបរាជ័យ (២)មានភាពអត់ធ្មត់ចំពោះសម្ពាធនៃអារម្មណ៍តានតឹង(Stress)ជួយអ្នកដឹកនាំសម្រេចចិត្តបានត្រឹមត្រូវ មានស្មារតីនឹងនរ បង្ហាញផ្លូវជាក់លាក់ដល់អ្នកនៅក្រោមបង្គាប់នៅក្នុងស្ថានភាពលំបាក (៣) មានភាពចាស់ទុំនិងចេះគ្រប់គ្រងអារម្មណ៍ ដែលធ្វើឲ្យអ្នកដឹកនាំដឹងច្បាស់ពីរកម្លាំង និងភាពទន់ខ្សោយ និងផ្តោតលើការកែលម្អលើខ្លួនឯង ដោយរក្សាទំនាក់ទំនងសហការជាមួយអ្នកដឹកនាំឯទៀត និងជាមួយអ្នកក្រោមបង្គាប់ (៤) សុចរិតភាព(integrity) អ្នកដឹកនាំមានអាកប្បកិរិយាសមស្របទៅនឹងឯតម្លៃរបស់គេ ស្មោះត្រង់មានសីលធម៌ ទទួលខុសត្រូវ និងគួរឲ្យទុកចិត្ត ដែលជាគុណសម្បត្តិធ្វើឲ្យអ្នកដឹកនាំទទួលបាននៅកិច្ចសហការ និងការគាំទ្រពីអ្នកដទៃនិង (៥)ឥរិយាបទបើកចំហ (Extroversion) អ្នកដឹកនាំមានចរឹករួសរាយរាក់ទាក់និងចេះធ្វើការងារជាក្រុមហើយជាពិសេសគឺជាអ្នកដឹកនាំក្រុមតែម្តង(ហង់ជួន ណារ៉ុន ២០២០)។

### ២.៣.៣. តួនាទី និងភារកិច្ចរបស់នាយក

**តួនាទី និងភារកិច្ចរបស់នាយកមានដូចតទៅៈ**

**ទី១ -ការរៀន និងការបង្រៀន ៖** នាយក គឺជាអ្នកដឹកនាំការរៀន និងការបង្រៀន (Intructional leader) ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យបានល្អ ប្រសើរ ដោយរៀបចំផែនការ ជានានូវការអនុវត្តយុទ្ធសាស្ត្របង្រៀន ការ រៀបចំថ្នាក់រៀន និងការធ្វើវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ការងារ របស់នាយកត្រូវផ្តោតលើការរៀបចំបរិស្ថានសិក្សាល្អ ការរៀបចំថ្នាក់រៀន ការផ្តល់សម្ភារឧបទេស បន្ទប់

ពិសោធ ការរៀបចំកាលវិភាគបង្រៀន ការ អនុវត្តកម្មវិធីសិក្សា ការអនុវត្តវិធីសាស្ត្របង្រៀន ការប្រជុំក្រុមបច្ចេកទេស ដើម្បីផ្តល់យោបល់កែលម្អ។ យើងអាចចែកការងារនេះជាបួនផ្នែកគឺ ៖

- **ការអនុវត្តកម្មវិធីសិក្សា** ៖ នាយកត្រូវដឹងពីក្របខ័ណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងយុទ្ធសាស្ត្របង្រៀន ដើម្បីជួយគ្រូអនុវត្តកម្មវិធី សិក្សា និងសម្រេចបាននូវលទ្ធផលសិក្សា ដោយចែកកម្មវិធីសិក្សាជាមេរៀន ដែលមានគោលដៅច្បាស់លាស់ សកម្មភាព លទ្ធផលសិក្សារបស់សិស្ស និងវង្វាយតម្លៃសម្រាប់មេរៀននីមួយៗ ទៅតាមចំណាត់ចំណេះដឹងរបស់សិស្សានុសិស្ស។ គ្រូត្រូវយកចិត្តទុកដាក់បង្រៀនមេរៀនដែលលំបាក ដោយប្រើប្រាស់ លទ្ធផលនៃវង្វាយតម្លៃដើម្បីកែលម្អការបង្រៀន។

- **ការបង្រៀននៅក្នុងថ្នាក់រៀន** ៖ នាយកត្រូវអនុវត្តយុទ្ធសាស្ត្របង្រៀនដោយធានាឱ្យបាននូវថ្នាក់រៀនដែលមានសម្ភារឧបទ្ទេស មានបរិស្ថានស្អាត និងជួយគាំទ្រគ្រូ និងសិស្សក្នុងការរៀន និងបង្រៀនដើម្បីទទួលបានលទ្ធផលសិក្សាតាមការរំពឹងទុក តាមរយៈការត្រួតពិនិត្យ និងវិធានការកែលម្អជាប្រចាំ។ នាយកត្រូវពិនិត្យថាវិធីសាស្ត្របង្រៀនមួយណា ដែលជួយឱ្យ សិស្សខិតខំប្រឹងប្រែងរៀនសូត្រ សម្រេចបាននូវលទ្ធផលសិក្សាជាចំណេះ ដឹង បំណិនបច្ចេកទេស និងបំណិនទន់ បំណិនត្រិះរិះពិចារណា និង ដោះស្រាយបញ្ហា។ គ្រូត្រូវមានគុណវុឌ្ឍិ បំណិន និងវិធីសាស្ត្របង្រៀន ដើម្បីជួយសិស្សទាំងអស់សម្រេចបានតាមគោលដៅរំពឹងទុក។ នាយកត្រូវ រៀបចំឱកាសឱ្យគេទទួលបាននូវការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ តាមរយៈ ការធ្វើវិក្រឹតការរយៈពេលខ្លី ការបំប៉ននៅនឹងកន្លែង និងការចូលរួមក្នុង វគ្គសិក្សាវែង។ នាយកសាលាត្រូវបង្កើតនូវសហគមន៍ផ្លាស់ប្តូរបទពិសោធន៍វិជ្ជាជីវៈ(PLC)ដើម្បីឲ្យគ្រូអាចកែលម្អវិធីសាស្ត្របង្រៀន និងចែករំលែកបទពិសោធន៍ថ្មីៗបាន។ នាយកត្រូវស្រាវជ្រាវ និងផ្តួចផ្តើមគំនិត ដើម្បីអនុវត្តវិធីសាស្ត្រថ្មីៗ ដើម្បីឆ្លើយតបទៅនឹងនិន្នាការបច្ចុប្បន្នលើសកលលោក។ នាយកត្រូវត្រួត ពិនិត្យជាប្រចាំនូវលទ្ធផលសិក្សារបស់សិស្ស ជាពិសេសដោយផ្តោតលើ ទស្សនាទាន បំណិនបច្ចេកទេស និងបំណិនទន់។ នាយកត្រូវរៀបចំការ ប្រជុំក្រុមបច្ចេកទេស និងផ្តល់ឱកាសឱ្យគ្រូចូលរួមប្រជុំ និងពិភាក្សា ដើម្បី កែលម្អវិធីសាស្ត្របង្រៀន( ហង់ជួន ណារ៉ុន ២០២០)។

- **ការវិភាគទិន្នន័យ** ៖ នាយកត្រូវប្រមូលទិន្នន័យស្តីពី វត្តមានរបស់ សិស្ស និងត្រូវ ការគោរព

វិន័យ លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់ និងតាម មុខវិជ្ជា ដោយប្រើប្រាស់រង្វាយតម្លៃសិក្សា ហើយដាក់ចេញនូវវិធានការ កែលម្អ ដោយមានការចូលរួមពីសំណាក់គ្រូ និងសិស្ស។ នាយកត្រូវមានយន្តការដើម្បីឱ្យទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ នាយកប្រើនូវទិន្នន័យស្តីពីពិន្ទុតេស្តប្រចាំខែ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំឆ្នាំ និងលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតាមមុខវិជ្ជា ដើម្បីដាក់ចេញនូវវិធានការកែលម្អការរៀន និងការបង្រៀន។ នាយកត្រូវតាម ដានសិស្សរបស់ខ្លួនដែលរៀនចប់នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីវាយ តម្លៃពីការសិក្សានៅសាលារៀន។ នាយកត្រូវជួបប្រជុំជាប្រចាំជាមួយគ្រូ និងរៀបចំផែនការកែលម្អ ដោយផ្តោតលើចំណុចខ្លាំង និងចំណុចខ្សោយ របស់សិស្ស។ នាយកត្រូវបង្កលក្ខណៈគ្រូអាចចូលរួមដាក់ចេញនូវវិធា នការកែលម្អដោយលើកឡើងពីឧត្តមានុវត្តន៍ និងវិធានការកែតម្រូវ។ គ្រូត្រូវជួបជាមួយសិស្ស ដើម្បីដាក់ចេញពីវិធានការកែលម្អសម្រាប់សិស្សម្នាក់ៗ។

- **ការអនុវត្តវិធីសាស្រ្តបង្រៀនទៅតាមសមត្ថភាពសិស្ស** ៖ នាយក ត្រូវជួយគ្រូក្នុងការប្រើវិធីសាស្រ្តបង្រៀន ដែលឆ្លើយតបទៅនឹងសិស្ស ផ្សេងៗគ្នា។ នាយកត្រូវធ្វើការជាមួយគ្រូ ដើម្បីរកសិស្សខ្សោយតាមមុខវិជ្ជា ហើយដាក់ចេញនូវវិធានការជួយសិស្សខ្សោយ ដោយបង្កើតឱកាសសិក្សា ម៉ោងបន្ថែម និងផ្តល់ការលើកទឹកចិត្តដល់គ្រូក្នុងការជួយសិស្សរៀនបន្ថែម ម៉ោង បំពេញបន្ថែមនូវចំណុចខ្វះខាតរបស់សិស្ស កាត់បន្ថយហានិភ័យ ផ្សេងៗ។ ទីពីវប្បធម៌សាលារៀន ឬការរៀបចំរបៀបរបបដំណើរការ ៖ វប្បធម៌សាលារៀន គឺជាមូលដ្ឋានគ្រឹះនៃកិច្ចដំណើរកានៃសាលារៀនល្អ។ ដើម្បី បង្កើតឱ្យមានវប្បធម៌ការសិក្សារៀនសូត្រ និងការសម្រេចនូវឧត្តមភាព នាយកត្រូវរៀបចំបញ្ជីលទ្ធផលសិក្សាដែលត្រូវសម្រេចបាន និងវិធានការ ដែលគណៈគ្រប់គ្រង និងសាស្រ្តាចារ្យត្រូវអនុវត្ត ដើម្បីសម្រេចបានតាមគោលដៅដែលបានដាក់ចេញ។

- **ទីពីរការគ្រប់គ្រងធនធានមនុស្ស** ៖ សាលាល្អ គឺសាលាដែលមាន នាយកល្អ ចេះទាក់ទាញជ្រើសរើសគ្រូល្អ ដែលមានសមត្ថភាព បទពិសោធ ជួយគាំទ្រ និងចេះរក្សាគ្រូល្អ តាមរយៈការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ ( ហង់ជួន ណារ៉ុន ២០២០)។

## ២.៣.៤. ភាពជាអ្នកដឹកនាំការបង្រៀន ( INSTRUCTIONAL LEADERSHIP )

ការបង្រៀន គឺជាមុខងារបច្ចេកទេស (Technical core) របស់សាលា រៀន។ លោក 'Talcott Parsons (1960) បានបែងចែកមុខងាររបស់អង្គភាព ជាបីផ្នែក គឺ ៖ (១) បច្ចេកទេស (២) គ្រប់គ្រង និង (៣) ស្ថាប័ន។ ក្នុង ន័យនេះ មុខងារបច្ចេកទេសរបស់សាលារៀន គឺការរៀននិងការបង្រៀន។

ទស្សនាទានទូលំទូលាយនៃភាពជាអ្នកដឹកនាំការបង្រៀន គ្របដណ្តប់ សកម្មភាពដឹកនាំទាំងអស់ ដែលចូលរួមចំណែកក្នុងការរៀនរបស់អ្នករៀន ដូចជាគុណភាពនៃការអនុវត្តកម្មវិធីសិក្សា ការបង្រៀនសិស្ស រួមទាំងសកម្មភាពគាំទ្រ ផ្សេងទៀតដូចជាវប្បធម៌សាលារៀនជាដើម។ គេចាត់ទុកថា នាយកសាលា គឺជាអ្នកដឹកនាំការបង្រៀន ដែលមានឥទ្ធិពលខ្លាំងលើការ រៀនរបស់សិស្ស តាមរយៈសកម្មភាពនៃការគ្រប់គ្រង (ក្រសួងអប់រំ យុវជន និងកីឡា ២០២០)។

នាយកសាលាត្រូវដឹកនាំការងារបង្រៀន ដោយសម្របសម្រួល ជាមួយប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា ដែលត្រូវបំពេញការងារផ្ទាល់ ជាមួយគ្រូបង្រៀន។ ដើម្បីដឹកនាំសាលារៀនមានប្រសិទ្ធភាព នាយកសាលា ត្រូវសម្របសម្រួលការងារជាមួយប្រធានក្រុមបច្ចេកទេសក្នុងការរៀបចំ ថ្នាក់និទស្សន៍ និងការចុះធ្វើអធិការកិច្ចការបង្រៀននៅក្នុងថ្នាក់រៀន។ ក្នុង ន័យនេះ ទស្សនាទានស្តីពីភាពជាអ្នកដឹកនាំការបង្រៀនលើតួនាទី របស់នាយកសាលារៀន ក្នុងការសម្របសម្រួល និងការត្រួតពិនិត្យការ បង្រៀន។ សកម្មភាពរបស់នាយក ក្នុងការវាយតម្លៃការរៀន និងការបង្រៀន នៅក្នុងថ្នាក់រៀន គឺជាគន្លឹះនៃការដឹកនាំសាលារៀនប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់ការរៀនរបស់សិស្ស (Hargreaves et al. 2001, Ha linger, 2005, Leith Wood et al. 2004)។ ( ហង់ជួន ណារ៉ុន ២០២០ ) ។

### ២.៣.៥ គ្រូបង្រៀននៅក្នុងសាលារៀន

គ្រូបង្រៀនក្នុងភារកិច្ចជាសិក្ខាបនធារី ជាកម្លាំងអប់រំចម្បងជួយសិស្សានុសិស្សដោយផ្ទាល់ឱ្យ សម្រេចភារកិច្ចរៀនសូត្ររបស់ខ្លួនដែលជាភារកិច្ចស្នូលរបស់សាលារៀន។ ថ្នាក់នីមួយៗមានកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំខែ តាមមុខវិជ្ជានីមួយៗមានម៉ោងសម្គាល់មានវិធីសាស្ត្របង្រៀនមានវត្ថុបំណងនៃមេរៀនមានលំហាត់អនុវត្តដែលក្រសួងអប់រំយុវជន និងកីឡាបានសម្គាល់ព្រមទាំងមានសិស្សានុសិស្សពី៣០ទៅ៤៥នាក់ ដែលមានចិត្តសាស្ត្រមិនដូចគ្នា និងមានស្ថានភាពគ្រួសារ មិនដូចគ្នា។

គ្រូបង្រៀន ជាអ្នកបច្ចេកទេសត្រូវតែបង្រៀនមុខវិជ្ជានីមួយៗតាមវិធីសាស្ត្រដែលក្រសួងអប់រំយុវជននិងកីឡាបានសម្គាល់។ គ្រូបង្រៀនមិនអាចអភិវឌ្ឍសម្បទាចិត្តគរុកោសល្យរបស់ខ្លួនបានទេប្រសិនបើគាត់មិនបង្រៀនតាមវិធីសាស្ត្រ។ ដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពថែមទៀតនោះទាមទារឱ្យគ្រូបង្រៀនមានការស្រាវជ្រាវឯកសារដែលទាក់ទងនឹងវិធីសាស្ត្របង្រៀនឱ្យបានច្រើន។

បង្រៀនគឺជាមុខងារពិបាក ពីព្រោះគេមិនអាចនៅនឹងមួយកន្លែងពេញចិត្តនឹងខ្លួនឯងប៉ុន្តែគេត្រូវតែសម្របសម្រួលបង្កើតថ្មីនិងរាវរកជានិច្ច។ គ្រូបង្រៀនត្រូវដឹកនាំការបង្រៀនរបស់ខ្លួនសម្រាប់ ថ្នាក់ទាំងមូលផងនិងសម្រាប់សិស្សម្នាក់ៗផង។ ជំបូន្មានគរុកោសល្យមួយល្បះបានបំភ្លឺគ្រូបង្រៀនយើងជានិច្ចកាលថា "ជំរុញសិស្សខ្សោយដោយមិនពន្យឺតសិស្សពូកែ" នេះហើយជាសិល្បៈរបស់ គ្រូបង្រៀនយើង( ហង់ជួន ណារ៉ុន ២០២០)។

គ្រូបង្រៀនត្រូវទទួលខុសត្រូវក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបដោយគុណភាព។ បើមិនយ៉ាងនេះទេអនាគតនៃការសិក្សារបស់សិស្ស នឹងត្រូវវង្វេងគ្រោះហើយដែលជាទូទៅមិនសូវបានទទួលការ លម្អបានផង។

គ្រូបង្រៀនជាអ្នកធ្វើការងារផ្ទាល់ជាមួយសិស្ស ដោគវាសនារបស់ពួកគេសង្ឃឹមលើគ្រូបង្រៀនទាំងស្រុង ដូចនេះគ្រូបង្រៀនគប្បីមានលក្ខណសម្បត្តិដូចខាងក្រោម ៖

## ២.៣.៦ប្រតិបត្តិវិជ្ជាជីវៈ

**ក-និយ័តភាពក្នុងការបំពេញការងារ** ត្រូវគោរពពេលម៉ោងចេញ ចូល យកចិត្តទុកដាក់ក្នុងការ បំពេញការងារ យកចិត្តទុកដាក់បណ្តុះចំណេះដឹង និងសមត្ថភាពសិស្សដោយទទួលខុសត្រូវខ្ពស់ក្នុង ការបង្រៀន និងរៀន។

**ខ-ការរៀបចំផែនការបង្រៀន** ត្រូវធ្វើផែនការបង្រៀនប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ឆមាសនិងឆ្នាំ មានកិច្ចតែងការបង្រៀន(មានចំណងជើងមេរៀន វត្ថុបំណងមេរៀនសម្ភារបង្រៀន រយៈពេលបង្រៀននិងលំនាំសកម្មភាពទាំង៥ជំហាន) ដាក់ជូននាយករងទទួលបន្ទុកបច្ចេកទេសពិនិត្យមុន រយៈពេល១សប្តាហ៍រួចយកមកបង្រៀនសិស្ស មានផែនការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជា,ជនសិស្សជាប្រចាំ(នាយកដ្ឋានចំណេះទូទៅ ២០២០)។

**គ-ការគ្រប់គ្រង និងរៀបចំរដ្ឋបាលថ្នាក់រៀន** គ្រូបង្រៀនត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ រៀបចំតារាងទាំង ០៩ (តារាងកិត្តិយស តារាងចំណាត់ថ្នាក់ប្រចាំខែ ឆមាស បទបញ្ជាផ្ទៃក្នុង បំណែងចែកកម្មវិធីសិក្សា កាលវិភាគវេនសម្អាតថ្នាក់ បញ្ជីសារពើណ្ឌ តារាងប្រឡងឆមាស ) មានភាពប៉ិនបានទទួលការលើគ្រូបង្រៀនកាលវិជ្ជាជីវៈត្រូវសរសេរកិច្ចតែងការប្លែកៗ មាន និងឥរិយាបថាមានការយល់ដឹងវិជ្ជាជីវៈរបស់ខ្លួន អន្តរាគមន៍ ជា គឺពីការសម្រេចសិស្សមានវិន័យល្អ មានការដាក់តាំងស្នាដៃសិស្ស និង សម្ភារបង្រៀន គ្រប់ប្រភេទ ថ្នាក់រៀនមានស្លាក មានបាវចនា អ្នក មានបាវចនា ទង់ជាតិ ព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ មានបញ្ជីហៅឈ្មោះសិស្ស បញ្ជីសម្រង់វត្តមានសិស្ស មានរៀបចំក្តារខៀនសរសេរបានល្អ មាន ក្តាខៀនព័ត៌មាន មានគៀនអនាម័យ កៀនបណ្ណាល័យ មានធុងដាក់សម្រាម(ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។

**ឃ-ការប្រើប្រាស់កិច្ចតែងការបង្រៀន** ក្នុងការតាក់តែងកិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវ ត្រួតពិនិត្យវត្តមាន សណ្តាប់ធ្នាប់ និងអនាម័យថ្នាក់រៀន ត្រូវត្រួតពិនិត្យកិច្ចការរបស់សិស្សសម្រាប់ ធ្វើទំនាក់

ទំនងជាមួយនឹងមេរៀនថ្មី ប្រើប្រាស់សម្ភារបង្រៀន និងរៀនស្របតាមខ្លឹមសារមេរៀន (សម្ភារជាក់ស្តែង សម្ភារច្នៃប្រឌិត រូបភាពតាមឯកសារនានា អនុវត្តជំហានទាំង៥បានត្រឹមត្រូវតាម រយៈពេលកំណត់ មានការឆ្លាស់វេនក្នុងការរៀបចំសកម្មភាពបង្រៀន និងរៀន (ការងារបុគ្គល ក្រុម ដៃគូរ ក្នុងថ្នាក់ក្រៅថ្នាក់ក្រៅសាលា.) ប៉ិនប្រសប់ក្នុងការប្រើប្រាស់សំណួរយ៉ាងតិចបីកម្រិត សំណួរគប្បីផ្សារភ្ជាប់ទៅនឹងជីវភាព និងសមត្ថភាពរបស់សិស្ស តាមលំដាប់លំដោយនៃខ្លឹមសារ មេរៀន បផុសសំណួរបន្ថែមនៅពេលសិស្សមិនអាចឆ្លើយបាន និងជួយគេឱ្យរកឃើញចម្លើយត្រឹមត្រូវ រួចធ្វើការសំយោគ និងវាយតម្លៃ ប៉ិនប្រសប់ក្នុងការលើកទឹកចិត្តសិស្ស មានបញ្ចូល សកម្មភាព ល្បែង សិក្សា ស្របតាមខ្លឹមសារមេរៀន ប៉ិនប្រសប់ក្នុងការសម្របសម្រួល និងផ្តល់ព័ត៌មានត្រឡប់ដល់សិស្ស អនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល ( ការសិក្សាបែបសហការ បុគ្គល ស្វ័យសិក្សា និងឯករាជ្យ ម្ចាស់ការ ) ឈ្លាសវៃក្នុងការសង្ខេបមេរៀន យកចិត្តទុកដាក់ដល់សិស្សគ្រប់សមាសភាគ (យេនឌ័រ ជនពិការ ជនជាតិភាគតិច) ត្រូវប៉ិនប្រសប់ក្នុងការវាយតម្លៃការសិក្សារបស់សិស្ស ត្រូវដាក់កិច្ចការ ឱ្យ សិស្សធ្វើនៅផ្ទះ និងកែជាប្រចាំ និងធ្វើកំណត់ត្រារីកចម្រើនអំពីការសិក្សារបស់សិស្សរៀងរាល់ខែ (ហង់ជួន ណារ៉ុន ២០២០)។

## ២.៦.៧-ក្របខ័ណ្ឌ គន្លងអាជីបគ្រូបង្រៀនកម្ពុជា

គន្លងអាជីបគ្រូបង្រៀនកម្ពុជាមានបីគន្លង ១)គន្លងគ្រូបង្រៀន ២)គន្លងគណៈគ្រប់គ្រង ៣)គន្លងអ្នកឯកទេសអប់រំ ។ នៅក្នុងគន្លងគ្រូបង្រៀនមានមានឋានៈវិជ្ជាជីវចំនួនបីកម្រិត ១)គ្រូល្អ ២)គ្រូឈានមុខ ៣)គ្រូឆ្នើម។

១)គន្លងអាជីបគន្លងអាជីពគ្រូបង្រៀនត្រូវបានរៀបចំសម្រាប់គ្រូបង្រៀន ដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន និងមានឆន្ទៈមោះមុត និងការប្តេជ្ញាខ្ពស់ ដើម្បីឲ្យសិស្សមានការរីកចម្រើនក្នុងជីវិតសិក្សានិងការងារ។ គន្លងគ្រូបង្រៀនចែកជាបីកម្រិតៈ

**គ្រូល្អ៖** គ្រូល្អប្រើវិធីសាស្ត្ររៀន និងបង្រៀនស្របទៅតាមប្រភេទ សារតា តម្រូវការ និងការលូតលាស់របស់សិស្ស។គ្រូបង្រៀនមានការទទួលខុសត្រូវខ្ពស់ និងជាគ្រូគំរូដល់គ្រូដទៃនៅក្នុងសាលារៀនរបស់ខ្លួន។

**គ្រូឈានមុខ៖** គ្រូឈានមុខសហការដឹកនាំ និងគាំទ្រដល់សហការីរបស់ខ្លួន ដើម្បីធ្វើឲ្យប្រសើដល់ការប្រតិបត្តិ វិជ្ជាជីវៈរបស់ខ្លួន និងសហការីរបស់ខ្លួន។

**គ្រូឆ្នើម៖** គ្រូឆ្នើមមានគំនិត្យច្នៃប្រឌិត និងនាវានុវត្តន៍ និងការស្រាវជ្រាវលើការបង្រៀន និងការរៀន ការវាយតម្លៃ លទ្ធផលសិក្សារបស់សិស្ស និគុណផលសាលារៀន និងក្រៅសាលារៀន ដើម្បីធ្វឲ្យសិស្សទទួលបានឱកាសរៀនស្ញូគ្រដូចៗគ្នា។

## ២.៦.៨ ចំណុចខ្លាំងនិងចំណុចខ្សោយនៃវិធីសាស្ត្រ

### វិធីសាស្ត្ររៀន និងបង្រៀនដោយទន្ទេញចាំមាត់

-សិស្សចេះពីខ្លឹមសាមេរៀន(ព្រឹត្តិការណ៍)(facts)និងចេះជំនាញដែលមានស្រាប់Existing skills)។ តែសិស្សអាចភ្លេចនិងមិនបានយកចំណោះដឹងទៅប្រើប្រសិនបើសភាពការប្រែប្រួលទៅអនាគត

-សិស្សប្រមាណជា៧០ទៅ៨០ភាគរយចេះកម្រិតចងចាំ និងយលើដឹងបុណ្ណោះ បើគិតាមវិស័យពុទ្ធិ (Cogntive domain)របស់លោក Bloom)។

-សិស្សទិន្នេញចាំមាត់សំស្រប នៅពេលដែលចំណោះដឹងប្រែប្រួលឃឹតៗ។ អ្នកចេះគឺដឹងរឿងច្រើន។

-លោកBuckminster Fuller បានបង្កើតខ្សែកោងកំណើនធ្វើដង នៃចំណោះដឹង(Knowledge Doudling Curve)។ មុនឆ្នាំ1900 ចំណោះដឹងរបស់មនុស្សកើនទ្វើដងក្នុងរយៈពេល100ឆ្នាំ។ ដល់ចុងសង្គ្រាមលោកលើកទី២ចំណោះដឹងមនុស្សកើនឡើងទ្វេដងក្នុងរយៈពេល២៥ឆ្នាំ។

## ២.៦.៩ វិធីសាស្ត្ររៀន និងបង្រៀនតាមបែបត្រិះរិះ

នាពេលបច្ចុប្បន្នចណោះដឹងខាងផ្នែកnanotechnologyកើនឡើងទ្វេដងក្នុងរយៈពេល២ឆ្នាំ ហើយចំណោះដឹងខាងផ្នែកclinic កើនឡើងទ្វេដង ក្នុងរយៈពេល១៨ខែ។ ជាមួយចំណោះដឹង មនុស្ស

កើនឡើងទ្វេដងក្នុងរយៈពេល១ឆ្នាំ។តាមការទះទាយIBMបន្ទាប់ពីមាន"internet of things"ចំណេះដឹងកើនឡើងទ្វេដងក្នុងរយៈពេល១២ម៉ោង។

ប្រសិនបើសិស្សចង់ដឹងពីព្រឹត្តិការណ៍(facts)គេអាចរកតាមgoogleតែក្នុងរយៈពេលពីរទៅបីនាទីប៉ុណ្ណោះ។ ដូច្នេះគ្រូមិនចាំបាច់យកពេល បង្រៀនសិស្សក្នុងរយៈពេល៣០នាទីទេ។

វិធីសាស្ត្រតាមបែបត្រិះរិះបង្រៀនសិស្សឲ្យចេះអនុវត្ត វិភាគ វាយតម្លៃ និងចូលរួមក្នុងការបង្កើតចំណេះដឹង តាមរយៈការផ្តល់នៅមតិយោបល់ផ្ទាល់ខ្លួនជាពិសេសដោយការប្រើប្រាស់បច្ចេកវិទ្យាពត៌មានក្នុងការស្រាវជ្រាវដោយខ្លួនឯង។ សិស្សក្លាយខ្លួន ជារៀនឯករាជ្យ និងយល់ពីបញ្ញត្តិ និងអាចបង្កើតបញ្ញត្តិដោយខ្លួនឯង។

ការរៀនតាមវិធីសាស្ត្រតាមបែបត្រិះរិះ ធ្វើឲ្យសិស្សអាចទទួលបានបំណិនរៀន ដើម្បីចេះរៀនដោយខ្លួនឯង(learn how to learn)។

ពួកគេអាចប្រើប្រាស់បំណិននេះ នៅពេលដែលពួគេចេញទៅធ្វើការនិងអាចរៀនពេញមួយជីវិតនៅពេលដែលសភាពការណ៍ មានការប្រែប្រលនាពេលអនាគត។

តាមបទពិសោធន៍ សាលារៀជំនាន់ថ្មី សិស្សអាចទទួលបាន ទាំងចំណេះដឹង បំណិនបច្ចេកទេស និងបំណិនទន់ ព្រមទាំងចរិយាសម្បទាផ្សេងទៀត។ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)

## ២.៦.១០ គ្រូទទួលបន្ទុកថ្នាក់ខ្លួន

-គ្រូទទួលបន្ទុកថ្នាក់ជាអ្នកស្គាល់សុខទុក្ខគ្រប់បែបយ៉ាងរបស់សិស្ស ដូច្នេះជោគវាសនារបស់ពួកគេត្រូវបានពឹងផ្អែកទាំងស្រុងលើគ្រូទទួលបន្ទុកថ្នាក់។

- ថ្នាក់រៀននីមួយៗត្រូវមានគ្រូទទួលបន្ទុកថ្នាក់ម្នាក់ចាត់តាំងដោយនាយកសាលា។

-នៅបឋមសិក្សាគ្រូប្រចាំថ្នាក់នីមួយៗមានភារកិច្ចជាសិក្ខាបនធារីគ្រប់មុខវិជ្ជាផង និងជាគ្រូ

ទទួលបន្ទុកថ្នាក់ផង ។

-នៅមធ្យមសិក្សាគ្រូទទួលបន្ទុកថ្នាក់ជាអ្នកបង្រៀនតាមមុខវិជ្ជាឯកទេសផង និងជាអ្នកគ្រប់គ្រងផ្ទាល់ក្នុងមួយថ្នាក់ផង។

-មានភារកិច្ចគ្រប់គ្រងថ្នាក់រៀនមួយ ដោយរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ រៀបចំតារាងទាំង ៩(តារាងកិត្តិយស តារាងវេនសំអាត កម្មវិធីសិក្សា កាលវិភាគ ចំណាត់ថ្នាក់ប្រចាំខែ ចំណាត់ ថ្នាក់ប្រចាំឆមាស បញ្ជីសារពើភ័ណ្ឌ តារាងប្រឡងឆមាស) ត្រួតពិនិត្យអនាម័យ បរិស្ថានថ្នាក់ រៀនមានសណ្ដាប់ធ្នាប់ មានពន្លឺ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ តុបតែងលម្អថ្នាក់រៀន ដោយមានដាក់តាំងសម្ភារ និងស្នាដៃសិស្ស ពាក្យស្លោក ស្លាកថ្នាក់ រូបមន្តផ្សេងៗបម្រើឱ្យ ការរៀន បាវចនា ទង់ជាតិ ព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រ និងថ្នាក់ដឹកនាំប្រទេស គ្រប់គ្រង វត្តមាន អវត្តមានសិស្សគ្រប់គ្រងការសិក្សាគ្រប់គ្រងការអប់រំសីលធម៌គ្រប់គ្រង ឯកសារផ្សេងៗ ដូចជា បញ្ជីហៅឈ្មោះសិស្ស បញ្ជីស្រង់ពិន្ទុសម្រង់វត្តមាន ឯកសារបង្រៀន ឯកសារគ្រប់គ្រងថ្នាក់រៀន និងប្រើប្រាស់សៀវភៅ សិក្ខាគារិក សៀវភៅតាមដានការសិក្សា របស់សិស្ស ឬព្រឹត្តប័ត្រពិន្ទុ ប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ រៀបចំក្ដារខៀនសិក្សា ក្ដារខៀន ព័ត៌មាន កៀនអនាម័យ កៀនសិក្សាតាមមុខវិជ្ជា ធុងអនាម័យតាមថ្នាក់ផ្ទាល់ខ្លួន។

-ផ្តល់ព័ត៌មានស្ដីពីការសិក្សាពិសេសលទ្ធផលសិក្សារបស់សិស្សដល់អាណាព្យាបាលរបស់ ពួកគេឱ្យបានទៀងទាត់ ដោយមានការយកចិត្តទុកដាក់លើសិស្សរៀនយឺត សិស្សពិការ សិស្ស មានបញ្ហាក្នុងការសិក្សា ( បញ្ហាបញ្ញា បញ្ហាមើល បញ្ហាស្ដាប់ ) សិស្សងាយរងគ្រោះ (គ្រួសារ ទីទ័លក្រ មានអំពើហិង្សា ផ្ទុកជំងឺអេដស៍ មេរោគអេដស៍ កុមារកំព្រា )

-គ្រប់គ្រងសិស្សក្នុងការចូលរួមសកម្មភាពសង្គម

-ត្រូវធ្វើរបាយការណ៍ទៀងទាត់ពីស្ថានភាពថ្នាក់ជូននាយកសាលា(ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។

## ២.៦.១១-សីលធម៌វិជ្ជាជីវៈ

ក-សីលធម៌បុគ្គលគ្រូបង្រៀនត្រូវស្លៀកពាក់សម្បរម្យ និងឥរិយាបថថ្លៃថ្នូរ ត្រូវមានភាព រស់រាយរាក់ទាក់ជាមួយសិស្សដោយមិនរើសអើង ត្រូវមានការប្តេជ្ញាចិត្ត និងការពារវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ គោរពសេចក្តីថ្លៃថ្នូរដល់សិស្សានុសិស្ស ( ជីវិត រូបរាងកាយ និងសិទ្ធិ សេរីភាព ) រក្សាការសម្ងាត់វិជ្ជាជីវៈខ្ពស់( កំហុសបុគ្គល ការងារប្រឡង...) មានភាពយុត្តិធម៌ និងតម្លាភាពជាមួយសិស្សានុសិស្ស សហសេវិក និងសមាជិកផ្សេងៗ ផ្តល់ក្តីសង្ឃឹមដល់សិស្សា នុសិស្សក្នុងការសិក្សា អំណត់ព្យាយាមក្នុងការងារ និងស្រឡាញ់វិជ្ជាជីវៈ មានទំនាក់ទំនង និងសាមគ្គីភាពជាមួយគ្រូបង្រៀន សិស្សានុសិស្ស មាតាបិតា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ និងដៃគូអភិវឌ្ឍន៍ ចូលរួមគ្រប់សកម្មភាពសង្គមនានា សកម្មភាពនៃការអប់រំក្នុង និងក្រៅសាលារៀន គោរពច្បាប់ស្តីពីការអប់រំច្បាប់ផ្សេងៗ ស្តាប់និងអនុវត្តតាមការចាត់តាំងរបស់គណៈគ្រប់គ្រង ចូលរួម ថែរក្សាការពារទ្រព្យសម្បត្តិសាធារណៈ ។

ដើម្បីឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់គ្រូបង្រៀន នាយកសាលាត្រូវធ្វើការបែងចែកភារកិច្ចសមនឹងសមត្ថភាពលើកទឹកចិត្ត ផ្តល់កិត្តិយសដើម្បីឱ្យការអនុវត្តភារកិច្ចមានប្រសិទ្ធភាព។ ការប្រកាន់បក្សពួកអំពើអយុត្តិធម៌ជាប្រភពនៃការបែកបាក់សាមគ្គី ដែលបង្ករមហន្តរាយដល់សាលារៀន។

**ខ-ស្មារតីយុត្តិធម៌** យុត្តិធម៌ជាប្រភពនៃសេចក្តីសុខក្នុងសង្គម ។ មានអយុត្តិធម៌ ចាប់ និង ការបែកបាក់ព្រមទាំងគំនុំគុំគួនផងៗជាការពិតសិស្សនៅវ័យក្មេង ប៉ុន្តែគេចាប់លើបញ្ហាយុត្តិធម៌ ។ កូនសិស្សឈឺចាប់បំផុតនៅពេលដែលគេមានគំនិតលំអៀង (ពេល ដាក់ពិន័យ ឬ ពេលសរសើរ ) អំពើទាំងនេះធ្វើឱ្យសិស្សដឹងភ្លាម ។ ហើយវាធ្វើឱ្យសិស្សបំភ្លេចមិនបានទេ។ ផ្តើមចេញពីនេះសិស្សនឹងស្អប់គ្រូហើយទីបំផុតគ្រូនឹងអស់ឥទ្ធិពល។ ជាការចាំ ម្យ៉ាងវិញទៀតគ្រូត្រូវចងចាំក្នុងចិត្តថាអំពើអយុត្តិធម៌តែងនាំមកនូវប្រតិកម្មជានិច្ចពីសិស្ស ជាប្រចាំ។ គ្រូចាំបាច់ត្រូវមានគោលការណ៍ច្បាស់លាស់ហើយត្រូវអនុ

វត្តគោលការណ៍ឱ្យបានខ្ជាប់ខ្ជួនជា ដែលមានស្មារតីយុត្តិធម៌នឹងទទួលការស្រឡាញ់រាប់អាននិងការគោរពពីសិស្ស។ ជារួមការរៀបរាប់ខាងលើបង្ហាញឱ្យឃើញថាមុខងារជាគ្រូបង្រៀន ពោរពេញទៅដោយភាព ស្មុគស្មាញ តែជាមុខរបរមួយប្រកបដោយកិត្តិយស ដែលគ្រូបង្រៀនត្រូវតែទទួលយកដោយសុទិដ្ឋិនិយម ខំបំពេញភារកិច្ចឱ្យបានសម្រេចដើម្បីអនាគតកុមារនិងប្រទេសជាតិទាំងមូល ។

**គ-គ្រូស្រលាញ់និងថ្នាក់ថ្នមសិស្ស** គ្រូបង្រៀនគឺជាអ្នកស្រឡាញ់ និងអាណិត អាសូរសិស្ស។ សេចក្តីស្រឡាញ់នាំមកនូវការស្រឡាញ់តបមកវិញកាលណាគ្រូស្រឡាញ់រាប់អាន សិស្សនិងជិតស្និទ្ធជាមួយសិស្ស ។ គ្រូចេះអត់ឱននិងអធ្យាស្រ័យរាល់កំហុសសិស្ស ដែលជាទូទៅគឺជា កំហុសរបស់កុមារភាព និងយុវវ័យ។

**ឃ-ភាពម៉ឺងម៉ាត់ គួបផ្សំនឹងចិត្តទូលាយ** គ្រូបង្រៀនត្រូវមានសន្តានចិត្តល្អចំពោះកុមារ ។ ប៉ុន្តែគ្រូបង្រៀនល្អគប្បីចាំថា សន្តានចិត្តល្អជ្រុលនាំមកនូវភាពទន់ខ្សោយនេះនឹងនាំមកនូវការខ្វះ វិន័យ។ គ្រូបង្រៀនដែលមានភាពម៉ឺងម៉ាត់ និយាយដោយប្រើពាក្យសម្តីទន់ភ្លន់និងជាក់លាក់ព្រោះគេ តែងគិតយ៉ាងហ្មត់ចត់មុននឹងនិយាយ។ បើក្នុងករណីគាត់បានពោលពាក្យសន្យាឬប្រើពាក្យគំរាម កំហែង ពាក្យសម្តីទាំងនេះមិនអត់ប្រយោជន៍ឡើយហើយសិស្សប្រាកដជាដឹង។

**ង-ទឹកមុខ** ទឹកមុខល្អគឺជាគុណសម្បត្តិមួយទៀតរបស់គ្រូបង្រៀន ។ ជានិច្ចកាលគ្រូបង្រៀនត្រូវបង្ហាញទឹកមុខស្ងប់ស្ងៀម ឬ ធម្មតាចំពោះមុខសិស្ស ។ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយឬក៏ជួបប្រទះនូវបាតុភូតអាក្រក់ណាក៏ដោយ គ្រូគប្បីចេះសំរួលឬទប់កំហឹងចំពោះការមិនសប្បាយចិត្ត ដោយមិនត្រូវបង្ហាញឱ្យសិស្សដឹងពីអារម្មណ៍របស់ខ្លួនឡើយ ។ អារម្មណ៍និងទឹកមុខស្រស់នេះបង្ហាញ ឱ្យឃើញនូវសុទិដ្ឋិនិយមរបស់គ្រូបង្រៀន ក្នុងការកសាងជីវភាពនិងសង្គមឈានទៅរកវឌ្ឍនភាពរបស់មនុស្សជាតិ។

**ច-ភក្តីភាព** អំណត់អត់ធន់គ្រូបង្រៀនត្រូវមានភក្តីភាពចំពោះសិស្ស ។ ភាពស្មោះត្រង់មិនថាពុតលើកិត្យានុភាពរបស់គ្រូ ។ ការអប់រំជាការងារមួយ ដែលទាមទារការអត់ធ្មត់ អំណត់អត់ធន់ និងឧស្សាហ៍ព្យាយាម ។ គ្រូបង្រៀនដែលអំណត់អត់ធន់ និងឧស្សាហ៍ព្យាយាម មិនខ្លាចការ និង ការនឿយហត់ឡើយ ។

ស្ថិតនៅចំពោះមុខលទ្ធផលមិនល្អ ឬ មិនពេញចិត្ត គាត់មិនរួញរានិងការចាប់ផ្តើមបង្រៀន វិញរាល់មេរៀន ដែលបានបង្រៀនរួចហើយនោះឡើយ ។ គាត់មិនដែលអស់សង្ឃឹមនឹងការងារ ទោះជាការងារនោះមិនសូវទទួលបានលទ្ធផលល្អក៏ដោយ ក៏គាត់តែងតែមានទឹកមុខញញឹម។ តែងតែមានទឹកមុខញញឹម និងចាប់ផ្តើមធ្វើជាថ្មី រហូតបានទទួលភារកិច្ចជោគជ័យគ្រប់ភារកិច្ច។ បង្រៀនតិចតែល្អ នេះជាឧត្តមគតិរបស់គ្រូបង្រៀន ដែលឧស្សាព្យាយាមនិងអំណត់ ក្នុងបរសិការបស់គាត់ គាត់មិននឿយហត់ អស់សង្ឃឹម ក្នុងការស្រាវជ្រាវ រកអ្វីដែលថ្មី និងច្បាស់លាស់មកបង្រៀន។ ការស្រាវជ្រាវនិងស្វែងស្រាវជ្រាវជាទំលាប់ ប្រចាំថ្ងៃរបស់គាត់ ។

**ឆ-មនសិការវិជ្ជាជីវៈ** ជាគន្លឹះ ដែលធ្វើមនុស្សរៀនសូត្រទទួលបាន នូវជោគជ័យក្នុងការងារ។ យកអ្នកអប់រំត្រូវមានស្មារតីភ្ញាក់រលឹក ទទួលខុសត្រូវចំពោះមុខសិស្ស ចំពោះអ្នកអាណាព្យាបាលសិស្ស ចំពោះសង្គមជាតិ និងមនុស្សទាំងមូល ។ វាសនាអនាគតនៃយុវវ័យជំនាន់ក្រោយ គឺស្ថិត នៅក្នុងកណ្តាប់ដៃនៃការអប់រំ ។

ដូចនេះវាសនាអនាគតប្រទេសជាតិ ក៏អ្នកអប់រំជាអ្នកកំណត់ដែរ។ កូន របស់គ្រូបង្រៀន បញ្ញាកុមារ និងយុវវ័យឱ្យស្គាល់តម្លៃរបស់ជាតិ និង តម្លៃជាសកល ដោយ អប់រំពួកគេបន្តិចម្តងៗឱ្យមានសមត្ថភាពចូលរួមបម្រើការរីកចម្រើនរបស់សង្គមជាតិ និង របស់សកល លោក ទាំងមូល។ គ្រូបង្រៀនអាចបំពេញតួនាទីនេះបាន លុះណាតែមានជំនឿចិត្តខ្លួនឯងនិងឱ្យតម្លៃ លើតួនាទីនេះ ផងពិសេសគ្រូបង្រៀនត្រូវចាប់អារម្មណ៍និងជឿជាក់លើការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកទេស លើសោភ័ណភាព

លើសង្គម និងសីលធមផងដែរ។ ផ្តើមចេញពីនេះ គ្រូនឹងមានមនសិការ វិជ្ជាជីវៈខ្ពស់ ហើយទទួលបានជោគជ័យគ្រប់ជំហាន (ហង់ជួន ណារ៉ុង ២០២០)។

### ២.៦.១២ ភត្តាសិស្ស

នាយកសាលាបង្ហាញនូវសុឆន្ទៈថា សិស្សានុសិស្សជាទំពាំងស្នងឫស្សីសម្រាប់ ជាអ្នកស្រែកឃ្លានការសិក្សា និងត្រូវទទួលការអប់រំជាចាំបាច់ ដើម្បីក្លាយ ប្រទេសជាតិ សិស្សានុសិស្សគ្រប់រូបត្រូវចូលរៀន ពេញចិត្ត និងអនុវត្តតាមបទបញ្ញាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សាមានដូចខាងក្រោម ៖

-មានសម្លៀកបំពាក់សមរម្យ (កុមារ/ យុវជន ស្លៀកខោខៀវ ពាក់អាវស ខៀវ ពាក់អាវសបើកកដូចគ្នា)

-មានអនាម័យជានិច្ច ទាំងអនាម័យសម្លៀកបំពាក់ និងខ្លួនប្រាណ (ដុសក្អែល កាត់ក្រចកសមរម្យ (កុមារ/ យុវជន ស្លៀកខោខៀវ ពាក់អាវសបើកក រីឯកុមារី ស្លៀកសំពត់ ជើង...)

-តុបតែងខ្លួនឱ្យបានសមរម្យ សិស្សប្រុសត្រូវកាត់សក់ឱ្យខ្លី រីឯសិស្សស្រីត្រូវចងសក់ឱ្យបានត្រឹមត្រូវ ចៀសវាងការតុបតែងខ្លួនមានភាពឆើតឆាយហួសហេតុ (ការលាបពណ៌សក់ ការលាបក្រចក ជាតិម្សៅ លាបក្រេម ពាក់គ្រឿងអលង្ការ សំពត់ខើច)។

-ចូលរួមគោរពទង់ជាតិគ្រប់ពេល

-រក្សាសណ្តាប់ធ្នាប់ និងវិន័យនៅក្នុងទីធ្លាគ្រឹះស្ថានសិក្សា ក្នុងបន្ទប់រៀនពេលរៀនសូត្រពេលចេញ លេង និងពេលចេញពីគ្រឹះស្ថានសិក្សា

-ខិតខំយកចិត្តទុកដាក់រៀនសូត្រ អនុវត្តតាមការណែនាំរបស់លោកគ្រូ អ្នកគ្រូ និងបំពេញរាល់កិច្ចការ ដែលលោកគ្រូ អ្នកគ្រូដាក់ឱ្យធ្វើ

-ប្រកាន់អាកប្បកិរិយាសមរម្យ ស្រឡាញ់យកអាសារមិត្តភក្តិ មានសាមគ្គីភាព មានសុជីវធម៌ ចេះ គោរពគ្នាទៅវិញទៅមក គោរពចាស់ព្រឹទ្ធាចារ្យ និងលោកគ្រូ អ្នកគ្រូ គ្រប់សកម្មភាពការងារ ក្រោក

ឈរ និងគោរពសំពះដោយទឹកមុខរីករាយ រាល់ពេលលោកគ្រូ អ្នកគ្រូ ឬ ភ្ញៀវចូល ឬ ចេញពីបន្ទប់រៀន រហូតដល់លោកទាំងអស់នោះអនុញ្ញាតឱ្យអង្គុញចុះវិញ។

-ស្មោះត្រង់រវាងគ្នា និងចំពោះគ្រឹះស្ថានសិក្សា ដោយមិនត្រូវយកវត្ថុផ្សេងៗរបស់គ្រឹះស្ថានសិក្សា និង របស់មិត្តភក្តិនោះឡើយ ។ ប្រសិនបើសិស្សណាម្នាក់រើសបានវត្ថុអ្វីមួយត្រូវយកប្រគល់ជូនទីចាត់ការឬ នាយក នាយិកា គ្រូបង្រៀន គ្រឹះស្ថានសិក្សា ដើម្បីធ្វើការចាត់ចែងផ្សព្វផ្សាយ និងប្រគល់ជូនម្ចាស់ដើមវិញ។

-រក្សាភាពស្ងប់ស្ងៀមនៅក្នុងថ្នាក់ពេលលោកគ្រូ អ្នកគ្រូអវត្តមាន ឬ មកយឺតយ៉ាវហើយរង់ចាំលោកគ្រូ អ្នកគ្រូមកជំនួស ករណីគ្មានដំណឹងក្រោយរយៈពេល ១៥នាទី ប្រធានថ្នាក់ត្រូវទៅជម្រាបសួរដំណឹង ពីនាយក នាយិកា នៅទីចាត់ការ ដើម្បីទទួលព័ត៌មាន និងការណែនាំផ្សេងៗ។

-រាយការណ៍ជាបន្ទាន់ជូនលោកគ្រូ អ្នកគ្រូ ឬ នាយក នាយិការាល់បាតុភាពអសកម្ម និងឧបហេតុ ផ្សេងៗ ដែលកើតមានក្នុងគ្រឹះស្ថានសិក្សា

-ចូលរួមគ្រប់សកម្មភាពរបស់សាលារៀនដូចជាថែរក្សាសួនច្បារ សួនបន្លែដាំ និងថែរទាំដើមឈើ ចិញ្ចឹមសត្វ ធ្វើពលកម្ម និងយាមកាម រក្សាសន្តិសុខ និងសុវត្ថិភាពសាលារៀន

-ចូលរួមគ្រប់សកម្មភាពសង្គមក្រោមការដឹកនាំរបស់លោកគ្រូ អ្នកគ្រូ និងក្រុមប្រឹក្សាកុមារ យុវជន ដូចជា ការចូលរួមពិធីបុណ្យក្នុងវត្តអារាម ដង្ហែក្បួននានា ការច្រូតកាត់ និងសកម្មភាពមនុស្សធម៌បណ្តាជាតិ។

-រាល់ទណ្ឌកម្មលើរាងកាយ និងស្មារតីសិស្សត្រូវហាមឃាត់ដាច់ខាតក្នុងសាលារៀន ចំពោះសិស្ស ប្រព្រឹត្តខុស ត្រូវដាក់ជូនក្រុមប្រឹក្សាវិន័យពិនិត្យ និងសម្រេចទៅតាមកម្រិតកំហុស

-ការគាបសង្កត់សិស្សគ្រប់រូបភាព ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវហាមឃាត់ជាដាច់ខាត

-ត្រូវបានទទួលការសរសើរលើកទឹកចិត្តជូនរង្វាន់ដល់សិស្សដែលរៀនសូត្រពូកែនិងចូលរួមធ្វើសកម្មភាពបានល្អ

-ត្រូវបានអនុញ្ញាតច្បាប់ឱ្យទៅពិនិត្យរោគដោយយកសៀវភៅពិនិត្យសុខភាពទៅជាមួយនិងទទួលឱ្យចូលរៀនវិញនៅពេលជាសះស្បើយ

-ត្រូវសុំច្បាប់ឈប់នៅពេលមានរវល់ ឬមានជំងឺផ្សេងៗ

-សិស្សានុសិស្សមិនត្រូវធ្វើសកម្មភាពមិនគប្បីដែលនាំឱ្យប៉ះពាល់ដល់កិត្តយស សេចក្តីថ្លៃថ្នូររបស់សាលារៀន និងប្រទេសជាតិដូចជា ការប្រើប្រាស់គ្រឿងញៀន ជក់បារី គ្រឿងស្រវឹងគ្រប់ប្រភេទ ជិះកង់ ម៉ូតូ និងពាក់មួកក្នុងបរិវេនសាលារៀន ស្រែកឡូឡា ឈ្លោះប្រកែក និយាយស្តីដោយជេរ ប្រមាថមើលងាយគ្នា ឬ បញ្ចេញអាកប្បកិរិយាអាសអាភាស រើសអើងប្រព្រឹត្តអំពើហិង្សាពាលាផ្សេងៗ និងអំពើដែលនាំឱ្យមានគ្រោះថ្នាក់ (ឡើងដើមឈើ ឡើងរបង លេងក្នុងស្រះទឹក ឬកន្លែងមានគ្រោះ ថ្នាក់) ចោលសម្រាម ឬខាកស្តោះធ្វើឱ្យទីធ្លាសាលារៀនកខ្វក់ គប់បំបែក ឬបំផ្លាញវត្ថុផ្សេងៗរបស់ សាលារៀន ការសរសេរ ឬ គូសវាសលើជញ្ជាំង តុ ទូ ទ្វា បង្អួចបន្ទប់រៀន របង ខ្លោងទ្វា បន្ទោបង់ក្រៅ បង្គន់ ឬ បត់ជើងតូចធំ ដោយមិនចាក់ទឹក ធ្វើឱ្យអគារ គ្រឿងសង្ហារឹម និងសម្ភារសិក្សាកខ្វក់ ឬ ខូចខាត យកអាវុធ ឬគ្រឿងផ្ទុះចូលក្នុងបរិវេនសាលារៀន អានសៀវភៅ ឬអត្ថបទ ឬទស្សនាវដ្តី អាសអាភាស...។

-នាយកសាលាត្រូវបង្ហាញឱ្យសិស្សានុសិស្សទាំងអស់បានឃើញថា រាល់ការប្រឹងប្រែងរបស់នាយកសាលា របស់គ្រូបង្រៀន របស់សហគមន៍ និងវិធានការវិន័យចំពោះសិស្សានុសិស្សគឺ ដើម្បីជួយសិស្សានុសិស្សទាំងអស់ឱ្យសម្រេចបាននូវលទ្ធផលល្អនៃការសិក្សា សម្រាប់បង្គរលក្ខណៈឱ្យពួកគេមានអនាគតល្អ នៅពេលដែលពួកគេត្រូវបានបញ្ចប់ការសិក្សា។

ប្រការនេះអនុគ្រោះឱ្យសិស្សានុសិស្សគោរពវិន័យសាលារៀនដោយមានការយល់ដឹង និងការខិតខំរៀនសូត្រដោយសប្បាយរីករាយ(ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។

## ៣-សហគមន៍

### ៣.១.១ស ហគមន៍និងសាលារៀន

សាលារៀន និងសហគមន៍ ជាកោសិការបស់សង្គមជាតិ។ សាលារៀនជាមជ្ឈមណ្ឌល សម្រាប បណ្ដាល ពលរដ្ឋគ្រប់វ័យឱ្យមានសមត្ថភាព និងគុណធម៌ រួមចំណែកក្នុងការអភិវឌ្ឍសហគម ន៍ ប្រទេសជាតិឱ្យរីកចម្រើន។ ដូចនេះទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ទាមទារការ ខិតខំ ប្រឹងប្រែងយកចិត្តទុកដាក់ប្រមូលផ្ដុំរាល់កម្លាំងពាក់ព័ន្ធសំខាន់ៗ ដែលមាននៅក្នុងសាលារៀន និង សហគមន៍ឱ្យអស់លទ្ធភាពរបស់មូលដ្ឋាននីមួយៗ ទាំងសម្ភារ និងស្មារតី បង្កើតជាអង្គឯកភាពមួយ រឹង មាំ សម្រាប់ធានាដល់ដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននិរន្តរភាព។

កន្លងមកការចូលរួមរបស់សហគមន៍ ក្នុងវិស័យអប់រំនៅប្រទេសកម្ពុជា មានសភាពខ្លាំងក្លា ណាស់ បើ ប្រៀបធៀបនឹងប្រទេសមួយចំនួនក្នុងតំបន់។ ទង្វើទាំងអស់នេះ នៅតែជាបទពិសោធន៍ ដ៏សំខាន់ ក្នុង ការជួយអភិវឌ្ឍវិស័យអប់រំនាពេលបច្ចុប្បន្ន ក៍ដូចទៅអនាគត។ ដើម្បីធានានិរន្តភាព និងសម្រេចបាន តាមគោលដៅអប់រំជាតិ អ្នកគ្រប់គ្រងអប់រំ ជាពិសេស នាយកសាលាចំណោះទូទៅ គប្បីស្វែងយល់នូវ ខ្លឹមសារឯកសារ ការងារទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ និងប្រើប្រាស់ យុទ្ធវិធីសំខាន់ៗ គួប ផ្សំជាមួយនឹងបទពិសោធន៍ល្អៗកន្លងមកដើម្បីទាក់ទាញសហគមន៍ចូលរួមឱ្យ បានផុលផុសក្នុងការក សាងធនធានមនុស្សប្រកបដោយគុណភាព(ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

### ៣.១.២ ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍

នៅសង្គមណាក៍ដោយ សាលារៀននិងសហគមន៍ត្រូវមានទំនាក់ទំនងគ្នាពុំអាចកាត់ផ្ដាច់គ្នា បានឡើយ។ សាលារៀនពុំអាចអភិវឌ្ឍបានបើខ្វះការចូលរួមពីសហគមន៍។ រីឯសហគមន៍វិញក៍ពុំអាច គង់វង្ស និងរីកចម្រើនបានបើខ្វះការផ្ដល់កម្លាំងចលករពីសាលារៀនផងដែរ។ អាស្រ័យហេតុនេះ ទើប ទំនាក់ទំនង រវាងការអប់រំរបស់សាលារៀន ការអប់រំរបស់គ្រួសារ និងការអប់រំរបស់សង្គម ចាំបាច់ត្រូវដំ ណើការព្រមៗគ្នា ឯកភាពគ្នា គ្រប់ផ្នែក ទោះបីសម្រេចនៅគោលដៅអប់រំជាតិ។ សាលារៀនចំណោះ

ទូទៅត្រូវមានតួនាទី ជាអ្នកដឹកនាំ ដែលមានគ្រូបង្រៀនជាកម្លាំងស្នូលក្នុងកិច្ចការទំនាក់ទំនងរវាងការអប់របស់សាលារៀន ជាមួយនឹងការអប់រំរបស់សង្គម។ តាមការពិសោធន៍ កន្លងមកការងារបង្រៀន និងរៀនទទួលបានលទ្ធផលល្អ អាស្រ័យដោយគ្រូទទួលបន្ទុកថ្នាក់មានបទពិសោធ និងមានការសហការណ៍ល្អពីមជ្ឈដ្ឋានការអប់រំទាំង៣(សាលា គ្រួសារ និងសហគមន៍)។ លោកគ្រូអ្នកគ្រូទទួលបន្ទុកថ្នាក់ទាំងអស់(ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

## ៤-យន្តការតេស្តគណិតវិទ្យាថ្នាក់ទី៦ឡើងទី៧ ដើមឆ្នាំសិក្សា

### -សេចក្តីផ្តើម

បច្ចុប្បន្នគុណភាពអប់រំកំពុងមានបញ្ហាប្រឈមមួយ ក្នុងចំណោមបញ្ហាប្រឈមផ្សេងៗទៀតនោះគឺសិស្សរៀនឆ្លងភូមិសិក្សាពីថ្នាក់ទី៦ឡើងថ្នាក់ទី៧ ដែលមិនទាន់មានចំណេះដឹងមូលដ្ឋានគណិតវិទ្យាជាពិសេសប្រមាណវិធីទាំង៤ ស្ថិតក្នុងអត្រាមួយគួរឱ្យកត់សម្គាល់។ សិស្សទាំងនេះ ជាមុខសញ្ញាសិស្សប្រឈមនឹងការបោះបង់ការសិក្សាផងដែរ។ ដូច្នេះសាលារៀនកម្រិតមធ្យមសិក្សាបឋមភូមិមានភារកិច្ចដ៏ចាំបាច់មួយ ក្នុងការរៀបចំផែនការជួយជាបន្ទាន់ដល់សិស្សដែលមិនទាន់មិន ទាន់មានចំណេះដឹងមូលដ្ឋានគណិតវិទ្យានៅដើមឆ្នាំសិក្សាថ្នាក់ទី៧។ ការជួយសិស្សខ្សោយផ្នែកគណិតវិទ្យានេះមានសារប្រយោជន៍ក្នុងការរួមចំណែកកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សានិងជួយសិស្សឱ្យរៀនមុខវិជ្ជាផ្សេងទៀតជាពិសេសផ្នែកវិទ្យាសាស្ត្របានល្អប្រសើរ។ ដូច្នេះសាលារៀនដែលកម្រិតមធ្យមសិក្សាបឋមភូមិ ត្រូវរកឱ្យឃើញមុខសញ្ញាសិស្សខ្សោយ ប្រមាណវិធីទាំង៤(បូក ដក គុណ ចែក) នៃគណិតវិទ្យា មុនពេលសិស្សទាំងនោះចាប់ផ្តើមរៀនថ្នាក់ទី៧ និងត្រូវរៀបចំផែនការជួយជាបន្ទាន់មុនពេលចាប់ផ្តើមបង្រៀនតាមកម្មវិធីសិក្សាថ្នាក់ទី៧គ្រប់មុខវិជ្ជា។

### -តើតេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យាជាអ្វី?

តេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា គឺជាតេស្តមួយប្រភេទដែលគេធ្វើឡើងដើម្បីវាស់ស្ទង់ចំណេះដឹងមូលដ្ឋានគណិតវិទ្យា ដែលសិស្សចាំបាច់ត្រូវចេះ ទើបអាចរៀនបន្តទៅកម្រិតថ្នាក់បន្តបន្ទាប់ទៀតបាន។ តេស្តនេះផ្តោតលើប្រមាណវិធីទាំង៤ នៃគណិតវិទ្យាមាន ប្រមាណវិធីបូក ប្រមាណវិធីដកប្រមាណវិធីគុណ និង ប្រមាណវិធីចែក។

**-គោលបំណងនិងសារៈសំខាន់នៃតេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា**

ការធ្វើតេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា មានគោលបំណងរកឱ្យឃើញមុខសញ្ញាសិស្សខ្សោយចំណេះដឹងមូលដ្ឋានគណិតវិទ្យា ជាពិសេសប្រមាណវិធីទាំង៤នៃ គណិតវិទ្យាមានប្រមាណវិធីបូក ដកគុណ និងចែក ដើម្បីរៀបចំផែនការជួយសិស្សឱ្យបានទាន់ពេលវេលា និងដើម្បីបង្កើនសមត្ថភាពសិស្សផ្នែកចំណេះដឹងមូលដ្ឋានគណិតវិទ្យា។ តេស្តនេះមានគោលបំណងនិងសារៈសំខាន់ដូចខាងក្រោម៖

- កំណត់បានមុខសញ្ញាសិស្សខ្សោយចំណេះដឹងមូលដ្ឋានគណិតវិទ្យាមានប្រមាណ វិធីបូក ដកគុណ និងចែក ដើម្បីជួយសិស្សបានទាន់ពេលវេលា
- បង្កើនសមត្ថភាពសិស្សលើចំណេះដឹងមូលដ្ឋានគណិតវិទ្យា
- តេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា អាចប្រើប្រាស់ជា តេស្តដើមឆ្នាំ តេស្តចុងឆ្នាំ តេស្តប្រចាំខែ តេស្តប្រចាំឆមាស។ល។
- ជួយសិស្សក្នុងការរៀនមុខវិជ្ជានានាជាពិសេសផ្នែកវិទ្យាសាស្ត្រឱ្យបានល្អប្រសើរ។

**-ដំណើរការនៃតេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា**

៤.១- ការសរសេរវិញ្ញាសា

៤.១.១-ការសិក្សាកម្មវិធីសិក្សាលម្អិត និងគោលការណ៍សម្រាប់សរសេរវិញ្ញាសា

ការធ្វើតេស្តអំណានស្ទាត់ត្រូវផ្អែកលើ៖

- បំណែកចែកកម្មវិធីសិក្សា

- ស្តង់ដាកម្មវិធីសិក្សា

- លទ្ធផលសិក្សា

- សៀវភៅសិក្សាគោលមានសៀវភៅសម្រាប់គ្រូសៀវភៅសម្រាប់សិស្សនិងឯកសារពាក់ព័ន្ធផ្សេងៗ

- ទ្រឹស្តីប្លូម

- កម្រិតលំបាកនៃសំណួរតេស្ត

-ការសរសេរវិញ្ញាសា និងតេស្តសាកល្បងជាមួយគ្រូបង្រៀន និងសិស្ស

## ក- ការសរសេរវិញ្ញាសាតេស្ត

ក.១- តើអ្វីសំណួរតេស្តដែលល្អ?

- សំណួរតេស្ត (Item) ជាធាតុសំខាន់ជាងគេទាំងអស់សម្រាប់ដំណើរការ តេស្តទាំងមូល
- តើវាគឺជាសិល្បៈ ឬជាវិទ្យាសាស្ត្រ? គឺទាំងពីរ ព្រោះជាវិធីសាស្ត្រពិសោធន៍ (experimental method) និងជាបណ្តុំនីតិវិធីសម្រាប់តាក់តែង item ឱ្យបានល្អ (ទម្រង់ ការប្រើប្រាស់ពាក្យពេចន៍ រូបភាព...)
- សំណួរតេស្តដែលសមស្របនឹងសមត្ថភាពសិស្សដែលយើងចង់វាស់វែងពោលគឺខ្លឹមសារនៃសំណួរ និងគោលបំណងនៃការវាយតម្លៃត្រូវឱ្យមានលក្ខណៈសមស្របគ្នា
- សំណួរត្រូវមានទម្រង់សំណង់សំណួរច្បាស់លាស់ ដោយមិនស្រពិចស្រពិល
- សំណួរដែលទាក់ទងជំនាញក្នុងការ ត្រិះរិះ ការវិភាគ ការធ្វើសំយោគ និងការវាយតម្លៃផ្សេងៗ ដោយមិនមែនជាសំណួរដើម្បីរំឭកការចងចាំ ឬអនុវត្តន៍ ធម្មតានោះឡើយ
- ចំណុចគួរចៀសវាង៖ លក្ខណៈបញ្ឆោត កំប៉ិកកំប៉ុក ប្រើពាក្យ(វត្ថុ) ដែលកុមារនៅតំបន់ផ្សេងទៀតមិនអាចយល់, ឃ្លា-ប្រយោគវែង ស្មុគស្មាញ មិនត្រឹមត្រូវ មិនស៊ីសង្វាក់នឹងប្រធាន ប្រយោគបដិសេធ សំនួនវោហារ...។

ក.២- លក្ខណៈពិសេសនៃសំណួរតេស្ត (Item)

- តំណាងឱ្យខ្លឹមសារមេរៀន ទាក់ទងនឹងលទ្ធផលសិក្សាក្នុងកម្មវិធីសិក្សា
- មានខ្លឹមសារផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- មានកម្រិតពុទ្ធិ ឬបំណិនពីទាបទៅខ្ពស់
- អាចឱ្យសិស្សបញ្ចេញសមត្ថភាពពីទាបទៅខ្ពស់។

ក.៣-ប្រភេទនៃសំណួរតេស្ត

ប្រភេទសំណួរតេស្ត៖

- សំណួរតេស្តដែលមានចម្លើយជ្រើសរើស (Selected-Response Test Item)៖ អ្នកធ្វើតេស្តត្រូវជ្រើសរើសចម្លើយមួយគត់ ពីជម្រើសចម្លើយ និងប្រធានលំហាត់ដែលគេឱ្យ។ នៅក្នុងប្រភេទសំណួរតេស្តប្រភេទនេះ មានចម្លើយត្រឹមត្រូវតែមួយគត់ ហើយគេអាចហៅថាសំណួរទម្រង់បិទ។
- សំណួរតេស្តដែលមានចម្លើយជ្រើសរើស (Selected-Response Test Item)
  - សំណួរ ពហុជ្រើសរើស
  - សំណួរ ត្រូវ ឬខុស
  - សំណួរ ផ្គូរផ្គង
- សំណួរដែលមានចម្លើយសរសេរ (Constructed-Response Items)៖ ជាប្រភេទសំណួរ ដែលតម្រូវឱ្យសិស្សសរសេរចម្លើយដោយគំនិតផ្ទាល់ខ្លួន ដើម្បីឆ្លើយនឹងបញ្ហាដែលបានចោទឡើង។ ចម្លើយអាចខ្លី ឬវែងអាស្រ័យលើទំហំនៃបញ្ហា និងសមត្ថភាពឆ្លើយរបស់សិស្សម្នាក់ៗ។
  - សំណួរសរសេរទម្រង់ខ្លី
  - សំណួរសរសេរទម្រង់វែង

ក.៤- គុណសម្បត្តិ និងគុណវិបត្តិ ប្រភេទនៃសំណួរតេស្ត



## គុណសម្បត្តិ និងគុណវិបត្តិ ប្រភេទនៃសំណួរតេស្ត

| សំណួរដែលមានចម្លើយសរសេរ( Constructed-Response Items )៖ | | |
|---|---|---|
| ប្រភេទសំណួរ | គុណសម្បត្តិ | គុណវិបត្តិ |
| សំណួរសរសេរខ្លី | • ល្អសម្រាប់ការវាយតម្លៃលើចំណេះដឹងជាក់ស្តែង<br>• គ្មានការទស្សន៍ទាយចម្លើយ<br>• ងាយស្រួលក្នុងការបង្កើតសំណួរ<br>• ងាយស្រួលកែពិន្ទុ | • មិនសមស្របនឹងការវាស់វែងលើការសិក្សាបែបត្រិះរិះពិចារណា<br>• ងាយនឹងឆ្លើយចម្លើយតាមវិធីមិនសមស្រប |
| សំណួរសរសេរវែង | • ជាមធ្យោបាយមួយសម្រាប់វាយតម្លៃបំណិនកម្រិតខ្ពស់<br>• ជំរុញការគិតបែបច្នៃប្រឌិត និងត្រិះរិះពិចារណា ដូចនឹងការរៀននៅក្នុងថ្នាក់<br>• អាចវាស់វែង ការសិក្សាក្នុងវិស័យហឫទ័យ (Affective domain) | • ការកែចម្លើយ ត្រូវចំណាយពេលវេលា និងមានតម្លៃខ្ពស់<br>• ពិបាកនឹងទទួលបាន ភាពជឿជាក់រវាងអ្នកកែ និងអ្នកកែផ្សេងៗទៀត។ |

ក.៥- ទ្រឹស្តីប្លូម( Bloom )

កាលណាគេនិយាយពីការវាយតម្លៃ គេតែងតែនិយាយទាក់ទងទៅនឹងទ្រឹស្តីប្លូម។

ក.៥.១- តើទ្រឹស្តីប្លូមជាអ្វី?

- ទ្រឹស្តីប្លូមបង្កើតឡើងដោយអ្នកជំនាញអប់រំរបស់អាមេរិកឈ្មោះបែនជ្យាមិនប្លូម (Benjamin S. Bloom) និងសហការី ដើម្បីពន្យល់ពីចំណែកថ្នាក់វត្ថុបំណងនៃការអប់រំ
- ខាងវិទ្យាសាស្ត្រគេប្រើពាក្យចំណែកថ្នាក់សម្រាប់ចែកថ្នាក់រុក្ខជាតិ ឬសត្វតាមទំនាក់ទំនងធម្មជាតិ របស់វា
- ចំពោះវិស័យអប់រំ បានប្រើទ្រឹស្តីប្លូមនេះដើម្បីបែងចែកពីកម្រិតនៃការគិតរបស់សិស្សទៅតាម វត្ថុបំណងមេរៀន

- ចំណែកថ្នាក់នៃការគិតនេះចែកវត្ថុបំណងសិក្សាទាំងអស់ជាកម្រិតទៅតាមភាពពិបាកស្មុគស្មាញ ពីទាបទៅខ្ពស់។

ក.៥.២- ចំណែកថ្នាក់វត្ថុបំណងនៃការអប់រំ

- វិស័យពុទ្ធិ (Cognitive domain) ទាក់ទងនឹងសមត្ថភាពបញ្ញា
- វិស័យហឫទ័យ (Affective domain) ទាក់ទងនឹងចំណូលចិត្ត ឥរិយាបថ
- វិស័យចិត្តចលករ (Psychomotor domain) ទាក់ទងនឹងបំណិនចលករ។

ក.៥.ក- វិស័យពុទ្ធិបែងចែក៦កម្រិត ដែលយើងហៅថា ចំណែកថ្នាក់ប៊្លូម៖

- ការចងចាំ(Knowledge)៖មើលស្តាប់កត់ត្រាសូត្រទន្ទេញ រំឭក ប្រាប់ អានឡើងវិញ ចង្អុលប្រាប់ រាប់ ពិពណ៌នា ផ្ទៀងផ្ទាត់ ហៅឈ្មោះ...
- ការយល់ដឹង(Comprehension)៖ សួរ បកស្រាយ បង្ហាញ ពន្យល់ បំប្លែង ពិភាក្សា...
- ការអនុវត្ត(Application)៖ ដោះស្រាយ គណនា ជ្រើសរើស ពិសោធ ប៉ាន់ស្មាន កំណត់ សម្រួល ពន្លាត បង្ហាញ អនុវត្ត សង់ ដៅ រក ប្រើប្រាស់ បញ្ជាក់...
- ការវិភាគ(Analysis)៖ ប្រៀបធៀប បែងចែក វិភាគលម្អិត ចំណាត់ថ្នាក់ រៀបលំដាប់ ញែកឱ្យឃើញច្បាស់...
- ការវាយតម្លៃ (Evaluation)៖ ផ្តល់យោបល់ សម្រេចចិត្ត រិះគន់ ដាក់ពិន្ទុ សង្ខេប ថ្លឹងថ្លែង ទាញសេចក្តីសន្និដ្ឋាន
- ការបង្កើតថ្មី(Creation)៖ រចនា ផលិត រៀបគម្រោង រៀបរៀង បង្កើត ផ្សំបញ្ចូលគ្នា ច្នៃប្រឌិត ទាញជារូបមន្ត ទាញវិបាក...។




ក.៦- កម្រិតលំបាកនៃសំណួរតេស្ត

កម្រិតលំបាកនៃសំណួរតេស្ត៖

- សំណួរងាយ៖ សិស្សភាគច្រើនអាចឆ្លើយត្រូវ( 3/4 )
- សំណួរមធ្យម៖ សិស្សប្រហែលពាក់កណ្តាលឬតិចជាង អាចឆ្លើយបានត្រឹមត្រូវ
- សំណួរលំបាក៖ សិស្សប្រហែល1/4 (ឬតិចជាង ) ប៉ុណ្ណោះ អាចឆ្លើយបានត្រឹមត្រូវ

ក.៧- ការបង្កើតសំណួរតេស្តទម្រង់ពហុជ្រើសរើស

ការណែនាំការបង្កើតសំណួរតេស្តទម្រង់ពហុជ្រើសរើស៖

- សំណួរតេស្តពហុជ្រើសរើសដែលមានលក្ខណៈស្តង់ដា ផ្សំឡើងដោយពីរផ្នែកសំខាន់ៗ ដូចជាផ្នែកសំណួរ( Stem ) និងសំណុំជម្រើសចម្លើយ( Option )
- គេត្រូវសរសេរផ្នែកសំណួរ( Stem ) ជាប្រយោគសំណួរពេញលេញ

- សំណុំជម្រើសចម្លើយ (Option) ត្រូវមានចម្លើយត្រូវមួយ(Key answer) និងចម្លើយខុសបី (Distractor)។

**សំណួរតេស្ត (**Test Item)**៖**

- បង្កើតសំណួរតេស្តមួយសម្រាប់តែគោលបំណងតែមួយគត់
- បង្កើតសំណួរតេស្តនីមួយៗត្រូវមានភាពឯករាជ្យពីគ្នាមិនពាក់ព័ន្ធគ្នាពីសំណួរមួយទៅសំណួរមួយទៀត
- មិនត្រូវបង្កើតសំណួរតេស្តខុសនោះទេ
- បង្ហាញព័ត៌មាន ឬសម្មតិកម្មលើសនៅក្នុងសំណួរតេស្ត
- ជៀសវាងការដកយកសំណួរតេស្តទាំងស្រុងពីសៀវភៅសិក្សាគោល

**ផ្នែកសំណួរ (**Stem)**៖**

- បង្ហាញពីគំនិតសំខាន់នៃសំណួរឱ្យបានច្បាស់លាស់នៅក្នុងផ្នែកសំណួរ(Stem) ហើយគំនិតសំខាន់នៃសំណួរមិនត្រូវបង្ហាញនៅក្នុងជម្រើសចម្លើយ
- ពាក្យពេចន៍សរសេរនៅក្នុងផ្នែកសំណួរ(Stem)ត្រូវតែវិជ្ជមានហើយត្រូវតែជៀសវាងបែបវិជ្ជមាន

ជម្រើសចម្លើយបន្លំ **(**Distractor)**៖**

- ជម្រើសចម្លើយបន្លំទាំងបីនីមួយៗ ត្រូវបង្ហាញពីគំនិតភាន់ច្រលំលើខ្លឹមសារមេរៀន ឬចំណុចខ្វះខាតរបស់សិស្ស
- ត្រូវប្រើប្រាស់ជម្រើសចម្លើយដែលបន្លំល្អ (Plausible) និងអាចញែក ពីកម្រិតយល់ដឹងរបស់សិស្សបានល្អ (Discriminated)
- ធ្វើឱ្យប្រាកដថាក្នុងចំនោមជម្រើសចម្លើយទាំង ៤ ត្រូវមានចម្លើយត្រូវ ១
- តម្រៀបជម្រើសចម្លើយតាមលំដាប់លេខ ឬតាមលំដាប់អក្សរ

- ជម្រើសរើសចម្លើយទាំង៤ត្រូវមានលក្ខណៈឯករាជ្យពីគ្នាហើយខ្លឹមសារនៃជម្រើសចម្លើយមិនជាន់គ្នា
- ចម្លើយបន្លំ មិនបង្ហាញគន្លឹះដើម្បីឆ្លើយសំណួរដទៃទៀត
- ជៀសវាងជម្រើសចម្លើយមួយចំនួនដូចជា **ចម្លើយខាងលើទាំងអស់មិនត្រឹមត្រូវ ចម្លើយខាងលើទាំងអស់ត្រឹមត្រូវ** និង**ខ្ញុំមិនដឹងទេជាដើម**
- ពាក្យពេចន៍សរសេរនៅក្នុងជម្រើសចម្លើយត្រូវតែវិជ្ជមាន ហើយត្រូវតែជៀសវាងបែបអវិជ្ជមាន
- ជៀសវាងផ្តល់តម្រុយចម្លើយត្រឹមត្រូវដល់សិស្ស៖

  ធ្វើយ៉ាងណាឱ្យជម្រើសចម្លើយប្រវែងស្មើគ្នាជៀសវាងប្រើពាក្យ បង្ហាញពីកម្រិត ដូចជា **តែងតែ មិនដែល ពេញលេញ យ៉ាងប្រាកដ...**

  ជៀសវាង ជម្រើសចម្លើយដែលមានពាក្យពេជច៍ដូច ឬ ស្រដៀងនឹងប្រយោគ ឬ ពាក្យនៅក្នុងផ្នែកសំណួរ (Stem) រក្សាយ៉ាងណាឱ្យជម្រើសចម្លើយមានសង្គតភាពទាំងខ្លឹមសារ សំណង់ប្រយោគ និងវេយ្យាករណ៍ជម្រើសចម្លើយទាំងអស់ត្រូវតម្រៀបតាមទិសឈរជានិច្ច

  **ភាពបន្លំនៃជម្រើសចម្លើយ៖**

- ការប្រើប្រាស់ចម្លើយបន្លំ(ជម្រើសចម្លើយខុស) គឺផ្អែកលើគំនិតភាន់ច្រលំ ឬចំណុចខ្វះខាតរបស់សិស្ស
- ការរកឃើញគំនិតភាន់ច្រលំរបស់តាមរយៈជម្រើសចម្លើយបន្លំ គឺអាចឱ្យយើងកែលម្អការបង្រៀន និងកម្មវិធីសិក្សាជាដើម។

  -ប្រសិនអ្នកតាក់តែងសំណួរតេស្តមិនអាចសរសេរជម្រើសចម្លើយបន្លំដែលបង្កប់នូវគំនិតភាន់ច្រលំបាន តែធ្វើយ៉ាងណាឱ្យជម្រើសចម្លើយបន្លំនេះសមហេតុផលផង។

**ការវិភាគជម្រើសចម្លើយ៖**

-រាល់ជម្រើសចម្លើយទាំងអស់ត្រូវមានសេចក្តីពន្យល់អំពីចំណុចខ្វះខាតរបស់របស់សិស្ស។

ឧទាហរណ៍៖ សំបូរ កំពុងបើកបររថយន្តលើផ្លូវត្រង់។ គាត់ដាក់កែវទឹកមួយដូចរូបខាងក្រោមក្នុងរយន្ត។ ដោយសារមានឧបសគ្គនៅខាងមុខ ភ្លាមៗនោះ សំបូរ ចាប់ប្រាំងយ៉ាងខ្លាំង។

តើមានអ្វី កើតឡើងចំពោះទឹកនៅក្នុងកែវ?



ទិសដៅបើកបរ

☐ ក- ទឹកនឹងនៅស្ងៀមដដែល

☐ ខ- ទឹកនឹងកំពប់ចេញពីកែវ ត្រង់ទីតាំងទី1

☐ គ- ទឹកនឹងកំពប់ចេញពីកែវ ត្រង់ទីតាំងទី2

☐ ឃ- ទឹកនឹងកំពប់ចេញពីកែវ ប៉ុន្តែគេមិនអាចដឹងថា ទឹកកំពប់ចេញត្រង់ទីតាំងណាឡើយ

**ចម្លើយត្រឹមត្រូវ និងការវិភាគលើជម្រើសចម្លើយ៖**



ទិសដៅបើកបរ

☐ ក- សិស្សប្រហែលជាមិនបានសិក្សា ឬ មិនចេះទាំងស្រុង ពីច្បាប់និចលភាព។

☐ ខ- សិស្សអាចដឹងថាទឹកនឹងកំពប់ចេញពីកែវ ហើយវាយតម្លៃថានៅត្រង់ ទីតាំង ទី1។ នេះបង្ហាញថាសិស្សមិនទាន់យល់ច្បាស់លាស់ ឬនៅស្រពិចស្រពិលពីច្បាប់និចលភាព។

☐ គ- ចម្លើយត្រឹមត្រូវ។ ពីព្រោះទឹកក្នុងកែវចង់រក្សាល្បឿនឱ្យនៅដដែល។

☐ ឃ- សិស្សអាចដឹងថាទឹកនឹងកំពប់ចេញពីកែវ តែមិនហ៊ានវាយតម្លៃថានៅត្រង់ទីតាំងណាមួយឡើយ។ នេះបង្ហាញថាសិស្សមិនទាន់យល់ច្បាស់លាស់ពីច្បាប់និចលភាពនៅឡើ។

ទម្រង់សរសេរគំរូនៃសំណួរតេស្តពហុជ្រើសរើស

| | |
|---|---|
| - លេខកូដសំងាត់៖ | ប្រភព |
| - មុខវិជ្ជា៖ | -☐ សៀវភៅសិក្សាគោល |
| - ថ្នាក់ទី៖ | -☐ សៀវភៅគ្រូ |
| - សមត្ថភាព / មុខវិជ្ជារង៖ | -☐ អ្នកនិពន្ធ |
| - លទ្ធផលសិក្សា៖ | -☐ ស្តង់ដារកម្មវិធីសិក្សា |
| - កម្រិតពុទ្ធិ៖ | កម្រិតលំបាក |
| - ប្រភេទសំណួរ៖ | -☐ ងាយ |
| - រយៈពេល៖ | -☐ មធ្យម |
| - ពិន្ទុ៖ | -☐ លំបាក |

| | |
|---|---|
| **អត្ថបទ៖** | |
| **ប្រធាន៖** ......<br>☐ ក......<br>☐ ខ......<br>☐ គ......<br>☐ ឃ...... | |
| **ចម្លើយត្រឹមត្រូវ៖** ☑ ... | |
| ***ការវិភាគជម្រើសចម្លើយ៖***<br>☐ ក......<br>☐ ខ......<br>☐ គ......<br>☐ ឃ...... | |
| ឈ្មោះអ្នកនិពន្ធ៖ ...... | លេខទូរស័ព្ទ៖...... |

ឧទាហរណ៍១៖ តើផលបូក 185.55 + 25 ស្មើនឹងនឹងប៉ុន្មាន?

☐ ក- 185.80

☐ ខ- 100.55

☐ គ- 200.55

☐ **ឃ**- 210.55

**ចម្លើយបន្លំល្អ**(185.55 + 25 )

ក- 185.80 ( បូកខុសខ្ទង់ )

ខ- 100.55 ( ភ្លេចត្រាទុកខ្ទង់ដប់ និងខ្ទង់រយ )

គ- 200.55 ( ភ្លេចត្រាទុកខ្ទង់ដប់ )

ឃ- 210.55 ( ចម្លើយត្រឹមត្រូវ )

ឧទាហរណ៍២៖ សំណួរបន្លំល្អគ្រួសារសុខមានជ្រូក ៣ក្បាល ៣ពៃ ៧ក្បាល និងគោ ១៤ ក្បាល។ តើគ្រួសារសុខមានសត្វទាំងអស់ចំនួនប៉ុន្មានក្បាល?

ក- ២៤ ក្បាល

ខ- ២៣ ក្បាល

គ- ១៤ ក្បាល

ឃ- ១៣ ក្បាល

ចម្លើយត្រូវគឺចម្លើយ 'ក' ហើយចម្លើយបន្លំនីមួយៗត្រូវតែជាតំណាងឱ្យ កំហុសសមស្របដែលអាចកើតឡើងចំពោះសិស្ស។ សិស្សអាចជ្រើសយកជម្រើស 'គ' ប្រសិនបើគេភ្លេចត្រាទុក១ គេអាចជ្រើសយកជម្រើស 'ខ' ប្រសិនបើគេបូកខ្ទង់រាយដំបូងមិនត្រឹមត្រូវ (៣+៧+៤=១៣) ហើយគេអាចជ្រើសយកជម្រើស 'ឃ' ប្រសិនបើគេភ្លេចត្រាទុក និងបូកខ្ទង់រាយខុសទៀត។

ឧទាហរណ៍៣៖ សំណួរបន្លំមិនល្អគ្រួសារសុខមានជ្រូក៣ក្បាល ៣ពៃ៧ក្បាល និងគោ១៤ ក្បាល។ តើគ្រួសារសុខមានសត្វទាំងអស់ចំនួនប៉ុន្មានក្បាល?

ក- ២៤ ក្បាល

ខ- ម្ភៃបីក្បាល

គ- ដប់បួនក្បាល

ឃ- ដប់បីក្បាល (២៤មានទម្រង់ខុសគេ)ឬ

ក- ៦១២ ក្បាល

ខ- ២៤ ក្បាល

គ- ៣៩៩ ក្បាល

ឃ- ១,០១២ ក្បាល (កុមារអាចប្រើអព្ភន្តរញ្ញាណជ្រើសជម្រើស ខ)

ឧទាហរណ៍៤៖ សំណួរបន្លំមិនល្អ

ក- គ្រួសាររបស់សុខមានសត្វ១៤ក្បាល

ខ- គ្រួសាររបស់សុខមានសត្វ២៤ក្បាល

គ- គ្រួសាររបស់សុខមានសត្វ១៣ក្បាល

ឃ- គ្រួសាររបស់សុខមានសត្វ២៣ក្បាល

*ចម្លើយនេះ**វែងពេក** ហើយលេខ**មិនរៀបតាមលំដាប់**ចុះឬឡើងទេ។*

ឧទាហរណ៍៥៖

១- តើព្រះរាជាណាចក្រកម្ពុជាមានខេត្តជាប់សមុទ្រចំនួនប៉ុន្មាន?

ក- ពីរ

ខ- បី

គ- បួន

ឃ-ប្រាំ

២- តើខេត្ត**ទាំងបួន**នោះ ខេត្តមួយណាមានក្រឡាផ្ទៃធំជាងគេ?

*នេះជាសំណួរបង្ហាញចម្លើយសម្រាប់សំណួរខាងលើ*

ឧទាហរណ៍៦៖

តើចម្លើយខាងក្រោមមួយណាដែល*មិនពិត* ចំពោះលោក George Washington? (ប្រយោគបដិសេធ)

ក- គាត់ធ្វើជាប្រធានាធិបតីបាន២អាណត្តិ

ខ- គាត់ធ្លាប់ធ្វើជាមន្ត្រីយោធាមុនសង្គ្រាមបដិវត្តន៍

គ- គាត់កើតនៅឆ្នាំ១៧៣២

ឃ- គាត់គឺជាមនុស្សម្នាក់ដែលបានចុះហត្ថលេខាប្រកាសឯករាជ្យ

សំណួរនេះជាសំណួរបដិសេធដែលគួរចៀសវាងសម្រាប់ ការធ្វើតេស្តថ្នាក់ជាតិ ពីព្រោះ វានឹងសិស្សវឹវក់នឹងចម្លើយទាំងនោះ។ ឧទាហរណ៍៧៖

បញ្ជាក់ឱ្យបានច្បាស់ និងទុកឃ្លាសម្រាប់ឆ្លើយ៖

- ចូរគាក់តែងឃ្លាឱ្យបានពីរ ឬបីបន្ទាត់រៀបរាប់អំពីបឹងទន្លេសាប។ (មិនល្អ )
- ចូរផ្តល់មូលហេតុឱ្យបានបីរៀបរាប់ពីសារសំខាន់របស់បឹងទន្លេសាប ចំពោះសេដ្ឋកិច្ចជាតិ។ (ល្អជាង)

១- ....................................

២- ....................................

៣- ....................................

ឧទាហរណ៍៨៖

តើរូបនាឡិកាខាងក្រោមនេះ បង្ហាញម៉ោងប៉ុន្មាន?

ក- .............................

ខ- .............................

គ- .............................

ឃ- .............................




ក.៨- ការបង្កើតសំណួរតេស្តទម្រង់ទម្រង់បើក

ការណែនាំការបង្កើតសំណួរតេស្តទម្រង់បើក៖

១-សិស្សនឹងមិនអនុញាត្តិឱ្យសួរអនុរក្សតេស្តដើម្បីបញ្ជាក់ពីសំណួរតេស្តនេះទេដូចនេះអ្នកគាត់តែងសួរតេស្តត្រូវសរសេរដោយប្រើពាក្យសមស្របតាមកម្រិតថ្នាក់របស់សិស្ស។ ប្រើវាក្យស័ព្ទ និងទម្រង់ប្រយោគសាមញ្ញៗ ហើយប្រើប្រាស់ឈ្មោះពិបាកៗនៅក្នុងសំណួរតេស្ត។

២-សរសេរយ៉ាងណាឱ្យសិស្សយល់ច្បាស់ពីគោលបំណងសំណួរ។

ជាឧទាហរណ៍៖

-"សូមផ្តល់ហេតុផលចំនួនបី" ប្រសើរជាង "សូមផ្តល់ហេតុផលមួយចំនួន"

-"សូមគូសនៅលើដ្យាក្រាមដើម្បីបង្ហាញពីវដ្តទឹក" ប្រសើរជាង "តើពាក្យ វដ្តទឹក មានន័យដូចម្តេច?"

៣-ជៀសវាងសួរសំណួរណាដែលចម្លើយរបស់វាមិនអាចសរសេរចម្លើយ និងដាក់ពិន្ទុបាន។
៤-ត្រូវសរសេរចម្លើយនៃសំណួរតេស្តដោយបង្ហាញពីកម្រិតចំណេះដឹង និងបំណិនរបស់សិស្សពូកែ សង្ឃឹមធ្វើបាន។
៥-បង្កើតអត្រាកំណែសម្រាប់សំណួរទម្រង់បើក។អត្រាកំណែសម្រាប់សំណួរទម្រង់បើកៈ

- គោលបំណង និងខ្លឹមសារនៃសំណួរច្បាស់លាស់ (កម្មវិធីសិក្សាលម្អិត)
- លំនាំដោះស្រាយដែលអាចនាំទៅរកចម្លើយនៃសំណួរ
- ពិន្ទុដែលអាចដាក់បាន
- សេចក្តីពន្យល់នៃពិន្ទុនីមួយៗឱ្យបានច្បាស់(ងាយស្រួលក្នុងការវែកញែកពីកម្រិតយល់ដឹង និង កំហុសរបស់សិស្សបានងាយស្រួល)
- ឧទាហរណ៍នៃចម្លើយដែលអាចទទួលបានពិន្ទុ ឬចម្លើយមិនទទួលបានពិន្ទុ

| | | |
|---|---|---|
| - **លេខកូដលំហាត់៖** | | **ប្រភព** |
| - **មុខវិជ្ជា៖** | រូបវិទ្យា | -☐ សៀវភៅសិក្សាគោល |
| - **ថ្នាក់ទី៖** | ១១ | -☐ សៀវភៅគ្រូ |
| - **សមត្ថភាព / មុខវិជ្ជាផង៖** | | -☑ អ្នកនិពន្ធ |
| - **លទ្ធផលសិក្សា៖** | កម្លាំងចូលផ្ចិត | -☐ ស្តង់ដារកម្មវិធីសិក្សា |
| - **កម្រិតពុទ្ធិ៖** | វិភាគ | **កម្រិតលំបាក** |
| - **ប្រភេទសំណួរ៖** | ទម្រង់បើក | -☐ ងាយ |
| - **រយៈពេល៖** | 10 | -☐ មធ្យម |
| - **ពិន្ទុ៖** | 4 | -☑ លំបាក |

**ប្រធាន៖** ភពសុក្រ ក៏ដូចជាភពផែនដីដែរ វិលជុំវិញព្រះអាទិត្យ មានគន្លងជារង្វង់។ រវាងភពសុក្រ និងផែនដី គឺភពសុក្រនៅជិតព្រះអាទិត្យជាង។ ដោយប្រើប្រាស់ច្បាប់ទី២ ញូតុន និងច្បាប់ទំនាញសកល។ ចូរបង្ហាញថាភពសុក្រ ផ្លាស់ទីលឿនជាងផែនដី ក្នុងគន្លងដែលវិលជុំវិញព្រះអាទិត្យ។

ឧទាហរណ៍៖
ទម្រង់សរសេរគំរូនៃសំណួរតេស្តទម្រង់បើក

| | |
|---|---|
| - លេខកូដលំហាត់៖ | ប្រភព |
| - មុខវិជ្ជា៖ | -☐ សៀវភៅសិក្សាគោល |
| - ថ្នាក់ទី៖ | -☐ សៀវភៅគ្រូ |
| - សមត្ថភាព / មុខវិជ្ជារង៖ | -☐ អ្នកនិពន្ធ |
| - លទ្ធផលសិក្សា៖ | -☐ ស្តង់ដាកម្មវិធីសិក្សា |
| - កម្រិតពុទ្ធិ៖ | កម្រិតលំបាក |
| - ប្រភេទសំណួរ៖ | -☐ ងាយ |
| - រយៈពេល៖ | -☐ មធ្យម |
| - ពិន្ទុ៖ | -☐ លំបាក |

| | |
|---|---|
| **អត្ថបទ៖** | |
| **ប្រធាន៖** ........................................ | |
| **ចម្លើយ៖**<br>........................................<br>........................................ | |
| **អត្រាកំណែ**<br>**គោលបំណងនៃសំណួរ៖**<br>ការដាក់ពិន្ទុ – ០ ១ ២ ៣<br>ពិន្ទុ 3 ៖<br>ពិន្ទុ 2 ៖<br>ពិន្ទុ 1 ៖<br>ពិន្ទុ 0 ៖ | |
| ឈ្មោះអ្នកនិពន្ធ៖ ........................................ | លេខទូរស័ព្ទ៖.............................. |

## ខ-ការរៀបចំឯកសារតេស្ត

### ខ.១- ការធ្វើគម្រោងលម្អិតតេស្ត

គម្រោងលម្អិតតេស្ត គឺជារាងមួយដែលបានបង្ហាញពីខ្លឹមសារសំខាន់ៗមាន សៀវភៅសិក្សាគោល ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សា( លទ្ធផលសិក្សា ) ប្រភេទសំណួរ កម្រិតពុទ្ធិ( ប្លូម ) កម្រិតលំបាកពិន្ទុ រយៈពេលលេខកូដ។ដើម្បីបំពេញតារាងបានត្រឹមត្រូវអ្នកធ្វើកម្រងសំណួរតេស្តត្រូវសិក្សានិងឈ្វេងយល់ឱ្យបានច្បាស់ទៅចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សា លទ្ធផលសិក្សា
- សៀវភៅសិក្សាគោល
- ប្រភេទសំណួរ កម្រិតពុទ្ធិ( ប្លូម ) និងកម្រិតលំបាក

- ពិន្ទុ និងរយៈពេល

ខ.២- ការរៀបចំគម្រោងលម្អិតសំណួរតេស្ត

ការរៀបចំគម្រោងសំណួរតេស្តត្រូវពឹងផ្អែកទៅលើព័ត៌មាននៅក្នុងតារាងគម្រោងលម្អិតតេស្ត។ ខ្លឹមសារសំខាន់ៗនៃគម្រោងសំណួរតេស្តមាន លេខកូដលំហាត់ មុខវិជ្ជា ថ្នាក់ទី មុខវិជ្ជារង សៀវភៅសិស្ស សៀវភៅគ្រូ ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សា លទ្ធផលសិក្សា ប្រភេទសំណួរ កម្រិតពុទ្ធិ កម្រិតលំបាក រយៈពេល ពិន្ទុ ខ្លឹមសារសំណួរ ចម្លើយ ការវិភាគសំណួរនិងចម្លើយ អ្នកនិពន្ធ។ ដើម្បីគម្រោងសំណួរតេស្តបានត្រឹមត្រូវ អ្នកធ្វើកម្រងសំណួរតេស្តត្រូវសិក្សា និងឈ្វេងយល់ឱ្យបានច្បាស់ទៅចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖ ថ្នាក់ទី មុខវិជ្ជា មុខវិជ្ជារង ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សា លទ្ធផលសិក្សា សៀវភៅសិស្ស សៀវភៅគ្រូ ប្រភេទសំណួរ កម្រិត ពុទ្ធិ(ប្លូម) កម្រិតលំបាក ពិន្ទុ និងរយៈពេល ខ្លឹមសារសំណួរ និងចម្លើយការវិភាគសំណួរនិងចម្លើយ ។

ខ.៣- ការរៀបចំកម្រងសំណួរតេស្ត ការរៀបចំសំណួរតេស្ត ត្រូវយោងទៅតាមគម្រោងសំណួរតេស្ត។ កម្រងសំណួរតេស្តមានសម្រាប់សិស្សផង និងសម្រាប់អនុរក្សផង។ សំណួរតេស្ត (Item) ជាធាតុសំខាន់ជាងគេទាំងអស់សម្រាប់ដំណើរការ តេស្តទាំងមូល។ ប្រភេទសំណួរតេស្តមាន សំណួរទម្រង់បិទ និងសំណួរទម្រង់បើក។ បង្កើតសំណួរតេស្តមួយសម្រាប់តែគោលបំណងតែមួយគត់។ ជៀសវាងការដកយកសំណួរតេស្តទាំងស្រុងពីសៀវភៅសិក្សាគោល។ គេត្រូវសរសេរផ្នែកសំណួរ(Stem) ជាប្រយោគសំណួរពេញលេញ សំណួរតេស្តគួរចៀសវាង លក្ខណៈបញ្ឆោត កំប៉ិកកំប៉ុក ប្រើពាក្យ(វត្ថុ) ដែលកុមារនៅតំបន់ផ្សេងទៀតមិនអាចយល់, ឃ្លា-ប្រយោគវែង ស្មុគស្មាញ មិនត្រឹមត្រូវ មិនស៊ីសង្វាក់នឹងប្រធាន ប្រយោគបដិសេធ សំនួនវោហារ...។

សំណុំជម្រើសចម្លើយ (Option) ត្រូវមានចម្លើយត្រូវមួយ(Key answer) និងចម្លើយខុសបី (Distractor)។ ត្រូវប្រើប្រាស់ជម្រើសចម្លើយដែលបន្លំល្អ(Plausible) និងអាចញែកពីកម្រិតយល់

ដឹងរបស់សិស្សបានល្អ (Discriminated)។ ជម្រើសចម្លើយបន្លំទាំងបីនីមួយៗ ត្រូវបង្ហាញពីគំនិតភាន់ច្រលំលើខ្លឹមសារមេរៀន ឬចំណុចខ្វះខាតរបស់សិស្ស។ តម្រៀបជម្រើសចម្លើយតាមលំដាប់លេខ ឬតាមលំដាប់អក្សរ និងធ្វើឱ្យប្រាកដថាក្នុងចំនោមជម្រើសចម្លើយទាំង៤ នោះគឺមានចម្លើយត្រូវ ១។ ជៀសវាងជម្រើសចម្លើយមួយចំនួនដូចជា ចម្លើយខាងលើទាំងអស់មិនត្រឹមត្រូវ ចម្លើយខាងលើទាំងអស់ត្រឹមត្រូវ និងខ្ញុំមិនដឹងទេជាដើម។ ការប្រើប្រាស់ចម្លើយបន្លំ(ជម្រើសចម្លើយខុស) គឺផ្អែកលើគំនិតភាន់ច្រលំ ឬចំណុចខ្វះខាតរបស់សិស្ស។ ត្រូវបង្កើតអត្រាកំណែសម្រាប់សំណួរទម្រង់បើក។

គ- ការធ្វើតេស្តសាកល្បងជាមួយគ្រូបង្រៀន និងជាមួយជាសិស្ស

- ការធ្វើតេស្តសាកល្បងជាមួយគ្រូបង្រៀន : ក្រោយពីបានរៀបចំឧបករណ៍តេស្តរួចរាល់ហើយ ក្រុមការងារតេស្តត្រូវយកឧបករណ៍តេស្តនោះមកអនុវត្តសាកល្បងជាមួយគ្រូ។ ការសាកល្បងនេះមានគោលបំណងហ្វឹកហាត់ការអនុវត្តការធ្វើតេស្តឱ្យបានស្ទាត់ ដោយបែងចែកភារកិច្ចគ្នាមានអ្នកដើរតួជាសិស្ស និងអ្នកខ្លះទៀតដើរតួជាអនុរក្ស។ បន្ទាប់ពីធ្វើតេស្តសាកល្បងរួច ក្រុមការងារត្រូវប្រជុំពិភាក្សារកចំណុចល្អ ចំណុចខ្វះខាត និងផ្តល់យោបល់កែលម្អ។ ក្នុងដំណើការធ្វើតេស្តនេះ។

- ការធ្វើតេស្តសាកល្បងជាមួយសិស្ស : បន្ទាប់ពីអនុវត្តជាមួយគ្រូរួច ត្រូវការអនុវត្តជាមួសិស្សមួយចំនួន ដើម្បីឱ្យក្រុមការងារធ្វើតេស្តកាន់តែស្ទាត់ជំនាញ។ ក្នុងដំណើការធ្វើតេស្តសាកល្បងជាមួយសិស្សនេះ សូមធ្វើដូចគ្នានឹង ការធ្វើតេស្តសាកល្បងជាមួយគ្រូបង្រៀនដែរ។ បន្ទាប់ពីធ្វើតេស្តសាកល្បងរួច ក្រុមការងារត្រូវប្រជុំពិភាក្សារកចំណុចល្អ ចំណុចខ្វះខាត និងផ្តល់យោបល់កែលម្អ។

៤.២-ដំណើរការធ្វើតេស្ត

៤.២.១-ការរៀបចំគណៈកម្មការតេស្ត

-គណៈគ្រប់គ្រងសាលារៀន សហការជាមួយគ្រូបង្រៀនដើម្បីរៀបចំគណៈកម្មការតេស្តនិងដំណើការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងថ្នាក់ទី៧។ គណៈកម្មការនេះមានសមាសភាពចូលរួមមកពី

ការិយាល័យ អយក.ខ័ណ្ឌ/ក្រុង/ស្រុកក្រុមប្រឹក្សាឃុំ/សង្កាត់ ភូមិសហគមន៍អាជ្ញាធរមាតាបិតា គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន។ល។

- គណៈកម្មការតេស្តមាន គណៈកម្មការគ្រប់គ្រង គណៈកម្មការហិរញ្ញវត្ថុ គណៈកម្មការចេញវិញ្ញាសា គណៈកម្មការអនុរក្ស គណៈកម្មការកំណែ គណៈកម្មការសម្ភារៈបរិក្ខា គណៈកម្មការវិន័យ និងគណៈកម្មការផ្សព្វផ្សាយរៀបចំបែងចែកភារកិច្ចសម្រាប់គណៈកម្មការនីមួយៗ

៤.២.២- ដំណើរការធ្វើតេស្ត

ក- ការរៀបចំទីកន្លែង

- សាលារៀន : ប្រើប្រាស់សាលារៀនរៀងខ្លួន
- បន្ទប់: រៀបចំតុសិស្សចំនួន២៥តុ និងតុសម្រាប់អនុរក្ស១ ដោយសិស្សម្នាក់អង្គុយតុ១ ក្តារខៀន១
- លេខតុ:រៀបចំលេខតុតាមស្ថានភាពជាក់ស្តែងធ្វើយ៉ាងកុំឱ្យបេក្ខជនចម្លងគ្នាបាន អាចរៀបលេខតុជារាងអក្សរអ៊ុយ « ប » ឬ រាងអក្សរ « ណ » ។

ខ- ការរៀបចំសម្ភារៈបរិក្ខា

- រៀបចំបញ្ជីឈ្មោះសិស្ស
- រៀបចំដីស ហ្វឺត
- បញ្ជីពិន្ទុ
- សន្លឹកកិច្ចការសិស្ស
- សន្លឹកវិញ្ញាសា
- សេចក្តីប្រកាស សេចក្តីជូនដំណឹង ...

គ- ការរៀបចំគណៈកម្មការនិងបេក្ខជន

- រៀបចំគណៈកម្មការកណ្តាល

- អនុរក្ស : ក្នុង១បន្ទប់មានអនុរក្ស២នាក់

- បេក្ខជន : ក្នុង១បន្ទប់មានបេក្ខជន២៥នាក់

ឃ- ការរៀបចំគោលការណ៍ផ្សេងៗ

- រៀបចំបទបញ្ជាផ្ទៃក្នុង

- រៀបចំវិន័យ

- រៀបចំគោលការណ៍ផ្សេងៗ

៤.២.៣- ដំណើរការតេស្តសិស្ស

- អនុវត្តតាមលំនាំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

- អនុវត្តវិន័យ និងគោលការឱ្យបានរឹងរ៉ឹងបំផុត

៤.២.៤- ការកែដាក់ពិន្ទុ

- ពិភាក្សាធ្វើអត្រាកំណែ

- កែដាក់ពិន្ទុ

- ត្រួតពិនិត្យកំណែ

៤.៣- ការស្រង់ពិន្ទុ និងការធ្វើរបាយការណ៍

- ស្រង់ពិន្ទុសិស្សដាក់ក្នុងបញ្ជីពិន្ទុ និងធ្វើចំណាត់ថ្នាក់សិស្សទាំងអស់

- ធ្វើរបាយការណ៍បង្ហាញពីសមត្ថភាពសិស្សលើផ្នែកចំណេះដឹងមូលដ្ឋានគណិតវិទ្យាមានប្រមាណវិធីបូក ដក គុណ ចែក។ល។

៤.៤- ការផ្សព្វផ្សាយផ្សព្វផ្សាយរបាយការណ៍ និងបិទផ្សាយបញ្ជីពិន្ទុនៅតាម ក្នុងសាលារៀនខ្លួនសាលារៀនបឋមសិក្សាចំណុះ ភូមិ សាលាឃុំសង្កាត់ សាលាស្រុក បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា បញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងដៃគូរអភិវឌ្ឍន៍។

៤.៥- ការផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស និងមាតាបិតា

៤.៥.១-ការជួបជាមួយសិស្សដែលខ្សោយគណិតវិទ្យាជាងគេម្នាក់ម្តងៗគណៈគ្រប់គ្រងសាលាសហការជាមួយគ្រូបង្រៀនរៀបចំកម្មវិធីជួបជាមួយសិស្សពី៣ទៅ៤នាក់ ដែលខ្សោយគណិតវិទ្យាជាងគេ(ជួបម្នាក់ម្តងៗ) ដើម្បីពិភាក្សារកមូហេតុនៃការលំបាកនេះសម្រាប់រៀបចំផែនការជួយ និងដើម្បីលើកទឹកចិត្តពួកគេ។

៤.៥.២-ការជួបជាមួយសិស្សពិបាកគណិតវិទ្យាជាងគេម្នាក់ម្តងៗ រួមគ្នា គណៈគ្រប់គ្រងសាលាសហការជាមួយគ្រូបង្រៀន រៀបចំកម្មវិធីជួបជាមួយសិស្សពី៣ទៅ៤នាក់ ដែលខ្សោយគណិតវិទ្យាជាងគេ (ជួបរួមគ្នា) ដើម្បីពិភាក្សារកមូលហេតុនៃការលំបាកនេះសម្រាប់រៀបចំផែនការជួយ និងឱ្យពួកគេបង្ហាញពីតម្រូវការ និងសំណូមពរ។

៤.៥.៣-ជួបជាមួយមាតាបិតាដែលកូនពិបាកគណិតវិទ្យាដើម្បីសហការគ្នា ជួយពង្រឹង គណៈគ្រប់គ្រងសាលាសហការជាមួយគ្រូបង្រៀន រៀបចំកម្មវិធីជួបជាមួយ មាតាបិតាសិស្សដែលមានកូនពិបាកគណិតវិទ្យា ដើម្បីធ្វើការសហការគ្នារកវិធី ជួយពង្រឹងការរៀនគណិតវិទ្យារបស់សិស្សទាំងនោះនៅសាលារៀន និងនៅផ្ទះ។

## ៥-លទ្ធផលរំពឹងទុកនៃតេស្តចំណេះដឹងមូលដ្ឋានគណិតវិទ្យា

-កំណត់បានច្បាស់លាស់ពីអត្រាសិស្សចូលរៀនថ្នាក់ទី៧ខ្សោយផ្នែកចំណេះដឹងមូលដ្ឋានគណិតវិទ្យាមានប្រមាណវិធីបូកដកគុណនិងចែក ដែលជាមុខសញ្ញាសិស្សត្រូវធ្វើការជួយជាបន្ទាន់លើផ្នែកនេះ

-កំណត់បានច្បាស់លាស់ពីមុខសញ្ញាសិស្សចូលរៀនថ្នាក់ទី៧ ដែលចេះកម្រិតមធ្យម និងខ្ពស់ផ្នែកចំណេះដឹងមូលដ្ឋានគណិតវិទ្យា។

## ៦-សេចក្ដីសន្និដ្ឋាន

តាមរយៈការធ្វើតេស្តចំណេះដឹង មូលដ្ឋានគណិតវិទ្យាសម្រាប់សិស្សថ្នាក់ទី៦ឡើងថ្នាក់ទី៧ ដើមឆ្នាំសិក្សា គឺជាមធ្យាបាយដ៏មានប្រសិទ្ធភាពមួយក្នុងការជួយសិស្សរៀនយឺតបានទាន់ពេលវេលា ដែលរួមចំណែកកាត់បន្ថយការបោះបង់សិក្សា និងបង្កើនគុណភាពសិក្សារបស់សិស្ស។ (នាយកដ្ឋានចំណេះទូទៅ ២០២១)។

# ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រនៅក្នុងការជ្រើសរើសសំណាកដោយមានគោលបំណង ក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយផ្តោតលើតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថាភាគសំណាកនោះអាចផ្តល់ នូវទិន្នន័យបានជាក់ច្បាស់ និងត្រឹមត្រូវដែលអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទីតាំងភូមិសាស្ត្រនិងភាគសំណាកឧបករណ៍ស្រាវជ្រាវ ដំណើរការប្រមូលទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរប្រាំមួយប្រភេទតាមបែបបរិមាណវិស័យ ដោយបន្ស៊ីជាមួយសំណួរស្រាវជ្រាវទាំងប្រាំមួយ។ នៃប្រធានបទដែលលើកយកមកសិក្សា ស្របតាមគោលការនៃការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី ១៤ ខែវិច្ឆិកាឆ្នាំ២០២១ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យគឺធ្វើ នៅវិទ្យាល័យ កម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តព្រះសីហនុ និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមានប្រាំមួយប្រភេទគឺការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនគ្រូបង្រៀនមាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ។

## ៣.២ ការប្រមូលទិន្នន័យ

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេសជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមកអ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវមានការសហការល្អជាមួយជាមួយមន្ទីរអប់រំ ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលារៀន ដើម្បីចែករំលែកផ្សព្វផ្សាយកម្រងសំណួរ ទៅតាមការសិក្សាជ្រើសរើសចំនួន

សំណាកដែលបានគ្រោងទុក។ ក្នុងនោះអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួនប្រាំមួយប្រភេទគឺ (១)សម្រាប់ការិយាល័យអប់រំស្រុកយុវជននិងកីឡា (២)អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន (៣)សម្រាប់គណៈគ្រប់គ្រងសាលារៀន (៤)សម្រាប់គ្រូបង្រៀន (៥) សម្រាប់មាតាបិតាឬអាណាព្យាបាលសិស្ស (៦)សម្រាប់សិស្ស ហើយក្នុងមួយប្រភេទចែកចេញជាប្រាំផ្នែកគឺ (១)ព័ត៌មានទូទៅ (២) ដំណើរការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបច្ចេកទេស ការគ្រប់គ្រងថវិកា ការគ្រប់គ្រងបុគ្គលិក (៣) អំពីទំនាក់ទំនង (៤) ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា (៥) ផលជះ និងសំណូមពរ។

អ្នកស្រាវជ្រាវបានចុះទៅជួបការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន នាយកសាលារៀន នីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាតជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរដល់ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាឬអាណាព្យាបាលសិស្ស និងសិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិដោយបានកំណត់ពេលវេលាជាក់លាក់។ ដោយស្ថិតក្នុងបរិបទសម័យកូវីត-១៩ ការប្រមូលទិន្នន័យដោយបំពេញកម្រងសំណួរតាម Google Form (online) អ្នកសិក្សាស្រាវជ្រាវបានណែនាំឲ្យមានការរក្សាគម្លាតសង្គម និងធ្វើអនាម័យតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងការប្រមូលទិន្នន័យ គឺបានប្រើប្រាស់ពេលវេលាសរុបចំនួន៥ខែ គិតចាប់ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពី ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតាឬអាណាព្យាបាលសិស្ស សិស្សានុសិស្សកម្រិតមធ្យមសិក្សាបឋមភូមិ។

## ៣.៣ ឧបករស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួនប្រាំមួយ ប្រភេទគឺ (១)សម្រាប់ការិយាល័យអប់រំស្រុកយុវជន និងកីឡា (២)អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន (៣) សម្រាប់គណៈគ្រប់គ្រងសាលារៀន (៤)សម្រាប់គ្រូបង្រៀន

(៥) សម្រាប់មាតាបិតាឬអាណាព្យាបាលសិស្ស (៦)សម្រាប់សិស្ស ហើយក្នុងមួយប្រភេទចែកចេញជាប្រាំផ្នែកគឺ (១)ព័ត៌មានទូទៅ (២) ដំណើរការគ្រប់គ្រងសាលារៀន (៣) អំពីទំនាក់ទំនង (៤) ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា(៥) ផលជះ និងសំណូមពរ។ ក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគណៈការិយាល័យអប់រំស្រុកយុវជន និងកីឡា អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គ្រប់គ្រងសាលារៀនគ្រូបង្រៀន មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្ស កម្រិតមធ្យមសិក្សាបឋមភូមិ ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានាដូចជា គោលនយោបាយកំណែទម្រង់១៥ចំណុចដោយឈរលើសូចនាករចំនួន៩គឺស្តង់ដាសូចនាករ ៖

ស្តងដាទី១. សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សាសិស្ស

(ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ)

ស្តង់ដាសូចនាករ ស្តង់ដាទី២. ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងរៀននៃសិស្សម្នាក់ៗ

ស្តង់ដា សូចនាករ ស្តង់ដាទី៣. ភាពជាម្ចាស់នៃសាលារៀនសហគមន៍

ស្តង់ដា សូចនាករស្តង់ដាទី៤. ដំណើរប្រតិបត្តិការសាលារៀន

ស្តង់ដា សូចនាករ ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិការៀបចំតេស្តប្រឡងតេស្តជាការចូលរួមក្នុងធ្វើឲ្យវិស័យអប់រំសិស្សកាន់តែមានគុណភាព និងមានខិតខំរៀនសូត្របានល្អជាងមុនបន្ថែមទៀត។

### ៣.៤.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់កម្រងសំណួរ ដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញអាចបំពេញដោយគូសផ្ទាល់នៅលើកម្រិតសំណួរ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។

ការវាយតម្លៃស្ថានភាពនៃផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ក្នុងខេត្តព្រះសីហនុ។ តួលេខចង្អុកបង្ហាញតាមបែបលោកLikert Scale(1981) គឺគេនិយមចូលចិត្តប្រើច្រើនលើនិក្ខេបបទ

ស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺគេប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃទៅលើកម្រិតការអនុវត្ត និងដំណើការនៃការបំពេញការងាររបស់ ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន មាតាបិតាឬអាណាព្យាសិស្ស គ្រូបង្រៀន សិស្ស ។

ក្នុងការស្រាវជ្រាវនេះកម្រិតចង្អុលបង្ហាញ នៃកម្រងសំណួរមាន៥កម្រិតពីទាបបំផុត( ១ )ទៅខ្ពស់បំផុតទៅខ្ពស់បំផុត( ៥ )រូបមន្តអង្គុលបង្ហាញមានដូចខាងក្រោម៖

| បរិយាយកម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|
| មិនស្រាបទាល់តែសោះ | មិនយល់ស្រប | ពុំមានយោបល់ | យល់ស្រប | យល់ស្របខ្លាំង |
| ១ | ២ | ៣ | ៤ | ៥ |

ការបកស្រាយលើការគណនាពិន្ទុពីការប្រមូលទិន្នន័យដើម្បីវិភាគលើពិន្ទុមធ្យមនៃសូចនាករនីមួយគឺមានរូបមន្តដូចខាងក្រោម( Best,1981 )៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{៥ - ១}{៥} = \frac{៤}{៥} = 0.៨$$

| អត្ថន័យកម្រិតអង្គុលបង្ហាញ | | | | |
|---|---|---|---|---|
| ខ្សោយខ្លាំង | ខ្សោយ | មធ្យម | ល្អ | ល្អណាស់ |
| ១.០០-១.៨០ | ១.៨១-២.៦០ | ២.៦១-៣.៤០ | ៣.៤១-៤.២០ | ៤.២១-៥.០០ |

( Best,1981 ) ដោយបង្ហាញលទ្ធផលដូចខាងក្រោម៖

ម៉្យាងទៀត នេះជាវិភាគផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ក្នុងខេត្តព្រះសីហនុការិយាល័យអប់រំយុវជននិងកីឡា អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតារឺអាណាព្យាសិស្ស សិស្ស និងភាគីពាក់ព័ន្ធផ្សេងទៀត ផលជះនៃការ

ធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧សាលារៀន នៅមធ្យមសិក្សាបឋមភូមិ ដោយប្រើតម្លៃមធ្យមភាគ(Mean) និងគម្លាតស្តង់ដា (Standard Deviation)។

### ៣.៤.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បី (១) ស្វែងយល់ពីកម្រិតនៃការអនុវត្តសិក្សាពីកម្រិតដំណើការដឹកនាំ គ្រប់គ្រង បង្រៀន និងរៀនសម្រាប់អនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧បាន នឹងឯកសារគតិយុត្តនៃការរៀបចំតេស្ត សាលារៀននៅមធ្យមសិក្សាបឋមភូមិ (២) រកឱ្យឃើញពីកត្តានានាដែលជាផលជះនៃការធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាដល់សិស្សថ្នាក់ទី៦ដើម្បីអាចរៀនថ្នាក់ទី៧បាន។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះប៉ុណ្ណោះ។

### ៣.៤.៣ កម្រងសំណួរសម្រាប់ការិយាល័យអប់រំយុវជននិងកីឡាស្រុក

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់ការិយាល័យអប់រំស្រុក ចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) តួនាទី ។ ផ្នែកទី២ ដំណើរការគ្រប់គ្រងការិយាល័យអប់រំស្រុក ដែលបែងចែកជា៤ចំណុចសំខាន់ៗ (ក) ផ្នែកការគ្រប់គ្រងរដ្ឋបាល (ខ) ផ្នែកការគ្រប់គ្រងបច្ចេកទេស(គ) ផ្នែកការគ្រប់គ្រងថវិកា (ឃ)ផ្នែកគ្រប់គ្រងបុគ្គលិក។ផ្នែកទី៣ការគ្រប់គ្រងបុគ្គលិកនៅកម្រិតសាលារៀន។ផ្នែកទី៤ អំពីការទំនាក់ទំនង អាជ្ញាធរដែនដីនិងសហគមន៍និងសាលារៀន។ផ្នែកទី៥ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧នៅកម្រិតសាលារៀន។

### ៣.៤.៤ កម្រងសំណួរសម្រាប់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) តួនាទី។ ផ្នែកទី២ ដំណើរការគ្រប់គ្រងអាជ្ញា

ធម៌ដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលបែងចែកជា៤ចំណុចសំខាន់ៗ (ក) ផ្នែកការគ្រប់គ្រងរដ្ឋបាល (ខ) ផ្នែកការគ្រប់គ្រងបច្ចេកទេស(គ) ផ្នែកការគ្រប់គ្រងថវិកា (ឃ)ផ្នែកគ្រប់គ្រងបុគ្គលិក។ផ្នែកទី៣ការគ្រប់គ្រងបុគ្គលិកនៅកម្រិតសាលារៀន។ផ្នែកទី៤ អំពីការទំនាក់ទំនង សហគមន៍ និងសាលា រៀន។ ផ្នែកទី៥ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧នៅកម្រិតសាលារៀន។

### ៣.៤.៥ កម្រងសំណួរសម្រាប់ គណៈគ្រប់គ្រងសាលារៀន

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀនចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) តួនាទី ។ ផ្នែកទី២ ដំណើរការអភិវឌ្ឍសាលារៀនចែកជា២ចំណុចសំខាន់ៗ (ក) ការចូលរួមផែនការអភិវឌ្ឍសាលារៀន (ខ)កៀរគរកម្មវិធីផ្សេងៗ ។ផ្នែកទី៣ អំពីការទំនាក់ទំនងសហគមន៍ និងសាលារៀន។ផ្នែកទី៤ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះ នៃការធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងទី៧ នៅកម្រិតសាលារៀន។

### ៣.៤.៦ កម្រងសំណួរសម្រាប់ គ្រូបង្រៀន

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់គ្រូបង្រៀនចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) បទពិសោធន៍ ។ ផ្នែកទី២ អំពីការបង្រៀន ដែលបែងចែកជា២ចំណុចសំខាន់ៗ (ក) ការបង្រៀន (ខ) ការលើកទឹកចិត្តនៅសាលារៀន ។ ផ្នែកទី៣ការទំនាក់ទំនងសាលារៀននិងសហគមន៍ ។ ផ្នែកទី៤ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧នៅកម្រិតសាលារៀន។

### ៣.៤.៧ កម្រងសំណួរសម្រាប់ មាតាបិតាអាណាព្យាបាលសិស្ស

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់មាតាបិតាអ្នកអាណាព្យាបាលសិស្សចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) តួនាទី ។ ផ្នែកទី២ ការតាមដានការសិក្សាសិស្ស ដែលបែងចែកជា៣ចំណុចសំខាន់ៗ (ក) ការតាមដានការសិក្សាកូន (ខ) ការផ្តល់ថវិកាសិក្សាសម្រាប់កូន(គ)ការទំនាក់ទងសាលារៀន ។ ផ្នែកទី៣ការទំនាក់ទនងនៅកម្រិតសាលារៀន។ផ្នែកទី៤ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧នៅកម្រិតសាលារៀន។

### ៣.៤.៨ កម្រងសំណួរសម្រាប់ សិស្សានុសិស្ស

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៥ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់សិស្សានុសិស្សចែកចេញជា៥ចំណុចគឺ (១) ឈ្មោះ (២) ភេទ (៣) អាយុ (៤) កម្រិតវប្បធម៌ (៥) តួនាទី ។ ផ្នែកទី២ អំពីការសិក្សាផ្ទាល់ខ្លួន ដែលបែងចែកជា៤ចំណុចសំខាន់ៗ (ក) កត្តាសិក្សាសិស្ស (ខ) កត្តាលើកទឹកចិត្តចំពោះគ្រូមកលើសិស្ស(គ) កត្តាលើទឹកចិត្តមាតាបិតាមកលើសិស្ស (ឃ)កត្តាលើកទឹកចិត្តពីមិត្តភ័ក្រ។ ផ្នែកទី៣ទំនាក់ទំនង។ផ្នែកទី៤៖ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា។ ផ្នែកទី៥៖ផលជះនៃការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧នៅកម្រិតសាលារៀន។

### ៣.៤.៩ ការជ្រើសរើសសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់វិធិសាស្រ្តក្នុងការជ្រើសរើសសំណាកតាមគោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅតែភាគសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យដែលអាចទុកចិត្តបាននោះមានបួនប្រភេទរួមមាន៖ ការិយាល័យអប់រំស្រុកចំនួន៦នាក់ អាជ្ញាធ

ដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនចំនួន៤៥នាក់ គណៈនាយលមានចំនួន៨នាក់ គ្រូបង្រៀនចំនួន៤០នាក់ និងអាណាព្យាបាលសិស្សចំនួន៦១នាក់ សិស្សានុសិស្សកម្រិតបឋមភូមិពីថ្នាក់ទី៧ចំនួន៦០នាក់ ក្នុងឆ្នាំសិក្សា២០២០-២០២១ ។

**ក្រុមគោលដៅទី១៖** គឺប្រធានការិយាល័យ(ប្រធាន) ឬអនុប្រធានការិយាល័យ(អនុប្រធាន) បំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើសប្រធានការិយាល័យ ឬអនុប្រធានការិយាល័យក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះពីព្រោះតែពួកគាត់ជាអ្នកដឹកនាំគ្រប់គ្រង និងអនុវត្តដោយផ្ទាល់ ច្បាស់ណាស់ពួកគាត់ប្រាកដជាផ្តល់ព័ត៌មានបានល្អប្រសើរ។

**ក្រុមគោលដៅទី២៖** គឺប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន(ប្រធាន) ឬអនុប្រធាន (អនុប្រធាន) សមាជិកនៅក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន បំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើសប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន ឬអនុប្រធាន សមាជិកនៅក្នុងគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះពីព្រោះតែពួកគាត់ជាអ្នកដឹកនាំគ្រប់គ្រង និងអនុវត្តដោយផ្ទាល់ ច្បាស់ណាស់ពួកគាត់ប្រាកដជាផ្តល់ព័ត៌មានបានល្អប្រសើរ។

**ក្រុមគោលដៅទី៣៖** គឺលោកនាយក(រង) ឬនាយិកា(រង) បំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើសនាយក(រង) ឬនាយិកា(រង)ក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះពីព្រោះតែពួកគាត់ជាអ្នកគ្រប់គ្រង និងអនុវត្តដោយផ្ទាល់ ច្បាស់ណាស់ពួកគាត់ប្រាកដជាផ្តល់ព័ត៌មានបានល្អប្រសើរ។

**ក្រុមគោលដៅទី៤៖** ការសម្ភាសន៍ជាកម្រងសំណួរគ្រូបង្រៀនបំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើស គ្រូបង្រៀនក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះ ពីព្រោះពួកគាត់ក៏ជាដែលអាចផ្តល់ព័ត៌មានទូទៅស្តីពីការការបង្រៀនផ្ទាល់នៅក្នុងសាលារៀនជាមួយសិស្សានុស្ស ជាអ្នកសង្កេត ពិនិត្យ ណែនាំ និងចូលរួមអនុវត្តការងារជាមួយនឹងគណៈគ្រប់គ្រងសាលារៀនផងដែរ។

**ក្រុមគោលដៅទី៥៖** ការសម្ភាសន៍ និងឲ្យអ្នកអាណាព្យាបាលសិស្សបំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើស អ្នកអាណាព្យាបាលសិស្សក្នុងការផ្ដល់ព័ត៌មានក្នុងការស្រាវជ្រាវនេះ ពីព្រោះពួកគាត់ក៏ជាដែលអាចផ្ដល់ព័ត៌មានទូ ទៅស្ដីពីការសិក្សារបស់សិស្សដែលជាកូនរបស់គាត់បានសិក្សានៅសាលារៀនរបស់នាយកសាលា គ្រូបង្រៀន ជាពិសេសអ្នកអាណាព្យាបាលសិស្សគឺជាអ្នកសង្កេត ពិនិត្យ ណែនាំ និងចូលរួមអនុវត្តការងារជាមួយនឹងគណៈគ្រប់គ្រងសាលារៀនផងដែរ។

**ក្រុមគោលដៅទី៦៖** គឺជ្រើសរើសយកសិស្សចំនួន៦០នាក់ មកធ្វើជាសំណាកបំពេញកម្រងសំណួរ ព្រោះតែពួកគាត់ជាអ្នកទទួលផលប្រយោជន៍ និងអនុវត្តផ្ទាល់។ ហេតុដូច្នេះពួកគាត់ប្រាកដជាអាចផ្ដល់ព័ត៌មានបន្ថែមទាក់ទងទៅ នឹងប្រធានបទនេះបានគ្រប់ជ្រុងជ្រោយសម្រាប់ឲ្យអ្នកសិក្សាស្រាវជ្រាវយកមកធ្វើការវិភាគ។

| ល.រ | ឈ្មោះសាលា | ស្រុក | ការិយាល័យអប់រំស្រុក | អាជ្ញាធរដែនដី | គណៈគ្រប់គ្រងសាលា | គ្រូ | សហគមន៍ | សិស្ស | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| **១** | វិ.ហស វាលរេញ | ព្រៃនប់ | ៤ | ១៤ | ២ | ១៧ | ៣០ | ២១ | ៨៨ |
| **២** | វិ.ហស ព្រៃនប់ | ព្រៃនប់ | ០ | ១៤ | ៣ | ១១ | ១៨ | ២១ | ៦៧ |
| **៣** | វិ.ស្ទឹងហាវ | ស្ទឹងហាវ | ២ | ១២ | ៣ | ១៧ | ១៣ | ១៨ | ៦៥ |
| | **សរុប** | | **៦** | **៤០** | **៨** | **៤៥** | **៦១** | **៦០** | **២២០** |

តារាងទី១ (ក្រុមគោលដៅក្នុងការប្រមូលសំណាក)

## ៣.៤.១០ ការវិភាគទិន្នន័យ

ការស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើវិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទភាគសំណាកនីមួយៗ(ការិយាល័យអប់រំស្រុក អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកអាណាព្យាបាលសិស្ស និងសិស្ស)។ បន្ទប់មកអ្នកសិក្សាស្រាវជ្រាវ សំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅការដំណើការដឹកនាំគ្រប់គ្រងផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាដើម្បីបានចូលរៀនថ្នាក់ទី៧ថ្មី ។ ដើម្បីឆ្លើយតបនឹងចំណុចទាំងនេះ អ្នកសិក្សាស្រាវជ្រាវប្រាស់ប្រាស់កម្មវិធី Microsoft Excel សម្រាប់ស្វែងរកមធ្យម និងគម្លាតស្តង់ដា សម្រាប់ក្រាប និងសង់តារាង និងការពន្យល់បកស្រាយ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានលើកជាសំណួរ ចំពោះចំណុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឲ្យបានប្រសើរឡើង។

## ៣.៤.១១ ក្រមសីលធម៌នៃសិក្សាស្រាវជ្រាវ

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំ នៃវិទ្យាស្ថានជាតិអប់រំ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឲ្យចុះប្រមូលទិន្នន័យស្តីពីដំណើការផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ឡើងទី៧ថ្មី នៅកម្រិតមធ្យមសិក្សាបឋមភូមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រះសីហនុ រួចមកអ្នកសិក្សាស្រាវជ្រាវបានយកលិខិតនេះ មកប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ ដើម្បីសុំការអនុញ្ញាត ដែលនេះជាក្រមសីលធម៌មួយសម្រាប់ការសិក្សាស្រាវជ្រាវនៅក្នុងសាលាដែលស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ និងជាការបង្ហាញពីការគោរពតាម ឋានានុក្រមថ្នាក់ដឹកនាំផងដែរ។ អ្នកស្រាវជ្រាវមិនត្រូវបានបង្ហាញពីឈ្មោះអ្នកដែលខ្លួនបានប្រមូលព័ត៌មាននោះទេ ជាពិសេសនូវរាល់ចំណុចដែលអវិជ្ជមានចំពោះអ្នកដែលបានឆ្លើយសំណួរស្រាវជ្រាវ ព្រោះវាជាកត្តាមួយធ្វើឲ្យមានការធ្លាក់ទឹកចិត្តរឺមានការបារម្ម

ណ៍មិនល្អក្នុងការបំពេញការងារនោះទេរឹបង្ករការភ័យខ្លាចដល់អង្គភាពនោះឡើយ។ គ្រាន់តែការផ្តល់នូវពត៌មានពិតសម្រាប់សិក្សាវិភាគរកចំណុចវិជ្ជមាន និងអវិជ្ជមានហើយចំណុចទាំងនោះយកទៅកែលម្អកាន់តែមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងដឹកនាំវិស័យអប់រំនៅកម្រិតសាលារៀនកាន់តែល្អ។

# ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

# ជំពូក៤
# លទ្ធផល និងពិភាក្សា

នៅក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញ តាមរយៈកម្រងសំណួរដែលបានបំពេញដោយការិយាល័យអប់រំយុវជននិងកីឡាស្រុក គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរដែនដី គណៈនាយក លោកគ្រូ អ្នកគ្រូ មាតាបិតាឬអាណាព្យាបាលសិស្ស សិស្សានុសិស្ស ។ ចំណុចសំខាន់មួយចំនួនដែលពាក់ព័ន្ធការចូលរួមរបស់សហគមន៍ក្នុងការលើក កម្ពស់លទ្ធផលសិក្សារបស់សិស្ស នៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តព្រះសីហនុ នឹងត្រូវយកមកវិភាគ បកស្រាយ និងពិភាក្សា។

## ៤.១. ឧបករណ៍វិភាគទិន្នន័យ

ដើម្បីវិភាគទិន្នន័យ អ្នកស្រាវជ្រាវបានប្រើកម្មវិធីMicrosoft Excel ។ កម្មវិធី Microsoft Excel ត្រូវបានប្រើប្រាស់ដើម្បីស្វែងរក កម្រិតនៃការចូលរួមរបស់ ការិយាល័យអប់រំយុវជន និងកីឡាស្រុក គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរដែនដី គណៈ នាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្ស តាមរយៈកម្រងសំណួរ ដោយ គិតជាតម្លៃមធ្យម ( Mean ) គម្លាតស្តង់ដារ ចំនួនភាគរយ និងសង់ជាក្រាបផ្សេងៗ។

## ៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាម រយៈការបំពេញកម្រងសំណួរ។ ការវិភាគកម្រងសំណួរសម្រាប់ការិយាល័យអប់រំយុវជននិងកីឡាស្រុក គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរដែនដី គណៈនាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្ស មានគោលបំណងស្វែងរកឱ្យឃើញពីកម្រិតនៃការចូលរួមរបស់ពួកគាត់ ក្នុងការលើកកម្ពស់លទ្ធផលសិក្សា របស់សិស្ស ថាតើពួកគាត់បានចូលរួមក្នុង

កម្រិតណា មានបញ្ហាប្រឈមអ្វីខ្លះក្នុងការចូលរួមរបស់ពួកគាត់ ព្រមទាំងមានទស្សនៈ និងផលជះសំណូមពរបែបណាចំពោះការអប់រំ។

## ៤.៣. លទ្ធផលនៃការវិភាគទិន្នន័យ

ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធ ដូចមានបង្ហាញខាងលើគឺការិយាល័យអប់រំយុវជននិងកីឡាស្រុក គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរដែនដី គណៈនាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្ស នឹងត្រូវ បានលើកមកធ្វើការវិភាគម្តងមួយៗទៅតាមលំដាប់។ ដំបូងគឺអ្នកសិក្សាស្រាវជ្រាវវិភាគលើ កម្រងសំណួរ សម្រាប់ ការិយាល័យអប់រំយុវជននិងកីឡាស្រុក គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរដែនដី គណៈនាយក លោកគ្រូ អ្នកគ្រូ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស សិស្សានុសិស្ស ។

## ៤.៤ ការវិភាគទិន្នន័យសម្រាប់ការិយាល័យអប់រំយុវជននិងកីឡាស្រុក

### ផ្នែកទី១ ពត៌មានទូទៅ

**១.ភេទ**

| ល.រ | ភេទ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | សរុបភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ការិយាល័យអប់រំស្រុក | ៤ | ៦០% | ២ | ៤០% | ៦ | ១០០% |
| សរុប | | ៤ | ៦០% | ២ | ៤០% | ៦ | ១០០% |

រូបភាពទី២ ៖ ភេទ (ការិយាល័យអប់រំស្រុក)

ការិយាល័យអប់រំស្រុកបានចូលរួមបានចូលរួមក្នុងកម្រងសំណួរទាំងអស់គ្នាមានចំនួន៦នាក់។ ការិយាល័យអប់រំស្រុកដែលមានភេទមានភាគរយខ្ពស់ជាង60% ចំណែកការិយាល័យអប់រំស្រុកជាស្ត្រីមានចំនួន40%។ តាមរយៈតារាងខាងលើ យើងអាសន្និដ្ឋានបានថាការិយាល័យអប់រំស្រុកភាគច្រើនជាបុរស។

**ផ្នែកទី២ (ការិយាល័យអប់រំស្រុក)**

**២.អាយុ**

| ល.រ | អាយុ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | សរុបរួមភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ២០ទៅ៣០ឆ្នាំ | 0 | 0 | ១ | ១៦.៦០ | ១ | ១៦.៦0% |
| ២ | ៣១ទៅ៤០ឆ្នាំ | 0 | 0 | 0 | 0 | 0 | 00% |
| ៣ | ៤១ទៅ៥០ឆ្នាំ | ៤ | ៦៦.៦០ | ១ | ១៦.៦០ | ៥ | ៨៣.៣0% |
| ៤ | ៥១ឆ្នាំឡើង | 0 | 0 | 0 | 0 | 0 | 00% |
| សរុប | | ៤ | ៦៦.៦០ | ២ | ៣៣.២០ | ៦ | 100% |

រូបភាពទី២៖ អាយុ(ការិយាល័យអប់រំស្រុក)

ក្នុងចំណោមការិយាល័យអប់រំស្រុក ដែលបានចូលរួមបំពេញកម្រងសំណួរតាមកម្រិតអាយុផ្សេងៗគ្នា។ ការិយាល័យអប់រំស្រុកដែលមានចន្លោះអាយុពី២០ទៅ៣០ឆ្នាំ ភេទជាស្ត្រីមានភាគរយ ៣៣.២០%និងមានចន្លោះអាយុ៤១ទៅ៥០ឆ្នាំជាបុរស៦៦.៦០%។ តាមតារាងខាងលើយើងអាចសន្និដ្ឋានបានថាការិយាល័យអប់រំស្រុកភាគច្រើនមានអាយុចាប់ពី៤១ទៅ៥០ឆ្នាំ គឺជាក្រុមមនុស្សដែលមានសក្តានុពលសម្រាប់ការចូលរួមធ្វើឲ្យវិស័យអប់រំមានការអភិវឌ្ឍនកាន់តែរីកចម្រើននិងមានប្រសិទ្ធភាព។

**ផ្នែកទី៣ កម្រិតវប្បធម៌**

| ល.រ | កម្រិតវប្បធម៌ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ក្រោមបរិញ្ញាបត្រ | 0 | ១ | ១ | ១៦.៧0% |
| ២ | បរិញ្ញាបត្រ | ១ | ១ | ២ | ៣៣.៣0% |
| ៣ | បរិញ្ញាបត្រជាន់ខ្ពស់ | ៣ | 0 | ៣ | ៥0% |
| ៤ | បណ្ឌិត | 0 | 0 | 0 | 0 |
| សរុប | | ៤ | ២ | ៦ | 100% |

រូបភាពទី៣៖ កម្រិតវប្បធម៌(ការិយាល័យអប់រំស្រុក)

ក្នុងចំណោមការិយាល័យអប់រំស្រុក ដែលបានចូលរួមបំពេញកម្រងសំនួរទាំងអស់មានមានកម្រិតវប្បធម៌។ ការិយាល័យអប់រំស្រុកមានក្រោមបរិញ្ញាបត្រស្រីចំនួន១នាក់ស្មើចំនួន១៦.៧០%និងបរិញ្ញាបត្រចំនួន២នាក់បុរស១នាក់និងស្រីចំនួន១នាក់ស្មើ៣៣.៣០%។ ការិយាល័យអប់រំស្រុកមាន

បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន៣នាក់ជាបុរសស្មើនិងចំនួន៥០%។ តាមរយៈតារាងខាងលើយើងអាច សន្និដ្ឋានបានថាកម្រិតវប្បធម៌របស់ការិយាល័យអប់រំស្រុក មានបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់។

**ផ្នែកទី៤ តួនាទី**

| ល.រ | តួនាទី | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ប្រធានការិយាល័យ | ១ | ១ | ២ | ៣៣.៣០% |
| ២ | អនុប្រធានការិល័យ | ៣ | ១ | ៤ | ៦៦.៧០% |
| សរុប | | ៤ | ២ | ៦ | 100% |

រូបភាពទី៤៖តួនាទី(ការិយាល័យអប់រំស្រុក)

ក្នុងចំណោមតួនាទីការិយាល័យអប់រំស្រុកដែលបានចូលរួមបំពេញកម្រងសំនួរមានប្រធានការិ យាល័យចំនួន២នាក់ស្មើចំនួន៣៣.៣០%។ អនុប្រធានការិយាមានការចូលរួមចំនួន៣នាក់និងស្រី ដែល មានចំនួន៤នាក់ស្មើចំនួន៦៦.៧០%។ តាមរយៈតារាងខាងលើយើងអាចសន្និដ្ឋានបានថាអនុ ប្រធានការិយាល័យមានចំនួនច្រើន។

**ផ្នែកទី៥ បទពិសោធន៍ការងារ**

| ល.រ | បទពិសោធន៍ការងារ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ក្រោម៥ឆ្នាំ | ០ | ១ | ១ | ១៦.៧០% |
| ២ | ៥ឆ្នាំទៅ៩ឆ្នាំ | ០ | ១ | ១ | ១៦.៧០% |
| ៣ | ១០ឆ្នាំទៅ១៤ឆ្នាំ | ០ | ០ | ០ | ០០% |
| ៤ | ១៥ឆ្នាំទៅ១៩ឆ្នាំ | ២ | ០ | ២ | ៣៣.៣០% |
| ៥ | ២០ឆ្នាំឡើងទៅ | ២ | ០ | ២ | ៣៣.៣០% |
| សរុប | | ៤ | ២ | ៦ | 100% |

តារាងទី៥ ៖ បទពិសោធន៍ការងារ(ការិយាល័យអប់រំស្រុក)

ក្នុងចំណោម ការិយាល័យអប់រំស្រុកដែលមានបទពិសោធន៍ការងារក្រោម៥ឆ្នាំមានចំនួន១ នាក់ស្រីស្មើ១៦.៧០%។ ការិយាល័យអប់រំស្រុកដែលមានបទពិសោធន៍ការងារ៥ឆ្នាំទៅ៩ឆ្នាំមានចំនួន

១នាក់ស្រីស្មើនឹង១៦.៧០%។ ការិយាល័យអប់រំស្រុកដែលមានបទពិសោធន៍ការងារ១៥ឆ្នាំទៅ១៩ឆ្នាំ ដែលមានចំនួន២នាក់ស្រី០នាក់ គិតជាភាគរយស្មើ ៣៣.៣០%។ ការិយាល័យអប់រំស្រុក ដែលមាន បទពិសោធន៍ការងារ២០ឆ្នាំឡើងទៅដែលមានចំនួន២នាក់ស្រី០នាក់គិតជាភាគរយស្មើ ៣៣.៣០%។ តាមរយៈតារាងខាងលើយើងអាចសន្និដ្ឋានបានថាការិយាល័យអប់រំស្រុក ដែលមានបទពិសោធន៍ ការងារច្រើនឆ្នាំនិងធ្វើឲ្យវិស័យអប់រំកាន់តែអភិវឌ្ឍឈានឡើងបានល្អប្រសើរ។

**ផ្នែកទី៦ ដំណើការ ការគ្រប់គ្រងរដ្ឋបាលការិយាល័យអប់រំស្រុក**

| ដំណើការ ការគ្រប់គ្រងរដ្ឋបាលការិយាល័យអប់រំស្រុក | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 6 | លោក-លោកស្រីប្រធានការិយាល័យអប់រំស្រុកមានផែនការប្រតិបត្តិប្រចាំឆ្នាំ(SEIP) ហើយអនុវត្តបាន | 4.50 | 0.54 | ខ្ពស់ |
| 7 | លោក-លោកស្រីប្រធានការិយាល័យ ជំរុញនិងលើកទឹកចិត្តគណៈនាយកឲ្យគោរពនិយ័តភាពក្នុងការបំពេញភារកិច្ច(SEIP) ដើម្បីអភិវឌ្ឍការការគ្រប់គ្រង បង្រៀន និងរៀន | 4.66 | 0.51 | ខ្ពស់ |
| 8 | លោក-លោកស្រីប្រធានការិយាល័យ បានធ្វើការប្រជុំផ្សព្វផ្សាយវិធីសាស្ត្របង្រៀបបែបថ្មី(SEIP) ដល់គណៈនាយក លោកគ្រូអ្នកគ្រូ | 4.50 | 0.54 | ខ្ពស់ |
| 9 | លោក-លោកស្រីប្រធានការិយាល័យ បានរៀបចំដឹកនាំក្នុងការរៀបចំតេស្តប្រឡងសិស្សថ្នាក់ទី៦ឡើងទី៧ (SEIP) | 4.60 | 0.51 | ខ្ពស់ |
| សរុប | | 4.35 | 0.09 | ខ្ពស់ |

តារាងទី៦ ៖ ការគ្រប់គ្រងរដ្ឋបាល(ការិយាល័យអប់រំស្រុក)

តាមរយៈតារាងខាងលើបានបង្ហាញថាការិយាល័យអប់រំស្រុក បានរៀបចំផែនការផែនការ ប្រតិបត្តិប្រចាំឆ្នាំ(SEIP)មានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ ក្នុងនោះ ប្រធានការិយាល័យ ជំរុញនិងលើកទឹកចិត្តគណៈនាយកឲ្យគោរពនិយ័តភាពក្នុងការបំពេញភារកិច្ច (SEIP) ដើម្បីអភិវឌ្ឍការការគ្រប់គ្រង បង្រៀន និងរៀនមានតម្លៃមធ្យម(Mean)=4.66 , SD=0.51

ស្ថិតនៅកម្រិតខ្ពស់។ប្រធានការិយាល័យ បានធ្វើការប្រជុំផ្សព្វផ្សាយវិធីសាស្ត្របង្រៀបបែបថ្មី(SEIP) ដល់គណៈនាយក លោកគ្រូ អ្នកគ្រូ មានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ លោក-លោកស្រីប្រធានការិយាល័យ បានរៀបចំដឹកនាំក្នុងការរៀបចំតេស្តប្រឡងសិស្សថ្នាក់ទី៦ឡើងទី៧ (SEIP)មានតម្លៃមធ្យម(Mean)=4.60 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ សរុបមកការការគ្រប់គ្រងរដ្ឋបាលការិយាល័យអប់រំ មានតម្លៃមធ្យម(Mean)=4.35 ,SD=0.09 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថាក្នុងចំណោមសូចនាករទាំង៦ មានសូចនាករទី៥(ការគ្រប់គ្រងរដ្ឋបាល) និងទី៦(ជំរុញនិងលើកទឹកចិត្តគណៈនាយកឲ្យគោរពនិយ័តភាពក្នុងការបំពេញភារកិច្ច(SEIP) ដើម្បីអភិវឌ្ឍការការគ្រប់គ្រង បង្រៀន និងរៀន) មានតម្លៃមធ្យម(Mean)=4.66 , SD=0.51ស្ថិតនៅកម្រិតខ្ពស់។ ក្នុងចំណោមទាំងនោះមានសូចនាករលោក-លោកស្រីប្រធានការិយាល័យ បានធ្វើការប្រជុំផ្សព្វផ្សាយវិធីសាស្ត្របង្រៀបបែបថ្មី(SEIP) ដល់គណៈនាយក លោកគ្រូ អ្នកគ្រូ មានតម្លៃមធ្យម(Mean)=4.45 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ សរុបមកការគ្រប់គ្រងរដ្ឋបាលការិយាល័យអប់រំស្រុក មានតម្លៃមធ្យម(Mean)=4.35 ,SD=0.09 ស្ថិតនៅកម្រិតខ្ពស់។

**ផ្នែកទី៧៖ ការគ្រប់គ្រងបច្ចេកទេស**

| **ការគ្រប់គ្រងបច្ចេកទេស** | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 10 | លោក-លោកស្រីប្រធានការិយាល័យជំរុញឲ្យគណៈនាយក ក្រុមបច្ចេកទេសនីមួយៗ(SEIP)ផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន ដើម្បីលទ្ធផលសិក្សាសិស្សមានគុណភាព | 4.60 | 0.51 | ខ្ពស់ |
| 11 | លោក-លោកស្រីប្រធានការិយាល័យ លើកទឹកចិត្តគណៈនាយកគ្រូបង្រៀនឲ្យស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ(SEIP)ដើម្បីឲ្យការសិក្សារបស់សិស្សមានគុណភាព | 4.66 | 0.51 | ខ្ពស់ |
| 12 | លោក-លោកស្រីប្រធានការិយាល័យចុះអធិការកិច្ចការ | 4.33 | 0.81 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| | គណៈនាយកការបង្រៀនរបស់គ្រូ និងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូបានញឹកញាប់(SEIP) | | | |
| 13 | លោក-លោកស្រីប្រធានការិយាល័យ តែងជំរុញឲ្យគណៈនាយកគ្រូគ្រប់រូបរៀបចំកិច្ចតែងការបង្រៀននិងណែនាំឲ្យបង្រៀនទៅតាម(SEIP) គោលវិធីសិស្សមជ្ឈមណ្ឌលវិធីសាស្ត្រិះរក(SEIP) ដើម្បីជួយសិស្សឲ្យទទួលបានចំណេះដឹងប្រកបដោយគុណភាពឆ្លើយតបតម្រូវការទីផ្សារការងារ | 4.50 | 0.54 | ខ្ពស់ |
| សរុប | | 4.52 | 0.14 | ខ្ពស់ |

តារាងទី៧ ៖ ការគ្រប់គ្រងបច្ចេកទេស (ការិយាល័យអប់រំស្រុក)

តាមរយៈតារាងបង្ហាញថា ការិយាល័យជំរុញឲ្យគណៈនាយក ក្រុមបច្ចេកទេសនីមួយៗ (SEIP)ផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន ដើម្បីលទ្ធផលសិក្សាសិស្សមានគុណភាពមានតម្លៃមធ្យម(Mean)=4.160, SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ លើកទឹកចិត្តគណៈនាយកគ្រូបង្រៀនឲ្យស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ(SEIP)ដើម្បីឲ្យការសិក្សារបស់សិស្សមានគុណភាពមានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យចុះអធិការកិច្ចការគណៈនាយកការបង្រៀនរបស់គ្រូ និងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូបានញឹកញាប់(SEIP) មានតម្លៃមធ្យម(Mean)=4.33 , SD=0.81 ស្ថិតនៅកម្រិតខ្ពការិយាល័យ តែងជំរុញឲ្យគណៈនាយកគ្រូគ្រប់រូបរៀបចំកិច្ចតែងការបង្រៀននិងណែនាំឲ្យបង្រៀនទៅតាម(SEIP) គោលវិធីសិស្សមជ្ឈមណ្ឌលវិធីសាស្ត្រិះរក(SEIP) ដើម្បីជួយសិស្សឲ្យទទួលបានចំណេះដឹងប្រកបដោយគុណភាពឆ្លើយតបតម្រូវការទីផ្សារការងារ មានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ សរុបមក ការគ្រប់គ្រងក្រុមបច្ចេកទេសការិយាល័យអប់រំស្រុកមានតម្លៃមធ្យម(Mean)=4.52 , SD=0.14 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោមសូចនាករទាំង៦មានសូចនាករទី៥(ការគ្រប់គ្រងក្រុមបច្ចេកទេស)និង ទី៦(ការិយាល័យ លើកទឹកចិត្តគណៈនាយកគ្រូបង្រៀនឲ្យស្រាវជ្រាវ

រកវិធីសាស្ត្របង្រៀនថ្មីៗ(SEIP) ដើម្បីឲ្យការសិក្សារបស់សិស្សមានគុណភាព)មានតម្លៃមធ្យម (Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ក្នុងចំណោមទាំងនោះមានសូចនាករការិយាល័យចុះអធិការកិច្ចការគណៈនាយកការបង្រៀនរបស់គ្រូ និងបានពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូបានញឹកញាប់(SEIP)ទាប មានតម្លៃមធ្យម(Mean)=4.33 , SD=0.81 ស្ថិតនៅកម្រិតខ្ពស់។ រុបមកការគ្រប់គ្រងក្រុមបច្ចេកទេសរបស់ការិយាល័យអប់រំស្រុកមានតម្លៃមធ្យម(Mean)=4.52 ,SD=0.14 ស្ថិតនៅកម្រិតខ្ពស់។

**ផ្នែកទី៨៖ ការគ្រប់គ្រងថវិកា**

| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
|---|---|---|---|---|
| 14 | លោក-លោកស្រីប្រធានការិយាល័យរៀបចំដំណើរការគ្រប់គ្រងថវិកាសាលារៀន(SEIP)ដោយមានរបៀបរៀបរយតាមច្បាប់កំណត់ | 4.39 | 0.93 | ខ្ពស់ |
| 15 | លោក-លោកស្រីប្រធានការិយាល័យ តែងតែទទួលបានរាយការណ៍ការចាយវាយថវិកា(SEIP)ដល់គណៈកម្មការតាមអង្គភាពផ្សេងៗនៅពេលចាយវាយដោយតម្លាភាព | 4.52 | 0.07 | ខ្ពស់ |
| 16 | លោក-លោកស្រីប្រធានការិយាល័យ ជំរុញលើកទឹកចិត្តគណៈនាយក គ្រូ(SEIP) ឲ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀនដើម្បីយកមកអភិវឌ្ឍសាលារៀន | 4.16 | 1.00 | ខ្ពស់ |
| 17 | ការប្រជុំប្រចាំខែនីមួយៗ(SEIP)លោក-លោកស្រីតែងលើកយកការប្រើប្រាស់ថវិកាមកផ្សព្វផ្សាយប្រាប់ដល់គណៈនាយកដើម្បីឲ្យដំណើរការផ្តត់ផ្គង់ថវិកានៅក្នុងអង្គភាពសាលារៀនមានតម្លាភាព | 4.31 | 0.86 | ខ្ពស់ |
| សរុប | | 4.34 | 0.15 | |

តារាងទី៨ ៖ ការគ្រប់គ្រងថវិកា(ការិយាល័យអប់រំស្រុក)

តាមរយៈតារាងបង្ហាញថា ការគ្រប់គ្រងថវិការបស់(ការិយាល័យអប់រំស្រុក)ឃើញថាមានការិយាល័យរៀបចំដំណើរការគ្រប់គ្រងថវិកាសាលារៀន(SEIP)ដោយមានរបៀបរៀបរយតាមច្បាប់កំណត់មានតម្លៃមធ្យម(Mean)=4.39 , SD=0.93 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ តែងតែទទួល

បានវាយការណ៍ការចាយវាយថវិកា(SEIP) ដល់គណៈកម្មការតាមអង្គភាពផ្សេងៗនៅពេលចាយវាយ ដោយតម្លាភាពមានតម្លៃមធ្យម(Mean)=4.52 , SD=0.07 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ ជំរុញ លើកទឹកចិត្តគណៈនាយក គ្រូ(SEIP) ឲ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀនដើម្បីយកមកអភិវឌ្ឍ សាលារៀនមានតម្លៃមធ្យម(Mean)=4.16 , SD=1.00 ស្ថិតនៅកម្រិតខ្ពស់។ ការប្រជុំប្រចាំខែនីមួយៗ (SEIP) លោក-លោកស្រីតែងលើកយកការប្រើប្រាស់ថវិកាមកផ្សព្វផ្សាយប្រាប់ដល់គណៈនាយក ដើម្បីឲ្យដំណើរការផ្គត់ផ្គង់ថវិកានៅក្នុងអង្គភាពសាលារៀនមានតម្លាភាពមានតម្លៃមធ្យម (Mean)= 4.31 , SD=0.86 ស្ថិតនៅកម្រិតខ្ពស់។ សរុបមកការគ្រប់គ្រងថវិកា(ការិយាល័យអប់រំស្រុក) មានតម្លៃ មធ្យម(Mean)=4.34 , SD=0.15 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោមការគ្រប់គ្រងថវិកា(ការិយាល័យអប់រំ ស្រុក)សូចនាករទាំង៦(ការិយាល័យអប់រំស្រុក) និងទី៦(ការិយាល័យ តែងតែទទួលបានវាយការណ៍ ការចាយវាយថវិកា(SEIP)ដល់គណៈកម្មការតាមអង្គភាពផ្សេងៗនៅពេលចាយវាយដោយតម្លាភាព) មានតម្លៃមធ្យម(Mean)=4.52 , SD=0.07 ស្ថិតនៅកម្រិតខ្ពស់។ ក្នុងចំណោមទាំងនោះមានសូចនា ករការប្រជុំប្រចាំខែនីមួយៗ(SEIP) លោក-លោកស្រីតែងលើកយកការប្រើប្រាស់ថវិកាមកផ្សព្វផ្សាយ ប្រាប់ដល់ គណៈនាយកដើម្បីឲ្យដំណើរការផ្គត់ផ្គង់ថវិកា នៅក្នុងអង្គភាពសាលារៀនមានតម្លាភាព ទាបវត្តមានតម្លៃមធ្យម(Mean)=4.16 , SD=1.00 ស្ថិតនៅកម្រិតខ្ពស់។ រុបមកការគ្រប់គ្រងថវិកា សាលារៀន មានតម្លៃមធ្យម(Mean)=4.34 , SD=0.15 ស្ថិតនៅកម្រិតខ្ពស់។

**ផ្នែកទី៩៖ ការគ្រប់គ្រងបុគ្គលិក**

| ការគ្រប់គ្រងបុគ្គលិក | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 18 | លោកនាយកមានការជំរុញលើកទឹកចិត្តគណៈនាយកគ្រូបង្រៀនក្នុងការចូលរួមបណ្តុះបណ្តាលបន្ត(SEIP) តាមកម្រិតវិជ្ជាជីវៈស្របតាមគុណវុឌ្ឍិ | 4.66 | 0.51 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| 19 | លោក-លោកស្រីប្រធានការិយាល័យ តែងជំរុញលើកទឹកចិត្តដល់គណៈនាយកគ្រូ(SEIP)ឲ្យមានការប្រាស្រ័យទំនាក់ទំនងល្អនៅក្នុងអង្គភាពមិនថាជាមួយសិស្ស គ្រូគ្នាឯងនិងជាមួយគណៈគ្រប់គ្រងដើម្បីដំណើរការបង្រៀនមានប្រសិទ្ធភាព | 4.50 | 0.54 | ខ្ពស់ |
| 20 | លោក-លោកស្រីប្រធានការិយាល័យតែងត្រួតពិនិត្យតាមដានការមកបំពេញការងាររបស់គណៈនាយក គ្រូ(SEIP) ជាប្រចាំដើម្បីឲ្យមានតម្លាភាព យុត្តិធម៌ដល់គណៈនាយកគ្រូដទៃ | 4.33 | 0.81 | ខ្ពស់ |
| សរុប | | 4.49 | 0.16 | ខ្ពស់ |

តារាងទី៩ ការគ្រប់គ្រងបុគ្គលិក(ការិយាល័យអប់រំស្រុក)

តាមរយៈតារាងបង្ហាញថា ការគ្រប់គ្រងបុគ្គលិករបស់(ការិយាល័យអប់រំស្រុក)ឃើញថាមានលោកនាយកមានការជំរុញលើកទឹកចិត្ត គណៈនាយកគ្រូបង្រៀនក្នុងការចូលរួមបណ្ដុះបណ្ដាលបន្ត(SEIP) តាមកម្រិតវិជ្ជាជីវៈស្របតាមគុណវុឌ្ឍិ មានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ តែងជំរុញលើកទឹកចិត្តដល់គណៈនាយកគ្រូ(SEIP)ឲ្យមានការប្រាស្រ័យទំនាក់ទំនងល្អនៅក្នុងអង្គភាពមិនថាជាមួយសិស្ស គ្រូគ្នាឯងនិងជាមួយគណៈគ្រប់គ្រងដើម្បីដំណើរការបង្រៀនមានប្រសិទ្ធភាពមានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យតែងត្រួតពិនិត្យតាមដានការមកបំពេញការងាររបស់គណៈនាយក គ្រូ(SEIP) ជាប្រចាំដើម្បីឲ្យមានតម្លាភាព យុត្តិធម៌ដល់គណៈនាយកគ្រូដទៃមានតម្លៃមធ្យម(Mean)=4.33 , SD=0.81 ស្ថិតនៅកម្រិតខ្ពស់។ សរុបមក ការគ្រប់គ្រងថវិកា(ការិយាល័យអប់រំស្រុក) មានតម្លៃមធ្យម(Mean)= 4.49 , SD=0.16 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោមការគ្រប់គ្រងបុគ្គលិក(ការិយាល័យអប់រំស្រុក) ទៅតាមសូចនាករ នីមួយ(មានការជំរុញលើកទឹកចិត្តគណៈនាយកគ្រូបង្រៀនក្នុងការចូលរួមបណ្ដុះបណ្ដាលបន្ត(SEIP) តាមកម្រិតវិជ្ជាជីវៈស្របតាមគុណវុឌ្ឍិ) មានតម្លៃមធ្យម(Mean)= 4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ក្នុងចំណោមទាំងនោះមានសូចនាករ ការិយាល័យតែងត្រួត

ពិនិត្យតាមដានការមកបំពេញការងាររបស់គណៈនាយក គ្រូ(SEIP) ជាប្រចាំដើម្បីឲ្យមានតម្លាភាព យុត្តិធម៌ដល់គណៈនាយកគ្រូដទៃទាប វត្តមានតម្លៃមធ្យម(Mean)=4.33 , SD=0.81 ស្ថិតនៅកម្រិតខ្ពស់។របមកការគ្រប់គ្រងបុគ្គលិក(ការិយាល័យអប់រំស្រុក)មានតម្លៃមធ្យម(Mean)=4.49 ,SD=0.16 ស្ថិតនៅកម្រិតខ្ពស់។

## ផ្នែកទី១០៖ អំពីការទំនាក់ទំនង

| អំពីការទំនាក់ទំនង | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 21 | លោក-លោកស្រីប្រធានការិយាល័យ មានការមានការផ្សព្វផ្សាយស្តីពីសិស្សរៀនយឺត(SEIP) ទៅកាន់មាតាបិតាអាណាព្យាបាល អាជ្ញាធរដែនដី សហគមន៍ | 4.66 | 0.51 | ខ្ពស់ |
| 22 | លោក-លោកស្រីប្រធានការិយាល័យ បានចុះពិនិតនិងសង្កេតលើ(SEIP) ការប្រឡងតេស្តសិស្ស ប្រចាំខែធមាស | 4.50 | 0.54 | ខ្ពស់ |
| 23 | លោក-លោកស្រីប្រធានការិយាល័យមានការមានការផ្សព្វផ្សាយ(SEIP)ស្តីពីសិស្សរៀនយឺតទៅកាន់សាលាបណ្តាញតាមគោលដៅ ជំរុញសាលាបណ្តាញក្នុងការចូលរួម | 4.50 | 0.54 | ខ្ពស់ |
| 24 | លោក-លោកស្រីប្រធានការិយាល័យធ្វើការទំនាកទំនងមានភាពងាយស្រួលប្រជុំក្នុងការសម្របសម្រួលជាមួយអាជ្ញាធរដែនដីមាតាបិតា អាណាព្យាបាលសិស្ស(SEIP) | 4.66 | 0.51 | ខ្ពស់ |
| សរុប | | **4.58** | 0.09 | |

តារាងទី១០ អំពីការទំនាក់ទំនង(ការិយាល័យអប់រំស្រុក)

តាមរយៈតារាងបង្ហាញថា ការទំនាក់ទំនងរបស់(ការិយាល័យអប់រំស្រុក)ការិយាល័យ មានការមានការផ្សព្វផ្សាយស្តីពីសិស្សរៀនយឺត(SEIP) ទៅកាន់មាតាបិតាអាណាព្យាបាល អាជ្ញាធរដែនដីសហគមន៍មានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ បានចុះពិនិតនិងសង្កេតលើ(SEIP) ការប្រឡងតេស្តសិស្ស ប្រចាំខែ ធមាស មានតម្លៃមធ្យម(Mean)=4.50 ,

SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យ មានការមានការផ្សព្វផ្សាយ(SEIP)ស្តីពីសិស្សរៀនយឺតទៅកាន់ សាលាបណ្តាញតាមគោលដៅ ជំរុញសាលាបណ្តាញក្នុងការចូលរួមមានតម្លៃមធ្យម (Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ ការិយាល័យធ្វើការទំនាកទំនងមានភាពងាយស្រួលប្រជុំក្នុងការសម្របសម្រួលជាមួយ អាជ្ញាធរដែនដី មាតាបិតាអ្នកអាណាព្យាបាលសិស្ស(SEIP)មានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ សរុបមក ការទំនាក់ទំនង(ការិយាល័យអប់រំស្រុក) មានតម្លៃមធ្យម(Mean)=4.58 , SD=0.09 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោមការទំនាក់ទំនង ទៅតាមសូចនាករនីមួយ(ការិយាល័យធ្វើការទំនាកទំនងមានភាពងាយស្រួលប្រជុំក្នុងការសម្របសម្រួលជាមួយ អាជ្ញាធរដែនដី មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស(SEIP)) មានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ក្នុងចំណោមទាំងនោះមានសូចនាករការិយាល័យ មានការមានការផ្សព្វផ្សាយ (SEIP)ស្តីពីសិស្សរៀនយឺតទៅកាន់ សាលាបណ្តាញតាមគោលដៅ ជំរុញសាលាបណ្តាញក្នុងការចូលរួមទាបមានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ សរុបមកការទំនាក់ទំនង (ការិយាល័យអប់រំស្រុក) មានតម្លៃមធ្យម(Mean)=4.58 , SD=0.09 ស្ថិតនៅកម្រិតខ្ពស់។

**ផ្នែក១១ ផលជះនៃគម្រោងកែលម្អគុណភាពអប់រំហៅថា**(SEIP)

| **ផលជះនៃគម្រោងកែលម្អគុណភាពអប់រំហៅថា**(SEIP) | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 25 | លោក លោកស្រីយល់ពីគោលបំណង និងសារៈសំខាន់នៃតេស្តអំណានស្ទាត់ភាសាខ្មែរ និងគណិតវិទ្យា | 4.50 | 0.54 | ខ្ពស់ |
| 26 | លោកលោកស្រីចូលរួមតាមដាន និងត្រួតពិនិត្យដំណើរការសរសេរវិញ្ញាសា (តេស្ត)ភាសាខ្មែរ និងគណិតវិទ្យា | 4.50 | 0.83 | ខ្ពស់ |
| 27 | លោក លោកស្រីទទួលបានព័ត៌មាន ឬលទ្ធផលតេស្តភាសាខ្មែរ និងគណិតវិទ្យា | 4.66 | 0.51 | ខ្ពស់ |
| សរុប | | 4.55 | 0.09 | ខ្ពស់ |

តារាងទី១១៖ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា(ការិយាល័យអប់រំស្រុក)

តាមរយៈតារាងបង្ហាញថា យល់ពីការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងយល់ពីគោលបំណង និងសារៈសំខាន់នៃតេស្តអំណានស្ទាត់ភាសាខ្មែរ និងគណិតវិទ្យា ដល់ បុគ្គលិក សិស្ស ដំណើការមាន ប្រសិទ្ធភាពខ្ពស់ និងការពេញចិត្តនិងនាយកយល់ពីគោលបំណង និងសារៈសំខាន់នៃតេស្តអំណាន ស្ទាត់ភាសាខ្មែរ និងគណិតវិទ្យាអនុវត្តមានតម្លៃមធ្យម(Mean)=4.50 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ ចូលរួមតាមដាន និងត្រួតពិនិត្យដំណើរការសរសេរវិញ្ញាសា (តេស្ត)ភាសាខ្មែរ និងគណិតវិទ្យា មានតម្លៃមធ្យម(Mean)=4.50 , SD=0.83 ស្ថិតនៅកម្រិតខ្ពស់។ ទទួលបានព័ត៌មាន ឬលទ្ធផលតេស្ត ភាសាខ្មែរ និងគណិតវិទ្យាមានតម្លៃមធ្យម(Mean)=4.66 , SD= 0.51 ស្ថិតនៅកម្រិតខ្ពស់។ សរុបមក ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា(ការិយាល័យអប់រំស្រុក) មានតម្លៃមធ្យម (Mean)=4.55 , SD=0.09 ស្ថិតនៅកម្រិតខ្ពស់។

សរុបតាមតារាងខាងលើបានបង្ហាញថា ក្នុងចំណោម ការអនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និង គណិតវិទ្យា(ការិយាល័យអប់រំស្រុក)ទៅតាមសូចនាករនីមួយ(ទទួលបានព័ត៌មាន ឬលទ្ធផលតេស្ត ភាសាខ្មែរ និងគណិតវិទ្យា) មានតម្លៃមធ្យម(Mean)=4.66 , SD=0.51 ស្ថិតនៅកម្រិតខ្ពស់។ ក្នុង ចំណោមទាំងនោះមានសូចនាករយល់ពីគោលបំណង និងសារៈសំខាន់នៃតេស្តអំណានស្ទាត់ភាសាខ្មែរ និងគណិតវិទ្យាទាប មានតម្លៃមធ្យម(Mean)=4.54 , SD=0.54 ស្ថិតនៅកម្រិតខ្ពស់។ សរុបមកការ អនុវត្តតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា(ការិយាល័យអប់រំស្រុក) មានតម្លៃមធ្យម(Mean)=

4.55,SD=0.09ស្ថិតនៅកម្រិតខ្ពស់។




## ការិយាល័យអប់រំស្រុកក្នុងការចូលរួមគម្រោងដើម្បីបន្តគម្រោងមាននិរន្តរភាព




## ៤.៣.២ ការវិភាគទិន្នន័យទម្រង់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន

### ផ្នែកទី១ ពត៌មានទូទៅ

**១.ភេទ**

| ល.រ | ភេទ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | សរុបភាគរយ |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | គណៈកម្មការគ្រប់គ្រងសាលារៀន | ៣៧ | ៩២.៥០% | ៣ | ៧.៥០% | ៤០ | ១០០% |
| សរុប | | ៣៧ | ៩២.៥០% | ៣ | ៧.៥០% | ៤០ | ១០០% |

រូបភាពទី២ ៖ ភេទ (អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)

អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន បានចូលរួមបានចូលរួមក្នុងកម្រងសំណួរទាំងអស់គ្នាមានចំនួន៤០នាក់។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានភេទប្រុសមានភាគរយខ្ពស់ជាង៩២.៥០% ចំណែកការិយាល័យអប់រំស្រុកជាស្ត្រីមានចំនួន៣នាក់គិតជាភាគរយ៧.50%។តាមរយៈតារាងខាងលើ យើងអាសន្និដ្ឋានបានថា អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនភាគច្រើនជាបុរស។

**២.អាយុ**

| ល.រ | អាយុ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ២០ទៅ៣០ឆ្នាំ | ០ | ១ | ១ | ២.៥០% |
| ២ | ៣១ទៅ៤០ឆ្នាំ | ៣ | ១ | ៤ | ១០.០០% |
| ៣ | ៤១ទៅ៥១ឆ្នាំ | ៣៥ | ០ | ៣៥ | ៨៧.៥០% |
| សរុប | | ៣៨ | ២ | ៤០ | ១០០% |

រូបភាពទី២៖ អាយុ(អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)

ក្នុងចំណោមអាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលបានចូលរួមបំពេញកម្រងសំណួរតាមកម្រិតអាយុ ផ្សេងៗគ្នា។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានចន្លោះអាយុពី២០ទៅ៣០ឆ្នាំ ភេទជាស្ត្រីមាន១នាក់ គិតភាគរយ២.៥០%និងមានចន្លោះអាយុ៣១ទៅ៤០ឆ្នាំ មានចំនួន៤នាក់ស្មើ១០.០០% និងចន្លោះពី៤១ទៅ៥១ឆ្នាំ ដែលមានអ្នកចូលរួមបុរសចំនួន៣៥នាក់គិតជាភាគរយ៨៧.៥០%។ តាមតារាងខាងលើយើងអាចសន្និដ្ឋានបានថាការិយាល័យអាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន ភាគច្រើនមានជាក្រុមបុរសមានចំនួន៣៨នាក់ស្រី

ចំនួន៣នាក់ជាក្រុមមនុស្ស ដែលមានសក្តានុពលសម្រាប់ការចូលរួមការអភិវឌ្ឍនវិស័យអប់រំថ្នាក់សាលារៀនកាន់តែរីកចម្រើន។

## ផ្នែកទី៣ កម្រិតវប្បធម៌

| ល.រ | កម្រិតវប្បធម៌ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | អនុវិទ្យាល័យ | ២៣ | ០ | ២៣ | ៧៥.៥០% |
| ២ | វិទ្យាល័យ | ៨ | ១ | ៩ | ២២.៥០% |
| ៣ | បរិញ្ញាបត្រ | ៦ | ០ | ៦ | ១៥.០០% |
| ៤ | បរិញ្ញាបត្រជាន់ខ្ពស់ | ២ | ០ | ២ | ៥.០០% |
| ៥ | បណ្ឌិត | ០ | ០ | ០ | ០ |
| សរុប | | ៣៩ | ១ | ៤០ | ១០០% |

រូបភាពទី៣៖កម្រិតវប្បធម៌(អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)

ក្នុងចំណោមអាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលបានចូលរួមបំពេញកម្រងសំណួរទាំងអស់មានមានកម្រិតវប្បធម៌។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនមានអនុវិទ្យាល័យចំនួន២៣នាក់ស្រីចំនួន០នាក់ស្មើចំនួន៧៥.៥០% និងវិទ្យាល័យចំនួន៨នាក់និងស្រីចំនួន១នាក់ស្មើ២២.៥០%។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនមានបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន៦នាក់ជាបុរស៦ស្រី០នាក់ស្មើនិងចំនួន១៥.០០%និងបរិញ្ញាបត្រជាន់ខ្ពស់អ្នកចូលរួម២នាក់ស្រី០នាក់គិតជាភាគរយ៥%។ តាមរយៈតារាងខាងលើយើងអាចសន្និដ្ឋានបានថាកម្រិតវប្បធម៌របស់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនអនុវិទ្យាទ្យាល័យមានបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់។

## ផ្នែកទី៥ បទពិសោធន៍ការងារ

| ល.រ | បទពិសោធន៍ការងារ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ក្រោម៥ឆ្នាំ | ២ | ១ | ៣ | ៧.៥០ |
| ២ | ៥ឆ្នាំទៅ៩ឆ្នាំ | ១៥ | ០ | ១៥ | ៣៩.៥០% |
| ៣ | ១០ឆ្នាំទៅ១៤ឆ្នាំ | ១២ | ០ | ១២ | ៣០.០០% |

| | | | | | |
|---|---|---|---|---|---|
| ៤ | ១៥ឆ្នាំទៅ១៩ឆ្នាំ | ៣ | ០ | ៣ | ៧.៥០% |
| ៥ | ២០ឆ្នាំឡើងទៅ | ៧ | ០ | ៧ | ១៧.៥០% |
| សរុប | | ៣៩ | ១ | ៤០ | ១០០% |

តារាងទី៥ ៖បទពិសោធន៍ការងារ(អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)

ក្នុងចំណោម អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានបទពិសោធន៍ការងារក្រោម៥ឆ្នាំមានចំនួន២នាក់ស្រី១នាក់ស្មើ៧.៥០%។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានបទពិសោធន៍ការងារ៥ឆ្នាំទៅ៩ឆ្នាំ មានចំនួន១៥នាក់ស្រី០នាក់ស្មើនឹង៩.៥០%។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន ដែលមានបទពិសោធន៍ការងារ១០ឆ្នាំទៅ១៤ឆ្នាំដែលមានចំនួន១២នាក់ស្រី០នាក់គិតជាភាគរយស្មើ ៣០.០០%។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានបទពិសោធន៍ការងារ១៥ឆ្នាំឡើងទៅ១៩ឆ្នាំ ដែលមានចំនួន៣នាក់ស្រី០នាក់គិតជាភាគរយស្មើ ៧.៥០%។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានបទពិសោធន៍ការងារ២០ឆ្នាំឡើងទៅដែលមានចំនួន៧នាក់ស្រី០នាក់គិតជាភាគរយស្មើ ១៧.៥០%។តាមរយៈតារាងខាងលើយើងអាចសន្និដ្ឋានបានថាអាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនដែលមានបទពិសោធន៍ការងារច្រើនឆ្នាំ ក្នុងការជំរុញសាលារៀនជាពិសេសធ្វើឲ្យវិស័យអប់រំកាន់តែអភិវឌ្ឍឈានឡើងបានល្អប្រសើរ។

## ផ្នែកទី៦ អំពីការចូលរួមអភិវឌ្ឍសាលារៀន

| អំពីការចូលរួមអភិវឌ្ឍសាលារៀន | | | | |
|---|---|---|---|---|
| ល.រ | បរិយាកាស | MEAN | SD | អត្ថន័យ |
| 6 | ចូលរួមធ្វើផែនការកែកម្មសាលារៀនសម្រាប់ខែ ឆមាស និងប្រចាំឆ្នាំ(SEIP) | 4.85 | 0.36 | ខ្ពស់ |
| 7 | ចូលរួមផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាឱ្យបញ្ជូនកូនទៅរៀនគ្រប់ៗគ្នា(SEIP) | 4.90 | 0.30 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| 8 | ចូលរួមលើកទឹកចិត្តដាក់ផែនការជាមួយឪពុកម្តាយសិស្សការអានសៀវភៅនិងស្រាវជ្រាវកិច្ចការផ្ទះ | 4.90 | 0.30 | ខ្ពស់ |
| សរុប | | 4.88 | 0.02 | ខ្ពស់ |

តារាងទី៦៖អំពីការចូលរួមអភិវឌ្ឍនសាលារៀន(អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)

តាមរយៈតារាងបង្ហាញពីការចូលរួមអភិវឌ្ឍនសាលារៀន របស់អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលាមានចូលរួមធ្វើផែនការកែកម្មសាលារៀនសម្រាប់ខែ ឆមាស និងប្រចាំឆ្នាំ(SEIP)មានតម្លៃមធ្យម(Mean)=4.85 , SD=0.36 ស្ថិតនៅកម្រិតខ្ពស់។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនចូលរួមផ្សព្វផ្សាយដល់សហគមន៍ មាតាបិតាឱ្យបញ្ជូនកូនទៅរៀនគ្រប់ៗគ្នា(SEIP)មានតម្លៃមធ្យម(Mean)=4.90 , SD=0.30 ស្ថិតនៅកម្រិតខ្ពស់។ អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀនចូលរួមលើកទឹកចិត្តដាក់ផែនការជាមួយឪពុកម្តាយសិស្សការអានសៀវភៅ និងស្រាវជ្រាវកិច្ចការផ្ទះមានតម្លៃមធ្យម(Mean)=4.90 , SD=0.30 ស្ថិតនៅកម្រិតខ្ពស់។ សរុបអំពីការចូលរួមអភិវឌ្ឍនសាលារៀន(អាជ្ញាធរដែនដី/គណៈកម្មការគ្រប់គ្រងសាលារៀន)មានតម្លៃមធ្យម(Mean)= 4.88 , SD=0.02 ស្ថិតនៅកម្រិតខ្ពស់។

